ទស្សនាវដ្ដីរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា

# ស្វែងរក ការពិត



- គ្មានយុត្តិធម៌ គ្មានសន្តិភាព គ្មានតុលាការ គ្មានយុត្តិធម៌
- ការសេចសីគមកពីជំនាន់ប៉ុលពត

លេខ១២ ខែធ្នូ ឆ្នាំ២០០០

ទស្សនាវដ្ដីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

លេខ១២ ខែធ្នូ ឆ្នាំ២០០០

## មាតិកា

◆សំបុត្រៈ គ្មានយុត្តិធម៌ គ្មានសន្តិភាព....................................១

**ផ្នែកឯកសារ**

◆សេចក្ដីថ្លែងការណ៍រួមរវាងព្រះរាជាណាចក្រកម្ពុជា.......................៥

◆អ្នកសួរចម្លើយនៅមន្ទីរស-២១ត្រូវអន្ដការចាប់ខ្លួន.....................៦

◆រណ្ដៅសាកសពប្រល័យពូជសាសន៍នៅខេត្តបាត់ដំបង..............១០

◆ប្រវត្តិរូបសមមិត្ត ម៉ុន....................................................១៣

◆លក្ខណៈសម្បត្តិ១០«ខ»របស់បក្ស.......................................១៤

◆ចាមដែលជាកម្មាភិបាលខ្មែរក្រហម......................................១៧

◆យុវជនស្នេហាជាតិ.........................................................២០

**ផ្នែកប្រវត្តិសាស្ត្រ**

◆សម្លេងពីមន្ទីរស-២១.......................................................២២

**ផ្នែកច្បាប់**

◆ការដកស្រង់មាត្រាដែលពាក់ព័ន្ធនឹង.......................................២៩

◆គំរូមួយនៃភ័ស្តុតាងឯកសារភ្ជាប់មេដឹកនាំជាន់ខ្ពស់.....................៣០

◆សេចក្ដីប្រកាសរបស់រាជរដ្ឋាភិបាលកម្ពុជា.............................៣៤

**វេទិកាពិភាក្សាជាសាធារណៈ**

◆យុត្តិធម៌ដែលត្រូវបានពន្យារពេលនៅកម្ពុជា............................៣៥

◆ការសងសឹកក្នុងជំនាន់ប៉ុលពត.............................................៣៨

◆ការលើកលែងទោស........................................................៤២

◆ថ្លៃចងកំហឹង...............................................................៤៨

**ទំព័រស្រាវជ្រាវរកគ្រួសារ**

◆សៀវភៅកំណត់ហេតុជីវិត.................................................៥៣

◆គ្រួសារ ភោគ ឆាយ.........................................................៥៦

◆១៧ មេសា ប៉ាលែងបានបន្ទោះខ្លែងឲ្យខ្ញុំរហូត......................៥៨

**សិល្បៈខ្មែរក្រហម**

◆**ចម្រៀងខ្មែរក្រហមៈ** ដំនោរកត្តឹក...............................ក្របក្រោ





ជនរងគ្រោះក្រោមរបបខ្មែរក្រហម

## រក្សាសិទ្ធិ

មជ្ឈមណ្ឌលឯកសារកម្ពុជា

អនុញ្ញាតឲ្យបោះពុម្ពផ្សាយដោយ
ក្រសួងពត៌មាននៃរាជរដ្ឋាភិបាលកម្ពុជា
ប្រកាសទេសរដ្ឋមន្ត្រី និងរដ្ឋមន្ត្រីក្រសួងពត៌មាន
លេខ ០២៩១ពម.៩៩
ចុះថ្ងៃទី២ ខែសីហា ឆ្នាំ១៩៩៩

រូបថតឯកសារៈ មជ្ឈមណ្ឌលឯកសារកម្ពុជា
និងសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង

***វាគ្មិនលេខនេះៈ*** *ដេវីត ឆេនដល័រ, ស្ទីវ ហេឌ័រ, អាឡិច ហីនតុន, ប៊ែន កៀរនិន, រ៉េឆែល ហួជ, យ៉ាន វ៉ាន់ គ្រីនធិន, អ៊ីសា ឧស្មាន, ហ៊ុយ វណ្ណៈ, វ៉ាន់ថាន់ ពៅដារ៉ា* ***អ្នកនិពន្ធនិងស្រាវជ្រាវៈ*** *សាន់ កល្យាណ, លី សុខុល, ជួង សុភារិទ្ធ* ***ជំនួយការនិពន្ធនាយកៈ*** *អែម សុខឃឹម* ***និពន្ធនាយករងទី១ៈ*** *ផាត កុសល* ***និពន្ធនាយករងទី២ៈ*** *សឹម សុរិយ៉ា* ***អ្នកបកប្រែៈ*** *សួ ប៊ុនស៊ូ* ***និពន្ធនាយកទូទៅៈ*** *ឆាំង យុ* ***ក្រាហ្វិកកុំព្យូទ័រៈ*** *ស៊ឹម សុភ័ក្ត្រ* ***គ្រប់គ្រងការចែកផ្សាយៈ*** *ទ្រី សុភក្ដិ*

*សំបុត្រៈ*

# គ្មានយុត្តិធម៌ គ្មានសន្តិភាព គ្មានតុលាការ គ្មានយុត្តិធម៌

បច្ចុប្បន្ននេះមានប្រជាជនជាច្រើនមិនបានដឹងថាអំពើប្រល័យពូជសាសន៍ដ៏សាហាវបំផុតនៅក្នុងសតវត្សរ៍ទី២០ ត្រូវបានអនុវត្តឡើងដោយរបបកុម្មុយនិស្តឡើយ ។ តួលេខនៃជនរងគ្រោះរាប់លាននាក់នៃរបបស្តាលីន ជនរងគ្រោះរាប់សិបលាននាក់ក្រោមការគ្រប់គ្រងរបស់ម៉ៅនិងប្រភេទនៃអំពើឃោរឃៅរបស់ពួកម៉ាក្ស-លេនីន នៅទូទាំងពិភពលោកក៏ចេះតែមានជាបន្តបន្ទាប់ឥតដាច់ ។

ប៉ុន្តែគួររំពឹកដែរថាចំពោះអំពើប្រល័យពូជសាសន៍ដទៃៗទៀតដូចជាករណីហាយនភាពនៃហ៊ីត្លែរនិងព្រឹត្តិការណ៍ថ្មីៗនៃជនជាតិហ៊ូទូនៅប្រទេសរ៉ាន់ដា ប្រព័ន្ធនយោបាយផ្សេងៗទៀតក៏បានធ្វើឲ្យមានរូបភាពមិនអាចយល់បាន ។ ជាការចាំបាច់ណាស់ក្នុងការបង្កើតឲ្យមានការយល់ដឹងសម្រាប់អនាគតដោយជួយកសាងនូវការតាំងចិត្តរបស់មនុស្សជាតិជាទូទៅថា ការធ្វើការងារទាំងអស់គ្នា យើងពិតជាអាចទប់ស្កាត់កុំឲ្យមានការកើតឡើងនូវអំពើប្រល័យពូជសាសន៍ជាថ្មីទៀត ។

មានមនុស្សជាច្រើនរូបបានខិតខំធ្វើការអស់ជាច្រើនឆ្នាំដើម្បីបញ្ចប់នូវភាពរួចទោសរបស់ក្រុមខ្មែរក្រហមនៅកម្ពុជា ។ ប៉ុន្តែយើងមិនទាន់បានសម្រេចនូវគោលដៅនេះនៅឡើយទេ ហើយយើងមិនត្រូវបញ្ឈប់សកម្មភាពរបស់យើងលុះត្រាតែកិច្ចការនេះបានសម្រេចដោយជោគជ័យ ។

ទោះបីជាអំពើប្រល័យពូជសាសន៍ដែលជាបទឧក្រិដ្ឋមួយបានធ្វើឲ្យមនុស្សជាតិទូទៅមិនអាចយល់បានយ៉ាងងាយបែបណាក៏ដោយ ប៉ុន្តែការដែលថាអំពើឧក្រិដ្ឋមួយដែលអាចឆាបយកជីវិតមនុស្សរាប់លាននាក់ គឺជាឧក្រិដ្ឋកម្មដែលពិតជាអាចទប់ស្កាត់បាន ។ នៅទីក្រុងវ៉ាស៊ីនតោននិងបណ្តាប្រទេសជឿនលឿនដទៃទៀត ជាទូទៅអ្វីៗហាក់ដូចជាស្ងប់ស្ងាត់និងមានសភាពជាធម្មតា ។ នៅក្នុងសភាពបែបនេះយើងមិនអាចប្រមើលឃើញបញ្ហាដូចជាអំពើប្រល័យពូជសាសន៍នោះឡើយ ហើយក៏មិនអាចជឿថាអំពើនេះនឹងអាចកើតឡើងនៅទីនេះពោលគឺកើតឡើងចំពោះយើងទាំងអស់គ្នាដែរ ។ក៏ប៉ុន្តែអ្នកដែលនៅរស់រានមានជីវិតពីអំពើប្រល័យពូជសាសន៍យល់ផ្ទុយស្រឡះពីយើងទាំងអស់គ្នា ពោលគឺយល់ថាអំពើប្រល័យពូជសាសន៍អាចកើតឡើងចំពោះអស់យើងទាំងអស់គ្នាហើយអាចកើតឡើងគ្រប់កន្លែងទាំងអស់ ។

កាលពីឆ្នាំមុនខ្ញុំបានធ្វើទស្សនកិច្ចនៅមជ្ឈមណ្ឌលឯកសារសង្គ្រាមនៅក្នុងទីក្រុងអាមស្ទែរដាមនៃប្រទេសហុល្លង់ ហើយក៏បានទៅមើលសារមន្ទីរ អាន ហ្វ្រែង ។ ទោះជាខ្ញុំធ្វើការរាល់ថ្ងៃទាក់ទងនឹងសភាពគួរឲ្យរន្ធត់នៃអំពើប្រល័យពូជសាសន៍នៅកម្ពុជាយ៉ាងណាក៏ដោយ ក៏ខ្ញុំនៅតែមានការតក់ស្លុតចំពោះរឿងរ៉ាវដែលបានកើតឡើងតាំងពី៥០ឆ្នាំមុន ហើយបានកើតឡើងជាថ្មីម្តងទៀតនៅប្រទេសកម្ពុជាក្នុងជំនាន់ខ្ញុំ ។ រឿងរ៉ាវនិងការពិតដែលខ្ញុំបានជួបប្រទះបានជួយពង្រឹងការតាំងចិត្តរបស់ខ្ញុំថាយើងទាំងអស់គ្នាចាំបាច់ត្រូវតែអប់រំគ្នាទៅវិញទៅមកអំពីព្រឹត្តិការណ៍នៃប្រល័យពូជសាសន៍អំពីរបៀបទប់ស្កាត់មិនឲ្យមានអំពើនេះកើតមានឡើងម្តងទៀត និងអំពីការផ្តល់ចំណេះដឹងដល់សាធារណជនទូទៅ ។ ម្នាក់ៗចាំបាច់ត្រូវតែដឹងថាអំពើប្រល័យពូជសាសន៍គឺជារឿងរបស់មនុស្សជាតិទូទៅ គឺជារឿងរបស់យើងទាំងអស់គ្នា ។

មូលហេតុនេះហើយទើបយើងត្រូវរួបរួមទាំងអស់គ្នាក្នុងនាមជាមនុស្សជាតិដូចគ្នាក្នុងការទប់ស្កាត់អំពើឧក្រិដ្ឋកម្មដ៏សែនឃោរឃៅយង់ឃ្នង និងព្យាយាមទប់ស្កាត់អំពើនេះនៅគ្រប់ទីកន្លែងទាំងអស់ ។ ប្រជាជននៅទូទាំងពិភពលោកមានវប្បធម៌ និងភាសាផ្សេងៗពីគ្នា ប៉ុន្តែមានលក្ខណៈមួយដូចគ្នាគឺចង់រស់រានមានជីវិតនិងចង់ទំនុកបម្រុងក្រុមគ្រួសារប្រកបដោយសេចក្តីសុខសន្តិភាព ។ អំពើប្រល័យពូជសាសន៍បានបំផ្លាញខ្ទេចនូវក្តីសង្ឃឹមជាមូលដ្ឋាននេះ ។ ដូនកាលយើងត្រូវការពេលវេលាជាច្រើនជំនាន់ដើម្បី

ព្យាបាលនូវរបួសសង្គម ហើយជួនកាលចំពោះគ្រួសារខ្លះអំពើប្រល័យពូជសាសន៍បានបំផ្លាញនូវក្តីសង្ឃឹមរបស់គ្រួសារជារៀងរហូតដែលគ្មានថ្ងៃនឹងអាចស្តារឡើងវិញបានឡើយ ។

យើងត្រូវតែបញ្ចប់នូវឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ។ នៅថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០០០ លោកប្រធានាធិបតីនៃសាធារណរដ្ឋប្រជាមានិតចិន ហ្សាង ហ្ស៊ឺមីង កំពុងតែធ្វើទស្សនកិច្ចជាផ្លូវរដ្ឋនៅក្នុងព្រះរាជាណាចក្រកម្ពុជា ។





ប្រទេសចិនក៏មានចំណែកដែរចំពោះអ្វីដែលបានកើតឡើងនៅក្នុងរបបខ្មែរក្រហម ។ ដូច្នេះប្រទេសចិនក៏មានការទទួលខុសត្រូវនិងកាតព្វកិច្ចក្នុងការជួយប្រទេសកម្ពុជាឲ្យរួចផុតពីអតីតកាលដ៏ខ្មៅងងឹតនេះ ។ ឥឡូវនេះចិននិយាយថាខ្លួនចង់រក្សាអព្យាក្រិតភាពរវាងក្រុមបដិបក្ខផ្នែកនយោបាយនៅក្នុងប្រទេសកម្ពុជា ។ មធ្យោបាយដ៏ល្អបំផុតក្នុងការសម្រេចគោលដៅនេះគឺត្រូវតែគាំទ្រប្រជាជនកម្ពុជាជាជាងជួយគណៈបក្សនយោបាយណាមួយនោះ ។ រាល់ការស្ទាបស្ទង់មតិកន្លងមកចំពោះអំពើប្រល័យពូជសាសន៍នៅកម្ពុជាបង្ហាញថា ភាគច្រើនលើសលប់នៃប្រជាជនកម្ពុជាចង់បានតុលាការមួយដែលដំណើរការដោយមានការចូលរួមគាំទ្រពីសំណាក់អង្គការសហប្រជាជាតិ ។ ដូច្នេះខ្ញុំសូមអំពាវនាវដោយស្មោះស្ម័គ្រចំពោះមេដឹកនាំនៃសាធារណរដ្ឋប្រជាមានិតចិនឲ្យពិចារណាអំពីអនាគតនិងការអភិវឌ្ឍរបស់ប្រទេសកម្ពុជា ។ ប្រទេសចិនខ្លួនឯងកំពុងតែស្ថិតនៅក្នុងដំណើរការអនុវត្តវិធាននៃច្បាប់ ។ ចិនគួរតែដឹងថាមធ្យោបាយដ៏ល្អបំផុតក្នុងការជួយប្រទេសកម្ពុជាគឺត្រូវចាប់ផ្តើមដោយបញ្ចប់នូវភាពរួចទោសចំពោះរាល់អំពើរំលោភច្បាប់ផ្សេងៗ ។ ហើយបញ្ហានេះក៏ត្រូវតែចាប់ផ្តើមជាមួយនឹងខ្មែរក្រហមដែលធ្លាប់មានគំនិតចង់បង្កើតសង្គមបរិសុទ្ធឥតខ្ចោះមួយដោយលុបបំបាត់ច្បាប់ទាំងស្រុងរួចហើយបន្តរំលោភទៅលើច្បាប់នីមួយៗរបស់មនុស្សលោក និងព្រះជាម្ចាស់ ។

ជួនពេលជាមួយនឹងទស្សនកិច្ចរបស់ប្រធាធិបតីចិននៅប្រទេសកម្ពុជា នៅថ្ងៃបន្ទាប់លោកប្រធានាធិបតី ប៊ីល គ្លីនតុន និងលោកជំទាវដែលទើបនឹងជាប់ឆ្នោតជាសមាជិកព្រឹទ្ធសភានៃរដ្ឋញូវយ៉កនឹងចាប់ផ្តើមដំណើរទស្សនកិច្ចរបស់ខ្លួនទៅកាន់ប្រទេសវៀតណាមដែលជាប្រទេសជិតខាងរបស់កម្ពុជាក្នុងគោលបំណងធ្វើការផ្សះផ្សាជាមួយនឹងអតីតសត្រូវរបស់ខ្លួន ។ នេះគឺជាតួនាទីមួយដ៏សំខាន់របស់សហរដ្ឋអាមេរិកនៅលើពិភពលោកក្នុងគោលបំណងមិនត្រឹមតែថែរក្សាសន្តិភាពតែប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងបង្កើតសន្តិភាពទៀតផង ។ ក្នុងនាមជាប្រទេសមួយដែលខ្លាំង និងស្តុកស្តម្ភដែលមិនធ្លាប់មានពីមុនមក សហរដ្ឋអាមេរិកមានការទទួលខុសត្រូវដ៏ពិសេសដោយឡែកពីគេ ។ នេះមិនមែនមានន័យថា សហរដ្ឋអាមេរិកគឺជានគរបាលរបស់ពិភពលោកទាំងមូលអាចធ្វើការជ្រៀតជ្រែកចូលកិច្ចការផ្ទៃក្នុងរបស់ប្រទេសផ្សេងនោះទេ ហើយក៏មិនមែនមានន័យថា សហរដ្ឋអាមេរិកអាចទប់ស្កាត់កុំឲ្យកើតមានអំពើប្រល័យពូជសាសន៍នោះដែរ ។ ប៉ុន្តែវាមានន័យយ៉ាងដូច្នេះទៅវិញទេថានៅពេលដែលយើងមានឱកាសការពារទប់ស្កាត់អំពើប្រល័យពូជសាសន៍យើងគួរតែព្យាយាមប្រឹងប្រែងឲ្យអស់លទ្ធភាព ។ លោកប្រធានាធិបតី រ៉ូណាល់ រីហ្គែន ធ្វើឲ្យនឹកឃើញដល់ទស្សនៈនៃសហរដ្ឋអាមេរិកនៅពេលដែលលោកមានប្រសាសន៍ថាសហរដ្ឋអាមេរិកគឺជា “ទីក្រុងនៅលើទួល” ដែលជាប្រទីបនៃក្តីសង្ឃឹមចំពោះប្រជាជាតិទាំងអស់នៅលើពិភពលោក ។ ក្នុងន័យនេះខ្ញុំគិតថាយើងមានការទទួលខុសត្រូវចំពោះការដឹកនាំតាមរយៈឧទាហរណ៍ដែលយើងមានកន្លងមក ហើយគ្មានឧទាហរណ៍ណាមួយដែលល្អជាងការធ្វើការងារជាក់ស្តែងដើម្បីពន្លត់ភ្លើងដែល

គួរឲ្យស្អប់ខ្ពើមមុនពេលដែលវាឆេះសន្ធោសន្ធៅហើយនឹងឆាបយកជីវិតមនុស្សទាំងអស់នៅលើលោកយើងនេះ ។ អណ្តាតភ្លើងនេះបានកម្ទេចប្រទេសកម្ពុជាស្ទើរក្លាយទៅជាផេះ ។ អ្នកចងក្រងអនុសញ្ញាស្តីពីការទប់ស្កាត់និងដាក់ទណ្ឌកម្មចំពោះបទឧក្រិដ្ឋកម្មប្រល័យពូជសាសន៍មិនដែលប្រមើលនឹកដល់ទាល់តែសោះថាមេដឹកនាំប្រទេសមួយហ៊ានបំផ្លាញជាតិខ្លួនឯងនោះឡើយ ។ ប៉ុន្តែជាការពិតអំពើនេះត្រូវបានប្រព្រឹត្តឡើងដោយក្រុមខ្មែរក្រហម ។ ការសិក្សាស្រាវជ្រាវដែលធ្វើឡើងនៅមជ្ឈមណ្ឌលឯកសារកម្ពុជាបង្ហាញថាក្នុងចំណោមប្រជាជនសរុបប្រមាណប្រាំបីលាននាក់ មានប្រជាជនប្រហែលពីរលាននាក់ បានស្លាប់ក្នុងជំនាន់របបខ្មែរក្រហម ។ ក្នុងអំឡុងពេលមិនដល់ប្រាំឆ្នាំផង មជ្ឈមណ្ឌលឯកសារកម្ពុជាបានធ្វើកំណត់ឯកសារទៅលើរណ្តៅសាកសពរួមចំនួនជាងពីរម៉ឺនរណ្តៅនៅទូទាំងប្រទេសកម្ពុជា ដែលសុទ្ធតែផ្ទុកនូវអដ្ឋិធាតុរបស់ជនរងគ្រោះក្រោមស្នាដៃខ្មែរក្រហម ។ ទោះបីជាខ្មែរក្រហមនិយាយថាពួកខ្លួនធ្វើបដិវត្តន៍ដើម្បីប្រជាជនក្រីក្រដែលជាអ្នកស្រុកស្រែចម្ការយ៉ាងណាក៏ដោយ ប៉ុន្តែគួរឲ្យចម្លែកមែនទែន ចំពោះការពិតដែលថាប្រជាជនភាគច្រើនត្រូវបានខ្មែរក្រហមសម្លាប់គឺសុទ្ធតែអ្នកស្រុកស្រែចម្ការធម្មតាដែលប្រាថ្នាចង់ត្រឹមតែប្រកបមុខរបរកសិកម្មចិញ្ចឹមជីវិតក្នុងសុខសន្តិភាពតែប៉ុណ្ណោះ ។

ឥឡូវសង្គ្រាមនៅកម្ពុជាបានបញ្ចប់ហើយ ប៉ុន្តែសន្តិភាពមិនទាន់មានដល់កម្ពុជាដោយបរិបូរណ៍នៅឡើយទេ ។ សន្តិភាពតម្រូវឲ្យមានអ្វីដែលលើសពីអវត្តមាននៃសត្រូវនៅក្នុងសមរភូមិ ពោលគឺមិនមានន័យថា អស់សត្រូវគឺមានសន្តិភាពនោះទេ ។ សង្គមដែលមានសន្តិភាព គឺជាសង្គមដែលមានយុត្តិធម៌ហើយ ប្រជាជនកម្ពុជាមិនទាន់រកឃើញយុត្តិធម៌នៅឡើយទេ ។ សន្តិភាពមិនអាចកើតមាននៅក្នុងប្រទេសកម្ពុជាឡើយ ដរាបណាពុំមានយុត្តិធម៌ពិតប្រាកដចំពោះអំពើឧក្រិដ្ឋកម្មខ្មែរក្រហមទេនោះ ។ ប្រជាជនកម្ពុជានៅតែមានការភ័យខ្លាចនៅក្នុងចិត្តពីព្រោះនៅតែឃើញអ្នកដែលបានប្រព្រឹត្តអំពើប្រល័យពូជសាសន៍ប្រឆាំងនឹងខ្លួនកាលពីអតីតកាលកំពុងរស់នៅដើរហើរដោយសេរីនៅក្បែរៗខ្លួន ។ បើយើងខកខានមិនបានទប់ស្កាត់អំពើប្រល័យពូជសាសន៍ដូចជាករណីនៅកម្ពុជានេះ យើងត្រូវតែនាំជនដៃដល់មកជំនុំជម្រះទោសនៅមុខតុលាការឲ្យខាងតែបាន ។

កិច្ចការរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា គឺរួមមានការប្រមូលព័ត៌មានទាក់ទងនឹងអ្វីដែលខ្មែរក្រហមបានប្រព្រឹត្តនៅក្នុងអំពើប្រល័យពូជសាសន៍របស់ខ្លួននៅប្រទេសកម្ពុជាដើម្បីប្រវត្តិសាស្ត្រនិងយុត្តិធម៌ ។ យើងប្រមូលឯកសារសិក្សាអំពីរណ្តៅសាកសពរួមប្រមូលនូវពាល់សក្ខីកម្មពីជនរងគ្រោះព្រមទាំងព័ត៌មានផ្សេងៗទៀតដែលទាក់ទងនឹងឧក្រិដ្ឋកម្មសង្គ្រាមអំពើប្រល័យពូជសាសន៍និងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិផ្សេងៗទៀត ។ ជាការពិតណាស់ខ្មែរក្រហមមិនពេញចិត្តចំពោះកិច្ចការដែលមជ្ឈមណ្ឌលឯកសារកំពុងធ្វើនោះទេ ហើយមេដឹកនាំកំប៉ិកកំប៉ុកខ្មែរក្រហមខ្លះបានបន្ទយពាក្យថា យើងកំពុងធ្វើអាជីវកម្មលើរបបដ៏បរិសុទ្ធនៃពួកខ្មែរក្រហមទៀតផង ។ ខ្មែរក្រហមព្យាយាមធ្វើជាសញ្ញាឲ្យយើងដឹងបានថាបុគ្គលិកនៅមជ្ឈមណ្ឌលឯកសារកម្ពុជាគឺដូចជាប្រេតមកពីឋាននរកអវិចីង ។ ពេលរឿងនេះកើតឡើង ខ្ញុំតែងនឹកដល់សម្តីរបស់លោកប្រធានាធិបតីហារី ទ្រូមែន ដែលមានប្រសាសន៍ថា «ខ្ញុំមិនដែលដេរប្រមាថដាក់បណ្តាសារឲ្យអ្នកទាំងអស់នោះចុះនរកអវិចីឡើយ ប៉ុន្តែគ្រាន់តែនិយាយអ្វីដែលជាការពិតតែប៉ុណ្ណោះ ប៉ុន្តែអ្នកទាំងនោះតែងគិតថាការពិតគឺជាប្រេតនរកអវិចី» ។

សព្វថ្ងៃនេះខ្មែរក្រហមចូលចិត្តនិយាយថាឲ្យភ្លេចរឿងអតីតកាលចោលទៅ ។ ប៉ុន្តែពេលដែលខ្លួនកំពុងកាន់អំណាចខ្មែរក្រហមមិនបានចង់បំភ្លេចអតីតកាលឡើយ ។ ខ្មែរក្រហមបានចាំទុកជានិច្ចនូវអ្នកសល់ពីសង្គមចាស់ ហើយព្យាយាមសម្លាប់ប្រជាជនដែលជាមុខសញ្ញានោះចោលទាំងអស់ ។ ខ្មែរក្រហមចូលចិត្តនិយាយរឿង «បង្រួបបង្រួមជាតិ» ប៉ុន្តែកាលពីរបបដែលខ្លួនកាន់កាប់ខ្មែរក្រហមមិនដែលចង់សម្របសម្រួលផ្សះផ្សាជាមួយអ្នកណាម្នាក់ឡើយ គឺមានតែការគោរពបញ្ជា និងបើមិនគោរពបញ្ជាគឺត្រូវសម្លាប់ចោល ។ ខ្មែរក្រហមចូលចិត្តនិយាយពីរបៀបអភិវឌ្ឍសេដ្ឋកិច្ចជាតិជាអាទិភាព ។ ប៉ុន្តែមូលហេតុដែលនាំឲ្យសេដ្ឋកិច្ចជាតិមិនមានការរីកចម្រើនយ៉ាងនេះគឺដោយសារ



ជនរងគ្រោះប្រមាណ១មុឺន៥ពាន់នាក់នៅមន្ទីរស-២១ ត្រូវបានធ្វើទារុណកម្មបង្ខំឲ្យឆ្លើយសារភាព រួចហើយយកទៅសម្លាប់ចោល

កាលនោះខ្មែរក្រហមមិនបានកសាងសេដ្ឋកិច្ចទាល់តែសោះគឺមានតែការបំផ្លាញចោលទាំងស្រុងតែប៉ុណ្ណោះ ។ ខ្មែរក្រហមចូលចិត្តនិយាយអំពី «ស្ថិរភាព» និង «ថែរក្សាសន្តិភាព» គឺជាកិច្ចការមានសារៈសំខាន់បំផុត ។ ប៉ុន្តែអ្វីដែលខ្លួនកំពុងតែធ្វើគឺការគំរាមកំហែងថានឹងមកធ្វើសង្គ្រាមសាជាថ្មីក្នុងគោលបំណងសម្លុតបំភ័យប្រជាជនកុំឲ្យធ្វើការដើម្បីយុត្តិធម៌ដែលប្រជាជនកំពុងតែចង់បាននោះ ។ ដូច្នេះខ្ញុំគិតថា ខ្មែរក្រហមមិននិយាយដោយស្មោះត្រង់ មិននិយាយការពិតដែលចេញពីចិត្តពិតៗឡើយ ។ ផ្ទុយទៅវិញខ្មែរក្រហមស្តែងចេញជាពាក្យពីបបូរមាត់ដែលរៀបចំឡើងដើម្បីផលប្រយោជន៍ផ្ទាល់ខ្លួន ជាជាងដើម្បីផលប្រយោជន៍សង្គមជាតិកម្ពុជាទាំងមូល ។

ដើម្បីសន្តិភាព ការបង្រួបបង្រួមផ្សះផ្សាជាតិ ការអភិវឌ្ឍនិងស្ថិរភាពពិតប្រាកដកម្ពុជាត្រូវប្រឈមមុខនឹងការពិតនិងស្រវាយកយុត្តិធម៌ឲ្យទាល់តែបាន ។ ប្រការនេះអាចធ្វើទៅបានប្រសិនបើអ្នកដែលទទួលខុសត្រូវចំពោះអំពើប្រល័យពូជសាសន៍ត្រូវបាននាំមកកាន់តុលាការឯករាជ្យមួយ ដើម្បីធ្វើឲ្យមានការពន្យល់បំភ្លឺនិងការពារខ្លួនចំពោះអំពើដែលខ្លួនបានប្រព្រឹត្តនៅមុខប្រជាជនទូទៅ ។ ពេលនោះហើយទើបប្រជាជនកម្ពុជាអាចទុកអតីតកាលដ៏គួរឲ្យរន្ធត់របស់ខ្លួនឲ្យស្ថិតស្ថេរនៅមួយកន្លែងហើយចាប់ផ្តើមកសាងអនាគតថ្មីមួយទៀតបាន ។ របបប្រល័យពូជសាសន៍ខ្មែរក្រហមត្រូវបានផ្តួលរំលំដោយសង្គ្រាមគឺមិនមែនដោយសារច្បាប់នោះទេ ។ ដូច្នេះប្រទេសកម្ពុជាមិនទាន់អាចក្លាយជានីតិរដ្ឋបានឡើយ ប្រសិនបើគ្មានវិធាននៃច្បាប់ទេនោះ ប្រទេសកម្ពុជាក៏មិនអាចអភិវឌ្ឍខ្លួនឲ្យក្លាយទៅជាប្រទេសមួយដែលមានសន្តិភាពនិងភាពសម្បូរសប្បាយបានឡើយ ។

ហេតុផលនេះហើយ ទើបខ្ញុំនៅតែប្រកាន់ខ្ជាប់នូវការតាំងចិត្តចំពោះបុព្វហេតុនៃការស្វែងរកការពិត និងយុត្តិធម៌នៅក្នុងប្រទេសកម្ពុជា ។ នេះមិនមែនជាការសងសឹកទេ ប៉ុន្តែជាការពិត ។ វាមិនមែនជារឿងរ៉ាវអតីតកាល ប៉ុន្តែវាជារឿងបច្ចុប្បន្នកាល ។ សូមជួយខ្ញុំក្នុងការនាំយកជនដៃដល់ដែលបានប្រព្រឹត្តអំពើប្រល័យពូជសាសន៍ដ៏យង់ឃ្នងបំផុតនៅក្នុងប្រវត្តិសាស្ត្រមកកាន់កន្លែងសមរម្យរបស់ខ្លួនគឺមន្ទីរឃុំឃាំង ។ **ឆាំង យុ**

# សេចក្តីថ្លែងការណ៍រួមរវាងព្រះរាជាណាចក្រកម្ពុជានិងសាធារណរដ្ឋប្រជាមានិតចិន ស្តីអំពីក្របខ័ណ្ឌកិច្ចសហប្រតិបត្តិការទ្វេរភាគី

សេចក្តីថ្លែងការណ៍រួមដែលធ្វើឡើងរវាងព្រះរាជាណាចក្រកម្ពុជានិងសាធារណរដ្ឋប្រជាមានិតចិននៅទីក្រុងភ្នំពេញ នាថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ២០០០ មានសរុបទាំងអស់១២ចំណុច ។ សេចក្តីថ្លែងការណ៍រួមនេះផ្តោតសំខាន់ទៅលើចំណងមិត្តភាពរវាងប្រទេសទាំងពីរដែលមានជាយូរយារណាស់មកហើយ ។ ជាងនេះទៅទៀត សេចក្តីថ្លែងការណ៍នៅមានលើកឡើងអំពីកិច្ចសហប្រតិបត្តិការក្នុងវិស័យផ្សេងៗ ដូចជាវិស័យនយោបាយ សេដ្ឋកិច្ចសង្គម វប្បធម៌ និង វិស័យអប់រំជាដើម ។ ភាគីទាំងពីរបានយល់ព្រមក្នុងការពង្រីកកិច្ចសហប្រតិបត្តិការជាមួយស្ថាប័នរដ្ឋ សភាជាតិ គណបក្ស នយោបាយ កងកម្លាំងប្រដាប់អាវុធ និងអង្គការក្រៅរដ្ឋាភិបាលក្នុងគោលបំណងពង្រីកការទុកចិត្តគ្នាទៅវិញទៅមក ។ វិស័យទំនាក់ទំនងការទូតរវាងប្រទេសទាំងពីរក៏ត្រូវបានបញ្ជាក់ច្បាស់ទន្ទឹមនឹងការសន្យាបង្កើតនូវកិច្ចសហប្រតិបត្តិការជាមួយប្រជាជាតិអាស៊ី-អគ្នេយ៍ អាស៊ីខាងកើត និងអង្គការសហប្រជាជាតិ ។

ពេលនេះយើងខ្ញុំសូមដកស្រង់ជូននូវចំណុចសំខាន់ៗមួយចំនួនដូចខាងក្រោមនេះ ÷

ចាប់តាំងពីការបង្កើតឡើងនូវទំនាក់ទំនងការទូតរវាងព្រះរាជាណាចក្រកម្ពុជានិងសាធារណរដ្ឋប្រជាមានិតចិន (ហៅកាត់ថាភាគីទាំងពីរ) នៅថ្ងៃទី១៩ ខែកក្កដា ឆ្នាំ១៩៥៨មក ទំនាក់ទំនងមិត្តភាពចិន-កម្ពុជា ដែលរីតចំណងដោយមេដឹកនាំជាច្រើនជំនាន់និងព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា សម្តេចព្រះនរោត្តមសីហនុ កាន់តែកក់ក្តៅខ្លាំងឡើងៗ ហើយទំនាក់ទំនងទ្វេភាគីកាន់តែជិតដិតជាលំដាប់ ។ ការប្តូរគ្នាទៅវិញទៅមករវាងភាគីទាំងពីរក្នុងវិស័យនយោបាយ សេដ្ឋកិច្ច វប្បធម៌ អប់រំនិងវិស័យផ្សេងៗទៀតបានផ្សារភ្ជាប់ចំណងមិត្តភាពនិងសាមគ្គីភាពចិន-កម្ពុជាយ៉ាងស្អិតរមួត ។

ភាគីទាំងពីរបញ្ជាក់ថា គោលការណ៍ដែលបានចែងនៅក្នុងធម្មនុញ្ញរបស់អង្គការសហប្រជាជាតិ គោលការណ៍ទាំងប្រាំស្តីពីអត្ថិភាពសន្តិភាព គោលការណ៍ដែលបានចែងនៅក្នុងសន្និសញ្ញាស្តីអំពីសាមគ្គីភាពនិងកិច្ចសហប្រតិបត្តិការនៅក្នុងតំបន់អាស៊ីអគ្នេយ៍ និងគោលការណ៍ច្បាប់អន្តរជាតិដែលត្រូវបានទទួលស្គាល់ជាសកលគឺជាបទដ្ឋានគោលសម្រាប់ទំនាក់ទំនងទ្វេរភាគីរបស់ខ្លួន ។

ភាគីទាំងពីរបញ្ជាក់ជាថ្មីទៀតថា គ្រប់ប្រទេសទាំងអស់មានសិទ្ធិជ្រើសរើសប្រព័ន្ធនយោបាយនិងប្រព័ន្ធសេដ្ឋកិច្ចហើយទាមទារឲ្យមានការបង្កើតឡើងនូវសណ្តាប់ធ្នាប់យុត្តិធម៌និងស្មើភាពថ្មីមួយក្នុងផ្នែកនយោបាយនិងសេដ្ឋកិច្ចអន្តរជាតិដើម្បីធានាដល់សន្តិភាពនិងស្ថិរភាព ។

ធ្វើនៅភ្នំពេញ,ថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ២០០០

(សង្ខេបនិងប្រែសម្រួលក្រៅផ្លូវការដោយ សូ ប៊ុនស៊ូ)



# អ្នកសួរចម្លើយនៅមន្ទីរស-២១ត្រូវអង្គការចាប់ខ្លួន

***សកម្មភាពរបស់ វង់ សំអាត ចាប់ពីឆ្នាំ១៩៧០ មកដល់មុនរំដោះឆ្នាំ១៩៧៥***

វង់ សំអាត ហៅ វង់ អឿន អាយុ១៩ឆ្នាំ នៅ លីវ មុនពេលអង្គការចាប់ខ្លួនធ្វើជាយុទ្ធជនសួរចម្លើយនៅមន្ទីរស-២១ (គុកទួលស្លែង) មានស្រុកកំណើតនៅភូមិស្តុកត្រនិច ឃុំត្រាវពន្លក ស្រុក១៨(ទឹកផុស) ខេត្តកំពង់ឆ្នាំង តំបន់៣១ភូមិភាគបស្ចិម ។ នៅឆ្នាំ១៩៧០ វង់ អឿន បានចូលធ្វើកិញ្ចឲ្យឈ្មោះ ឈុំ (មេវត្តទឹកជុំ) តាមការអប់រំរបស់ ឈុំ ដែលបានលើកឡើងថា «អឿន ឯងចង់បួសយ៉ាងម៉េចកើត បើឪពុកម្តាយ អឿន ឯងក្រយ៉ាងនេះ ។ ដូច្នេះបើចង់បួសបានឆាប់ៗត្រូវធ្វើតាមខ្ញុំមកទើបបានបួស» ។ បន្ទាប់មក ឈុំ បានបន្តទៀតថា «ឥឡូវប្រទេសយើងកើតខ្មែរក្រហមច្រើនណាស់ បើកើតពួកខ្មែរក្រហមនេះ បន្តិចទៀតប្រទេសយើងគ្មានបុណ្យទានអ្វីទាំងអស់ ពីព្រោះខ្មែរក្រហមនេះវាគ្មានសាសនាអ្វីទេ បើ អឿន ឯងធ្វើការឲ្យអញបានល្អៗអញនឹងបំបួស អឿន ឯង ។ មិនតែប៉ុណ្ណោះទៅថ្ងៃមុខអញនឹងឲ្យឯងពាក់សក្តិទៀត» ។ ដោយសារតែការអប់រំនេះធ្វើឲ្យ វង់ អឿន សុខចិត្តធ្វើការឲ្យ ឈុំ ។ ភារកិច្ចដែល វង់ អឿន ត្រូវធ្វើគឺ ១) ដើរយកការណ៍ពីពួកខ្មែរក្រហម ២) ក្តាប់មនុស្សណាដែលអាចកសាងកម្លាំងបាន ៣) កសាងកម្លាំងកិញ្ចឲ្យបានច្រើន ។ ពេលនោះ វង់ អឿន ត្រូវបាន ឈុំ ឲ្យទាក់ទងធ្វើសកម្មភាពជាមួយ ណេន (យុទ្ធជន) , ជុំ (ជាសង្ឃ) និងសុស (មេភូមិចាស់) ។

ក្រោយមក ជុំ បានឲ្យ វង់ អឿន ទាក់ទងស្គាល់គ្នាជាមួយ ឈួន (ជាសង្ឃ) រីឯ សុស បានឲ្យ វង់ អឿន និង ណេន ទៅទាក់ទងជាមួយ ហេង (ថៅកែម៉ាស៊ីនស្រូវ) ដើម្បីធ្វើសកម្មភាពប្រឆាំងបដិវត្តន៍ ។ សុស បាននិយាយប្រាប់ វង់ អឿន ថា «អឿន ឯងបើខ្ញុំមិននៅមានការអីទាក់ទងជាមួយ ហេង ចុះ» ។ បន្ទាប់ពីទាក់ទងជាមួយ ហេង រួចមក វង់ អឿន ត្រូវបាន ហេង ណែនាំឲ្យស្គាល់និងទាក់ទងជាមួយឈ្មោះ នី និងឈ្មោះ ណេន ដើម្បីធ្វើសកម្មភាពបំផ្លាញកម្លាំងបដិវត្តន៍នៅពេលណាដែលបានតាមដានឃើញកន្លែងរបស់ពួកខ្មែរក្រហម ។

នៅដើមឆ្នាំ១៩៧១ ទាហានបានវាយឡើងពីបន្ទាយរមាសចូលមកក្នុងភូមិខ្សែខ្ញុំ ឃុំចោងមោង ។ ពេលនោះដោយខ្លាចទាហានចាប់ឲ្យធ្វើទាហាន ឪពុកម្តាយរបស់ វង់ អឿន បាននាំកូនរត់ទៅនៅភូមិស្តុកទ្រនិច ឃុំត្រាវពន្លក ស្រុក១៨ តំបន់៣១ ។ ក្រោយពីរត់ចេញទៅ វង់ អឿន បានដាច់ខ្សែរយៈទាក់ទងចាស់ ហើយក៏មិនបានធ្វើសកម្មភាពក្បត់នឹងបដិវត្តន៍ដែរ ។

លុះមកដល់ពាក់កណ្តាលឆ្នាំ១៩៧២ ទើប វង់ អឿនបានជួបជាមួយ សុស ម្តងទៀត ហើយ សុស បានណែនាំ វង់ អឿន ឲ្យបន្តធ្វើសកម្មភាពក្បត់ទៀត ដោយបានដាក់ផែនការឲ្យធ្វើដូចជា ១) បំផ្លាញសម្ភាររបស់អង្គការ ២) កសាងកម្លាំងក្នុងជួរបដិវត្តន៍ឲ្យបានច្រើន ដើម្បីដណ្តើមយករដ្ឋអំណាចពីបដិវត្តន៍ទៅថ្ងៃមុខ ៣) ស្រាវជ្រាវរកខ្សែទាក់ទងចាស់ ។ រួច សុស បានឲ្យ វង់ អឿន ទៅទាក់ទងជាមួយឈ្មោះ គៀត (មេឃុំចាស់) ដើម្បីធ្វើសកម្មភាព ។

នៅឆ្នាំ១៩៧៣ វង់ អឿន ត្រូវបានឈ្មោះ កង អប់រំឲ្យស្អប់បដិវត្តន៍ និងឲ្យទាក់ទងជាមួយឈ្មោះ យៀប (ឈ្លបឃុំ) ធ្វើសកម្មភាពបំផ្លាញបដិវត្តន៍ ។ នៅពាក់កណ្តាលឆ្នាំ១៩៧៣ វង់ អឿន និង យៀប ត្រូវបានអង្គការចាត់ឲ្យទៅសមរភូមិមុខ ហើយបានបំផ្លាញគ្រាប់រំសេវរបស់បដិវត្តន៍អស់មួយចំនួន ។ នៅចុងឆ្នាំ១៩៧៣ យៀប បានខ្ទេសនាមឲ្យ វង់ អឿន ទាក់ទងជាមួយឈ្មោះ ហ៊ិន និងឈ្មោះ រស់ ។ ក្រោយពីទាក់ទងគ្នាជាប់ហើយ យៀប បានហៅ វង់ អឿន ណេន និង រស់ មកប្រជុំធ្វើសកម្មភាពបំផ្លាញបដិវត្តន៍ ។ ពេលនោះ វង់ អឿន និង យៀប ត្រូវបានអង្គការដកមកនៅសមរភូមិក្រោយវិញ ។ នៅខែតុលា ឆ្នាំ១៩៧៣ អង្គការបានបញ្ជូនទ័ពទៅសមរភូមិមុខបន្ថែម វង់ អឿន ក៏បានជួបជាមួយ ណេន ដែលជាខ្សែចាស់តាំងពីឆ្នាំ១៩៧០វិញ ។

នៅឆ្នាំ១៩៧៤ យៀប បានឲ្យបក្ខពួករបស់ វង់ អឿន


ប្រវត្តិរូប


យុទ្ធជនមន្ទីរស-២១

ស្គាល់ខ្សែរយៈរបស់ យូ (ឈ្លប) ។ យូ ក៏ណែនាំ វង់ អឿន ស្គាល់ពីកម្លាំងម្នាក់ទៀតគឺ ទិត (យុទ្ធជនឈ្លប) ។ ក្រោយពីបានដឹងថា ទិត ជាខ្សែទាក់ទងគ្នារួចមក វង់ អឿន និង ហ៊ិន បានទាក់ទងគ្នាធ្វើសកម្មភាពនៅតាមខ្សែត្រៀមពេលដែលមានទាហានខ្លាំងវាយបុក ដោយនាំទ័ពរត់ចោលខ្សែត្រៀមស្របតាមផែនការដែល ហ៊ិន បានលើកឡើងថា “ឥឡូវនេះ ពេលទាហានឡើងមកយើងកុំបាញ់អី ទុកឲ្យទាហានធ្វើបាបប្រជាជន ដើម្បីឲ្យប្រជាជនអស់ជំនឿទៅលើអង្គការបដិវត្តន៍” ។ នៅចុងឆ្នាំ១៩៧៤ អង្គការបានរៀបចំឈ្លបគ្រប់ឃុំទាំងអស់ និងកងធំលេខ២១៨ ដើម្បីបញ្ចូលទៅជាកងទ័ពស្រុក១៨ ។ ពេលនោះ វង់ អឿន មានជម្ងឺគ្រុនញាក់មកសម្រាកនៅពេទ្យស្រុក១៨ ។ នៅពេលព្យាបាលជម្ងឺនៅទីនោះ វង់ អឿន ខូចសីលធម៌ជាមួយនារី វៀន (ជាយុទ្ធនារីពេទ្យស្រុក១៨) និងបានបំផុសអ្នកជំងឺដែលដេកនៅពេទ្យនោះថា “ដេកពេទ្យស្រុកមិនដឹងឆ្នាំណាជាទេ បើឲ្យថ្នាំលេបសុទ្ធតែថ្នាំអាចម៍ទន្សាយ” ធ្វើឲ្យអ្នកជំងឺមានទំនាស់ជាមួយពេទ្យជាបន្តបន្ទាប់ ។

### សកម្មភាពរបស់ វង់ សំអាត ក្រោយរំដោះឆ្នាំ១៩៧៥ រហូតដល់ពេលអង្គការចាប់ខ្លួននៅដើមឆ្នាំ១៩៧៨

ពេលដែល វង់ អឿន បានចេញពីពេទ្យវិញ យៀប និង យូ បានខ្ទេសនាមឲ្យស្គាល់ សារឹម (អនុលេខាវរសេនាតូចលេខ២១៤ប្រចាំស្រុក១៨) ។ ក្រោយថ្ងៃរំដោះ ១៧ មេសា ឆ្នាំ១៩៧៥ វង់ អឿន ត្រូវបានដកមកចូលទ័ពនៅស្រុក១៨បាន ទាក់ទងជាប់ជាមួយ សារឹម ។ សារឹម បានអប់រំថា “ឥឡូវនេះរំដោះទូទាំងប្រទេសហើយក៏យើងមិនបានសប្បាយដែរ ។ ដូច្នេះបើចង់សប្បាយដូចអឿនឯងទៅថ្ងៃមុខ អឿន ឯងមិនបានសប្បាយទេ ដូចអឿនឯងឃើញស្រាប់ហើយ ធ្វើបដិវត្តន៍មួយឆ្នាំលំបាកបន្តិចៗ ឥឡូវ អឿន ឯងមិនបានស្លៀកពាក់ខោអាវល្អៗទេ ចាំមើលបន្តិចទៀតគេ (អង្គការ) ប្រមូលយកទៅដាក់រួមទាំងអស់ហើយ គេបើកអង្ករឲ្យស៊ីល្ងាចមួយកំប៉ុង ព្រឹកមួយកំប៉ុង ។ ដូច្នេះរបបនេះវេទនាណាស់មិនដូចយើងរស់នៅជាឯកជនទេ” ។

ក្រោយមក វង់ អឿន ត្រូវបាន សារឹម ណែនាំឲ្យស្គាល់កម្លាំងមួយចំនួនទៀតដូចជា ឆួយ យ៉ាន ចេង និងគ្រី ឲ្យស្រាវជ្រាវរកខ្សែរយៈនិងធ្វើសកម្មភាពបំផ្លាញបដិវត្តន៍ ។ ពេលអង្គការដកបក្ខពួករបស់ វង់ អឿន យកមកភ្នំពេញ សារឹម បានខ្ទេសនាមឲ្យទាក់ទងជាមួយ សោម (កងការពារ) ខុម (អ្នកសួរ) ថេត ថុន វ៉ាន់ និង អឿន (យុទ្ធជនការពារ) ដោយបានណែនាំថា “បើសិនអង្គការចាប់ពួកក្បត់មកពីតំបន់៣១ (កំពង់ឆ្នាំង) ត្រូវដោះលែង ហើយបើអង្គការចាប់ខ្លួនបានកុំឆ្លើយដាក់គ្នា” ។ ពេលមកដល់ភ្នំពេញ បក្ខពួករបស់ វង់ អឿន បាននាំគ្នាចាប់កុមារចងវាយបង្អត់បាយ និងធ្វើសកម្មភាពបំពុលជ្រូកដើម្បីបំផ្លាញបដិវត្តន៍ ។ នៅក្នុងឆ្នាំ១៩៧៥នេះដែរ អង្គការបានដកបក្ខពួករបស់ វង់ អឿន ទាំងអស់ឲ្យមករៀនបច្ចេកទេសនៅកងពលលេខ៧០៣ ។ បន្ទាប់ពីរៀនបច្ចេកទេសរួចកម្លាំងរបស់ វង់ អឿន បានដាច់ខ្សែរយៈទាក់ទងជាមួយ ឆួយ ចេង និងធូក ក្រៅពីនេះនៅជាប់ទាក់ទងគ្នាដដែល ។ បន្ទាប់មក វង់ អឿន ថេត និង យ៉ាន ត្រូវបានអង្គការចាត់តាំងឲ្យធ្វើជាកងហ (កម្លាំងដែលមានចំនួន៥០នាក់) ធ្វើសកម្មភាពជាមួយ កុសល បង្អត់អាហារកុមារដែល កុសល ជាអ្នកដាក់ផែនការដើម្បីបំផ្លាញកម្លាំងបដិវត្តន៍ ។

នៅខែមករា ឆ្នាំ១៩៧៦ វង់ អឿន បានដាក់ផែនការឲ្យ ខុម និង ថុន បំផុសឲ្យកុមារជុះអាចម៍ដាក់កន្លែងសេដ្ឋកិច្ច និងធ្វើសកម្មភាពសេរី ។ នៅខែកុម្ភៈ ឆ្នាំ១៩៧៦ វង់ អឿន និងបក្ខពួកបានទទួលផែនការពី កុសល ឲ្យបង្អត់អាហារ ចំពោះកុមារនិងបាញ់ថ្នាំពុលដាក់ផ្លែឈើដើម្បីបំពុលកុមារពេលដែលកុមារឃ្លាន ហើយលួចបេះផ្លែឈើនោះស៊ីនិងចាប់កុមារចងបង្អត់បាយបណ្តាលឲ្យស្លាប់អស់ចំនួន២នាក់ ។ នៅខែមីនា ឆ្នាំ១៩៧៦ អង្គការបានដក វង់ អឿន និងបក្ខពួកនៅសាលាបច្ចេកទេសឲ្យមកនៅមន្ទីស-២១ ។ ពេលនោះ វង់ អឿន និងបក្ខពួកមួយចំនួនដែលនៅក្នុងកងជាមួយគ្នាបានពិភាក្សាគ្នាលើកផែនការដូចតទៅៈ ១) ត្រូវបង្កប់ខ្លួនសិន ២) ចាប់កងទ័ពមិនក្បត់ដាក់គុក ៣) ផែនការយាមដេកនិងធ្វើពុតជាឈឺ ។

ក្នុងឆ្នាំ១៩៧៦នេះដដែល អង្គការបានចាត់តាំង វង់ អឿន ចេង និង ហូ ឲ្យទៅបង្កប់ជាមួយកងពល៥០២ ដើម្បីតាមដានកម្លាំងក្បត់នៅទីនោះ ។ ប៉ុន្តែពួកនេះបានលាក់បាំងសកម្មភាពក្បត់មិនព្រមរាយការណ៍ជូនអង្គការ ។ នៅចុងឆ្នាំ១៩៧៦

អង្គការបានដកមកនៅភ្នំពេញ(មន្ទីរស-២១)វិញ ។ ពេលនោះ វង់ អឿន ថេត ចេង និង អឿន ដែលនៅក្រុមជាមួយគ្នាបានដើរធ្វើសកម្មភាពគប់ដុំដី ហើយស្រែកថាមានមនុស្សលួចចូល ដែលសកម្មភាពនេះបានអនុវត្តរហូតមក ។

នៅខែកុម្ភៈ ឆ្នាំ១៩៧៧ អង្គការបានចាត់តាំងឲ្យ វង់ អឿន មកនៅក្នុងក្រុមសួរចម្លើយ ។ ប៉ុន្តែមុននឹងមក វង់ អឿន ត្រូវបាន ហូ ណែនាំឲ្យបំផ្លាញកម្លាំងបដិវត្តន៍តាមចម្លើយរបស់ខ្មាំង ។ ក្រោយពីទទួលបានការណែនាំហើយ វង់ អឿន បានសួរចម្លើយខ្មាំងឲ្យឆ្លើយដាក់កម្លាំងរបស់បដិវត្តន៍ ។ បន្ទាប់មកទៀតអង្គការបានចាត់តាំង វង់ អឿន ឲ្យមកនៅក្រុមឯកសារ ។ វង់ អឿន បានទាក់ទងជិតស្និទ្ធជាមួយឈ្មោះ កាក់ (មេពួក) ដោយនិយាយពីប្រវត្តិប្រាប់គ្នាទៅវិញទៅមក និងនាំគ្នាធ្វើសកម្មភាពក្បត់បដិវត្តន៍ធ្វើឲ្យកងការពារមានទំនាស់ជាមួយគ្នា មិនពិនិត្យឯកសារ និងបន្ថយម៉ោងការងារស្លូលដើម្បីសួរនារីខ្មាំងពីរឿងសីលធម៌ ។ មកដល់ខែកញ្ញា ឆ្នាំ១៩៧៧ វង់ អឿន បានធ្វើទារុណកម្មលើខ្មាំងដោយវៃធ្វើបាបឲ្យស្រែកឮពីបន្ទប់មួយទៅបន្ទប់មួយ ធ្វើឲ្យខ្មាំងវិលមុខមិនដឹងក្បាលកន្ទុយអ្វីទាំងអស់ ។ ម្យ៉ាងទៀតបានធ្វើឲ្យឯកសារច្របូកច្របល់ជាច្រើន និងធ្វើឲ្យបាត់ឯកសារដោយចោទថាកងការពារលួចឯកសារសន្តិបាលដើម្បីឲ្យអង្គការចាប់កងការពារដាក់គុក ។ មិនតែប៉ុណ្ណោះ វង់ អឿន បានធ្វើសកម្មភាពអសីលធម៌ចំពោះនារីខ្មាំងដូចជាសម្រាតឲ្យដើរ និងយកឈើរុកប្រដាប់ភេទជាដើម ។

នៅឆ្នាំ១៩៧៨ វង់ អឿន បានធ្វើសកម្មភាពចាក់រុកឲ្យមានទំនាស់នៅក្នុងអង្គភាព និងមិនស្តាប់តាមការណែនាំរបស់អង្គការឲ្យធ្វើឯកសារឲ្យច្បាស់លាស់និងហ្មត់ចត់ ។ ប៉ុន្តែ វង់ អឿន ធ្វើជាមិនយកចិត្តទុកដាក់ចំពោះឯកសារ គិតតែពីរឿងធ្វើឲ្យស្មុគស្មាញដល់អង្គការរហូតដល់ខែកុម្ភៈ ឆ្នាំ១៩៧៨ ត្រូវអង្គការចាប់ខ្លួន ។

ផ្អែកតាមការសង្ខេបចម្លើយសារភាពខាងលើចេញពីឯកសារលេខ J០០៨៥៤អាចកត់សម្គាល់បានថា ឯកសារនេះធ្វើចប់នៅថ្ងៃទី៧ ខែមីនា ឆ្នាំ១៩៧៨ ក្រោមការសួរចម្លើយរបស់សមមិត្ត ទិត ដែលឆ្លើយសារភាពនិងសរសេរដោយផ្ទាល់ដៃរបស់ វង់ អឿន ចំនួន៣៧ទំព័រ ។ ក្នុងនោះមានបញ្ជីរាយនាមជនក្បត់ក្នុងប្រវត្តិចំនួន៣២នាក់ ។ ចំពោះជនក្បត់ទាំង៣២នាក់នោះមានសរសេរថាចាប់ខ្លួនចំនួន៩នាក់ ។ ចំណុចសំខាន់នៃឯកសារមានស្នាមផ្តិតមេដៃរបស់សាមីជនសារភាពនិងចំណារអ្នកទទួលខុសត្រូវគឺសមមិត្ត ឌុច បានចារបញ្ជូនទៅថ្នាក់លើដោយដាក់ថា "បងជាទីគោរព, អានេះក៏ធ្វើសកម្មភាពក្បត់នៅក្នុងស-២១ ពួកសួរ ។ វាឆ្លើយសកម្មភាពតែក្នុងវង្សពួកសួរគ្នាវាទេ និងពួកការពារគឺក្នុងស-២១ ។ មិនដូចអាពីរនាក់មុននោះទេ ។ ដោយគោរព, ឌុច, ២៦-៣-៧៨" ។ ចំពោះចំណារមួយទៀតរបស់ថ្នាក់លើបានសរសេរថា "ទ.ទ (ទទួល) ២៦-៣-៧៨" ។

ចម្លើយសារភាពនេះត្រូវបានសង្ខេបសារឡើងវិញចំនួន៥ទំព័រដោយសមមិត្ត ទិត ចុះហត្ថលេខាទទួលស្គាល់នៅថ្ងៃទី៨ ខែមីនា ឆ្នាំ១៩៧៨ ។ សេចក្តីសន្និដ្ឋាននៃសេចក្តីសង្ខេបនោះសរសេរដាក់ថា "តាមការពិនិត្យរបស់ខ្ញុំលើចម្លើយ វង់ អឿន ឃើញច្បាស់តាំងពី១៩៧០មកជាខ្មែរចង្វាក់ ហើយរហូតបច្ចុប្បន្នវាក៏សកម្មខ្លាំង ពិសេសកាល(១៩)៧៥ នៅបច្ចេកទេស៧០៣ ក្រៅពីកម្លាំងចាប់ហើយ វានិយាយពីការទាក់ទងជាមួយ វ៉ាន, សោម (ការពារ) ក៏ឃើញច្បាស់ដែរក្នុងការធ្វើសកម្មភាពក្រោមការដឹកនាំរបស់ កុសល ហើយសកម្មភាពនិងផែនការមិនប្លែកពីចម្លើយរបស់ វ៉ុន និង ផុន ទេ ។ រហូតមានសកម្មភាពបំពុលកុមារតាមផ្លែឈើ ។ តែចំពោះមនុស្ស ដែលនៅក្នុងចម្លើយនេះខ្ញុំមិនហ៊ានសន្និដ្ឋានថាយ៉ាងម៉េចទេ គ្រាន់តែពិនិត្យឃើញថាវានិយាយច្បាស់ជាខ្មែរសង្វាក់ ដូច្នេះសម្រេចលើបក្សពិនិត្យតាមសកម្មភាពជាក់ស្តែង ។ គោរពជូនអង្គការ" ។ **ឡុង សុភារិទ្ធ**

## ទ្រឹស្តីខ្មែរក្រហម

◆ **ប្រជាជននិងប្រជាជាតិ ដែលទទួលការជិះជាន់ មិនត្រូវយកការអស់សង្ឃឹមរបស់ខ្លួន ផ្ញើសង្ឃឹមទៅលើការយល់ធម៌របស់ចក្រពត្តិនិងបរិវារជាច់ខាត ទើបទទួលជ័យជម្នះ។**

(ដកស្រង់ចេញពីសៀវភៅក្រហម ទំព័រទី៦០)

# រណ្តៅសាកសពប្រល័យពូជសាសន៍នៅខេត្តបាត់ដំបង

**ស្រុកឯកភ្នំៈ**

**១) វត្តសំរោងៈ** ជាទីតាំងមន្ទីរសន្តិសុខ គុក ជាទីតាំងសម្លាប់ និងជាកន្លែងតម្កល់អដ្ឋិធាតុជនរងគ្រោះកម្ពុជាក្រោមរបបកម្ពុជាប្រជាធិបតេយ្យ ។ ទីតាំងនេះស្ថិតនៅក្នុងភូមិសំរោង ឃុំសំរោងក្នុងស្រុកឯកភ្នំ ខេត្តបាត់ដំបង ដែលមានចម្ងាយ៥គីឡូម៉ែត្រពីទីរួមខេត្ត តាមបណ្តោយស្ទឹងសង្កែ ។ តាមប្រព័ន្ធកំណត់ទីតាំងភូមិសាស្ត្រពិភពលោក បង្ហាញថាទីតាំងនេះស្ថិតនៅក្នុងចំណុចខ្សែស្រប ១៣°០៧'៤៤២៧" និងខ្សែបណ្តោយ ១០៣°៣១'០៥៨៧" ។ ទិន្នន័យចំណុចទីតាំងភូមិសាស្ត្រនេះត្រូវបានថតទុកក្នុងឧបករណ៍អេឡិចត្រូនិកដោយលេខកូដ ២០៥០១/២/៣ និងលេខឯកសារ R០៥០២០៨A ។

លោក ឆន សុវត្ថិ អាយុ៥៧ឆ្នាំបានប្រាប់ថា កាលសម័យឆ្នាំ១៩៧០-៧៥ គាត់បានបួសជាសង្ឃ ហើយពីឆ្នាំ១៩៧៥-៧៦ គាត់ត្រូវបានពួកខ្មែរក្រហមបង្ខំឲ្យសឹកដោយភ្ជង់នឹងចំពុះទុង ។ ពួកខ្មែរក្រហមបានយកកុដិព្រះសង្ឃធ្វើជាមន្ទីរសន្តិសុខពួកឈ្លបយកសាលាឆាន់ធ្វើជាគុក យកអគារវិបស្សនាធ្វើជាកន្លែងសួរចម្លើយ ។ កន្លែងសម្លាប់ស្ថិតនៅក្បែរអគារវិបស្សនា ។ ពេលដែលសួរចម្លើយរួចត្រូវយកទៅសម្លាប់ចោលដាក់ក្នុងរណ្តៅ (ដែលនៅមានស្នាមមិនទាន់រលុបនៅឡើយ) ។

លោក ឆន សុវត្ថិ ជាសាក្សីដ៏សំខាន់ម្នាក់ដែលបានដឹងថាឆ្នាំ១៩៧៥ ពួកខ្មែរក្រហមបានប្រមូលព្រះសង្ឃពីគ្រប់វត្តនិងពីមជ្ឈដ្ឋាននានាមកដាក់ទីវត្តនោះប្រហែលជាចំនួន



បូជនីយដ្ឋានវត្តសំរោង

៣០០អង្គ ។ នៅឆ្នាំ១៩៧៦ ពួកខ្មែរក្រហមបានបង្ខំឲ្យព្រះសង្ឃទៅធ្វើស្រែដោយពុំឲ្យចូលវត្តទៀតឡើយ ហើយចាប់ពីពេលនោះមកខ្មែរក្រហមបានយកវត្តធ្វើជាគុកសន្តិសុខ និងជាកន្លែងសម្លាប់រហូតដល់ឆ្នាំ១៩៧៩ ។ ប្រភេទជនរងគ្រោះនៅទីនោះរួមមានពួកមន្ត្រីរាជការ ជនស៊ីវិល ទាហាន ប៉ូលិស ប៉េអឹម សាស្ត្រាចារ្យ ប្រជាជនទាំងគ្រួសារ និងខ្លះទៀតត្រូវបានខ្មែរក្រហមចម្រាញ់យកអ្នកដែលជាប់និន្នាការ ឬបងប្អូនជាទាហាន ។

គាត់បានបញ្ជាក់ថានៅឆ្នាំ១៩៧៩ គាត់មករៀបចំវត្តសំរោងនេះមុនគេ ។ ពេលនោះឃើញសាកសពក្នុងគុកប្រឡាក់ដោយឈាមនិងមានខ្នោះជើងនៅសេសសល់នៅឡើយ ប៉ុន្តែក្រោយមកបាត់បង់អស់ហើយនៅសេសសល់តិចតួចប៉ុណ្ណោះ ។ នៅឆ្នាំ១៩៨០ គាត់បានគាស់យកអដ្ឋិធាតុហើយបានឃើញលលាដ៍ក្បាលក្នុង១រណ្តៅពី៤០ទៅ៦០នាក់ ។ បរិវេណសម្លាប់មានទំហំដីមួយរ៉ៃ(៤០ម៉ែត្របួនជ្រុង) ។ រណ្តៅមានពាសពេញទាំងអស់មិនទាន់លុបទេ ដែលមានចំនួនពី៩០ទៅ១០០រណ្តៅ និងអណ្តូងទឹកមួយនៅខាងមុខវត្ត ។ បើគិតតាមឯកសារដែលគាត់បានឃើញនៅឆ្នាំ១៩៧៩ ជនរងគ្រោះមានចំនួន១០០៨នាក់ ប៉ុន្តែគាត់មិនបានរក្សាឯកសារនោះទុកឡើយ ។

លោក ញឹម វ៉ាន់ អាយុ៦៩ឆ្នាំ បាននិយាយថា ទីនោះមានជនរងគ្រោះទាំងក្មេងចាស់ ប្រុសស្រីចម្រុះគ្នាដែលត្រូវបានខ្មែរក្រហមដឹកយកមកពីគ្រប់មជ្ឈដ្ឋានយកទៅដាក់ទីនោះរួចសម្លាប់ចោលទាំងអស់គ្មានសល់ទេ ។ ការសម្លាប់ធ្វើឡើងដោយព្រៃផ្សៃបំផុត ។ ក្រោយពេលសម្លាប់រួចខ្មែរក្រហមបានយកសាកសពទៅចង់ផ្អែកគល់អំពិលដោយដាក់បារីឲ្យបៀមជាប់នឹងមាត់ ។

***២) វត្តឯកភ្នំ:*** ជាមន្ទីរសន្តិសុខ គុក និងជាទីតាំងសម្លាប់ជនរងគ្រោះក្រោមរបបកម្ពុជាប្រជាធិបតេយ្យ ។ ទីតាំងនេះស្ថិតនៅក្នុងភូមិតាគម ឃុំពាមឯក ស្រុកឯកភ្នំ ខេត្តបាត់ដំបង ដែលមានចម្ងាយ៥គីឡូម៉ែត្រពីសាលាស្រុក ។ទីតាំងនេះស្ថិតនៅក្នុងចំណុចខ្សែស្រប ១៣° ០៩៤' ៤៨២" និងខ្សែបណ្តោយ ១០៣° ១១' ២២៣៩" ។ ទិន្នន័យចំណុចទីតាំងភូមិសាស្ត្រនេះត្រូវបានថតទុកក្នុងឧបករណ៍អេឡិចត្រូនិក ដោយលេខកូដ ២០៥០៤ និងលេខឯកសារ R០៥០២០៥A ។ នៅទីតាំងសម្លាប់នាវត្តឯកភ្នំនេះមានប្រហែល២០០រណ្តៅសាកសព ។

លោក យុត ផ្លូន អាយុ៧៣ឆ្នាំ កាលពីជំនាន់ប៉ុលពត គាត់រស់នៅភូមិតាគម ឃុំពាមឯក ស្រុកឯកភ្នំ ខេត្តបាត់ដំបង ។ គាត់បានដឹងថាវត្តឯកភ្នំនេះកាលជំនាន់ប៉ុលពត ពួកខ្មែរក្រហមបានយកធ្វើជាមន្ទីរសន្តិសុខ គុក និងកន្លែងសម្លាប់នៅមុខវត្តចម្ងាយប្រហែល៣០០ម៉ែត្រ ។ នៅចម្ការក្រូចមានទំហំដី១ហិកតាបួនជ្រុងដែលមានពោរពេញដោយរណ្តៅធ្វើឲ្យដើមក្រូចងាប់ដោយសារជាតិប្រៃខ្មោចច្រើនក្នុងចម្ការនេះ ។ ប្រភេទជនរងគ្រោះដែលត្រូវសម្លាប់នៅទីនោះ គឺអ្នកជម្លៀសចេញពីទីក្រុងក្នុងឆ្នាំ១៩៧៥-៧៦ និងអ្នកខុសសីលធម៌ ដូចជាដើរលួចស៊ីជាដើម ។ ក្រោយពីនេះយកប្រជាជនពីតំបន់៤មកដាក់ទីនេះរួចបាននាំយកទៅសម្លាប់ចោល ។ ខ្មែរក្រហមបានយកព្រះវិហារវត្តនិងសាលាឆាន់ធ្វើជាគុក រីឯកន្លែងដែលខ្មែរក្រហមរស់នៅគឺនៅភ្នំថ្មខាងក្រោយព្រះវិហារ ។ មន្ទីរសន្តិសុខ គុក និងកន្លែងសម្លាប់ត្រូវបានបង្កើតឡើងតាំងពីឆ្នាំ១៩៧៥-៧៨ ហើយបានកាប់សម្លាប់មនុស្សអស់រយៈពេល៣ឆ្នាំ ។

## ស្រុកបាណន់:

***១) ចន្លោះភ្នំក្តោងនិងភ្នំសំពៅ:*** ជាទីតាំងមន្ទីរសន្តិសុខ គុក និងទីតាំងសម្លាប់មនុស្សក្រោមរបបកម្ពុជាប្រជាធិបតេយ្យ ។ ទីតាំងនេះស្ថិតនៅក្នុងភូមិភ្នំសំពៅលិច ឃុំភ្នំសំពៅ ស្រុកបាណន់ ខេត្តបាត់ដំបង ដែលមានចម្ងាយ១៤គីឡូម៉ែត្រ ពីទីរួមខេត្តត្រង់ចន្លោះភ្នំក្តោងនិងភ្នំសំពៅទីតាំងនេះស្ថិតនៅត្រង់ចំណុចខ្សែស្រប ១៣°១០'០៨០៩" និងខ្សែបណ្តោយ ១០៣°០៥' ៣៦០០" ។ ទិន្នន័យចំណុចទីតាំងភូមិសាស្ត្រនេះត្រូវបានថតទុកដោយលេខកូដ២០១០១ និងលេខឯកសារ R០៥០២០៥A ។

***២) ល្អាងតិរីរម្យៈ*** ជាកន្លែងតម្កល់អដ្ឋិធាតុជនគ្រោះនៃរបបកម្ពុជាប្រជាធិបតេយ្យ ។ ទីតាំងនេះស្ថិតនៅក្នុងភូមិសំពៅលិច ឃុំសំពៅ ស្រុកបាណន់ ខេត្តបាត់ដំបងដែលនៅលើភ្នំសំពៅជិតភ្នំក្តោង ។ ទីតាំងនេះស្ថិតនៅក្នុងចំណុចខ្សែស្រប ១៣° ០១' ១៦៥០" និងខ្សែបណ្តោយ១០៣° ០៥' ៥១៩៧" និងថតទុកក្នុងឧបករណ៍អេឡិចត្រូនិកដោយលេខកូដ ២០១០២/៣/៤


កន្លែងតម្កល់អដ្ឋិធាតុនៅល្អាងគិរីរម្យ ភ្នំសំពៅ

និងលេខឯកសារR០៥០២០៨A ។

លោក ប្រាក់ រ៉ុម បានឲ្យថា កាលពីជំនាន់ប៉ុល ពត គាត់ធ្វើចម្ការនៅលើភ្នំក្តោងចម្ងាយពីគុកប្រហែល២០០ម៉ែត្រ ។ គាត់បានឃើញការសម្លាប់មនុស្សផ្ទាល់ភ្នែក មានពេលខ្លះជនរងគ្រោះបានរត់រួចខ្លួនពីការសម្លាប់ខ្លះដែរដោយបន្លំធ្វើជាអ្នកចម្ការ ។ នៅទីនោះក្មេងៗអាយុ១០ទៅ១២ឆ្នាំក៏យកមកសម្លាប់ដែរ ដោយសារតែលួចបេះផ្លែឈើស៊ី ។ល ។ ចំពោះតាចាស់ៗត្រូវបានពួកខ្មែរក្រហមឲ្យធ្វើបង្គីនិងចិញ្ចឹមជ្រូក ។


ប្រាក់ រ៉ុម

នៅឆ្នាំ១៩៧៧ ពួកខ្មែរក្រហមបានប្រមូលជនរងគ្រោះមកពីគ្រប់កន្លែងផ្សេងៗដោយដឹកទាំងឡានៗយកមកបញ្ចូលគុកទីនោះជារៀងរាល់ថ្ងៃ ។ នៅពេលម៉ោង៤ម៉ោង៥ល្ងាចពួកខ្មែរក្រហមបានចងដៃជនរងគ្រោះជាក្រុមៗ ហើយបណ្តើរឡើងលើកំពូលភ្នំគិរីរម្យយកទៅសួរចម្លើយ រួចសម្លាប់ ។ គ្មាននរណារត់រួចខ្លួនឡើយ ។ មុនពេលសម្លាប់ពួកខ្មែរក្រហមបានទុកជនរងគ្រោះបង្អត់បាយមួយរយៈសិន ទើបយកទៅសម្លាប់ជាក្រោយ ។ សាក្សីរូបនេះបន្ថែមថា ពីមុនឆ្នាំ១៩៧៨-៧៩ ខ្មែរក្រហមបានបញ្ជូនអ្នកទោសដែលសុទ្ធតែមានបញ្ជីឈ្មោះភ្ជាប់មកជាមួយ ។ ដល់ឆ្នាំ១៩៧៧-៧៨ អ្នកទោសនាំមកភ្លាមយកទៅសម្លាប់ចោលភ្លាមតែម្តង ជនរងគ្រោះក្មេងៗក៏ត្រូវខ្មែរក្រហមយកទៅសម្លាប់ចោលដែរ ។ ចំពោះចាស់ៗសួរចម្លើយរួចអារកសម្លាប់ចោល ។ ទីនោះគ្មានរណ្តៅទេដោយយកល្អាងភ្នំដ៏ធំនិងជ្រៅៗបំផុត វាយសម្លាប់ទម្លាក់ចុះតែម្តង ហើយជនរងគ្រោះដែលត្រូវបានសម្លាប់មានរហូតដល់ចំនួន១៥៧០០នាក់ ។ គុកនិងកន្លែងសម្លាប់ស្ថិតនៅជើងភ្នំ ចន្លោះភ្នំសំពៅនិងភ្នំក្តោង ។ ជនរងគ្រោះត្រូវបានខ្មែរក្រហមអារកបង្ហូរឈាមតាមទុចុះមកក្រោមដែលមានទនៅជាប់ជញ្ជាំងព្រះវិហារជាភស្តុតាងស្រាប់ ។ កន្លែងសម្លាប់មានចំនួន៧ទីតាំង គឺល្អាងកំពូលភ្នំ១ ល្អាងតែងខ្ទួន១ ល្អាងល្ហោន២ និងល្អាងលើបំផុត៣កន្លែង ។

បញ្ហាភស្តុតាងរណ្តៅកន្លែងខ្ទក្រិដ្ឋកម្មខ្លះរលុបអស់ រីឯអដ្ឋិធាតុទៀតសោតបាត់បង់ដោយសារជនមិនស្គាល់មុខលួចជុតបំផ្លាញ ហើយអដ្ឋិធាតុដែលនៅសេសសល់ខ្លះនោះមិនត្រូវបានការពារឲ្យបានជិតដល់ទេ ។ ម្យ៉ាងទៀតទីតាំងទុកដាក់អដ្ឋិធាតុត្រូវពុកផុយបាក់បែកទ្រុឌទ្រោមអស់ទៅហើយ ។ **ឌួង សុភារិទ្ធ**

# ប្រវត្តិរូបសមមិត្ត ម៉ុន

## (កូនស្រីរបស់ សុន សេន)

**១) អំពីផ្ទាល់ខ្លួនៈ**

ឈ្មោះដើម សេន សូរិយា ឈ្មោះបដិវត្តន៍ ម៉ុន នៅមន្ទីរពេទ្យបដិវត្តន៍៣១ ក្រសួងសង្គមកិច្ច កើតនៅភ្នំពេញ ឆ្នាំ១៩៦១(១៩ឆ្នាំ) ភេទស្រី ជនជាតិខ្មែរ នៅលីវ ។ មុនរដ្ឋប្រហារវណ្ណៈភាពអនុធន របររកស៊ីនៅជាមួយជីដូន រៀនសូត្រនៅសាលាវត្តកោះភ្នំពេញ ។ ក្រោយមកបានទៅនៅរៀនសូត្រនៅវត្តដំណាក់ ខេត្តសៀមរាប ។ របររកស៊ីវណ្ណៈភាពក្រោយរដ្ឋប្រហារនៅរៀនដដែល ។ មុនចូលធ្វើបដិវត្តន៍មិនចូលអង្គការនយោបាយណាទេ ។ ចូលបដិវត្តន៍នៅឆ្នាំ១៩៧១ នៅមន្ទីរ៣០៥ ភូមិទួលខ្សាច់ ឃុំពាម ស្រុកកំពង់ត្រឡាច (ខេត្តកំពង់ឆ្នាំង) អ្នកនាំចូលអត់ស្គាល់ឈ្មោះ ។ មូលហេតុគឺមកពីខ្លួនមិនបានយល់មាគ៌ាបដិវត្តន៍ទេ ព្រោះគេទៅយកមក ហើយគ្មានបានចូលអង្គការស្នូលរបស់បក្សឡើយ ។

តាំងពីចូលបដិវត្តន៍មកធ្លាប់បានឆ្លងកាត់មន្ទីរ៣០៥ អ្នកទទួលខុសត្រូវអត់ស្គាល់ ។ ក្រោយមកបានមកនៅមន្ទីរសិល្បៈ៣០៦ អ្នកទទួលខុសត្រូវឈ្មោះ ឡុង នាទីអត់ដឹង ។ ក្រោយមកទៀតបានទៅនៅខេត្តកំពង់ចាម ភូមិភាគកណ្តាល នៅមន្ទីរ២៤ ប៧- ៧៤-៧៥ អ្នកទទួលខុសត្រូវអត់ស្គាល់ ។ ក្រោយរំដោះបាននៅមន្ទីរក-២ ក-១ ក-៣ ក-១៧ អ្នកទទួលខុសត្រូវក-១៧ ឈ្មោះ សារ៉ន (ក្បត់បដិវត្តន៍) ។ មានភារកិច្ចរៀនបកប្រែភាសាកម្ពុជា-ចិននៅមន្ទីរ៣១ ។

កម្រិតវប្បធម៌របបចាស់ថ្នាក់ទី៩ កម្រិតវប្បធម៌របបថ្មីចេះអាននិងសរសេរមធ្យម ។ អត្តចរិតបដិវត្តន៍ស្មោះត្រង់បដិវត្តន៍ អត្តចរិតមិនបដិវត្តន៍ចិត្តឆេវឆាវ លេងសើចច្រើនមាត់ច្រើន ។ ស្គាល់គុណសម្បត្តិរបស់ខ្លួនដោយស្រឡាញ់ស្មោះត្រង់នឹងសមូហភាព បដិវត្តន៍ និងបក្ស ។ ការរស់នៅស្អាតស្អំ ស្គាល់ពីគុណវិបត្តិរបស់ខ្លួនដោយនៅសម្ងំសុខមិនហ៊ានមានមតិ បុគ្គលច្រើនចិត្តឆេវឆាវ ។ បានខិតខំកែប្រែនូវគុណវិបត្តិនិងអាកប្បកិរិយាមួយចំនួន ហើយបានខិតខំរៀនសូត្រពីគំរូសមូហភាពថែមទៀត និងខិតខំកម្ចាត់ភាពសម្ងំសុខបុគ្គលនិយម ឆេវឆាវ ។

សីលធម៌រស់នៅខាងស្មារតីនិងសម្ភារ មុនចូលធ្វើបដិវត្តន៍រស់នៅស្អាតស្អំមិនដើរហើរទាក់ទងអ្វីទេ ។ ខាងសម្ភារក៏មិនដែលប្រើប្រាស់ខ្ជះខ្ជាយដែររស់នៅសមរម្យ និងគ្រប់គ្រាន់ប្រើប្រាស់ប៉ុណ្ណោះ ។ សីលធម៌រស់នៅក្រោយបដិវត្តន៍កាន់តែស្អាតស្អំថែមទៀត មិនដើរហើរសេរីទៅណាមកណាទេឬនិយាយស្តីសេរីទេ ។ ជីវភាពសន្សំសំចៃ អនាម័យ សណ្តាប់ធ្នាប់មានជានិច្ច រស់នៅមានអនាម័យល្អ ។

**២) អំពីឪពុកម្តាយបង្កើតៈ**

ឪពុកឈ្មោះ សុន សេន ឈ្មោះបដិវត្តន៍ ខៀវ ជនជាតិខ្មែរ នៅរស់ ម្តាយឈ្មោះ យុន យ៉ាត ឈ្មោះបដិវត្តន៍ អាត ជនជាតិខ្មែរ នៅរស់ ។ វណ្ណៈភាពមុនរដ្ឋប្រហារអនុធន របររកស៊ីធ្វើគ្រូបង្រៀន ។

**៣) អំពីបងប្អូនបង្កើតៈ**

មានបងប្អូនចំនួនពីរនាក់ ប្រុសម្នាក់និងស្រីម្នាក់ ។ ប្រុសឈ្មោះ សេន រស្មី ឈ្មោះបដិវត្តន៍ មី អាយុ២០ឆ្នាំ នៅលីវ ជាសិស្សសាលា វណ្ណៈភាពដើមអនុធនសិស្ស ។ (ស្រីឈ្មោះ សេន សូរិយា (ខ្លួនឯងផ្ទាល់) ឈ្មោះបដិវត្តន៍ ម៉ុន អាយុ១៩ឆ្នាំ នៅលីវ ជាសិស្សសាលា វណ្ណៈភាពដើមអនុធនសិស្ស ។) ម្នាក់ៗគ្មានចូលអង្គការនយោបាយណាទេបានចូលបដិវត្តន៍ទាំងអស់គ្នា ។ បងប្រុសនៅខាងអង្គភាពយោធា ។

**៤) អំពីបងប្អូនជីដូនមួយៈ**

មានបងប្អូនជីដូនមួយចំនួន៣នាក់ ស្រី១នាក់ ប្រុស២នាក់ ។ ១) ឈ្មោះដើម មឿន ទេពពី ឈ្មោះបដិវត្តន៍ ពូល ភេទស្រី រស់នៅជាមួយឪពុកម្តាយ ។ ២) ឈ្មោះដើម មឿន បូញ៉ា ឈ្មោះបដិវត្តន៍ហៅ បិច ភេទប្រុស រស់នៅជាមួយឪពុកម្តាយនិង ៣) ឈ្មោះដើមនិងឈ្មោះបដិវត្តន៍ ប៊ី ភេទប្រុស រស់នៅជាមួយឪពុកម្តាយ ។ គ្មាននរណាម្នាក់ចូលអង្គការនយោបាយណាទេ ចូលបដិវត្តន៍ទាំងអស់គ្នា ។

**ថ្នូង សុភារិទ្ធ**

**(សង្ខេបចេញពីឯកសារ I ០២៣២៤)**



# លក្ខណៈសម្បត្តិ១០ ខរបស់បក្ស

(ឯកសារទង់បដិវត្តន៍ ខែកក្កដា ឆ្នាំ១៩៧៨) (តចប់)

***៧) កសាងជំហរបដិវត្តន៍ខាងការធ្វើ និងត្រួតពិនិត្យប្រវត្តិរូប និងទស្សនៈបដិវត្តន៍ ៖***

ជាដំបូងបក្ខជនគ្រប់រូបត្រូវមានទស្សនៈឲ្យបានត្រឹមត្រូវ និងក្តាប់សំណូមពរនៃការកសាងជំហរបដិវត្តន៍ខាងការធ្វើ និងត្រួតពិនិត្យប្រវត្តិរូបនិងទស្សនៈបដិវត្ត ។ សំណូមពរនៃការធ្វើប្រវត្តិរូបរបស់បក្ខជនមួយរូបៗ សំខាន់ដើម្បីឲ្យសាមីខ្លួនស្គាល់ខ្លួនឯងឲ្យច្បាស់ ។ ស្គាល់ខ្លួនឯងគឺស្គាល់អ្វី? គឺស្គាល់វណ្ណៈដើមរបស់ខ្លួន ស្គាល់ការទាក់ទងក្នុងសង្គមរបស់ខ្លួន ស្គាល់អត្តចរិតរបស់ខ្លួន ស្គាល់ចំណុចខ្លាំងនិងចំណុចខ្សោយរបស់ខ្លួនឲ្យច្បាស់ ។ និយាយឲ្យខ្លីគឺក្តាប់ទំនាស់ក្នុងខ្លួនឲ្យជាប់ជាទំនាស់ខាងគោលជំហរនយោបាយ សតិអារម្មណ៍និងចាត់តាំងដើម្បីខ្លួនឯង កសាងខ្លួនឯងនិងដើម្បីសមូហភាពជួយកសាងថែមទៀត ។ ការត្រួតពិនិត្យប្រវត្តិរូបគឺដើម្បីស្វែងរកឲ្យយល់នូវលោកទស្សនៈរបស់បក្ខជនម្នាក់ៗ ។ តើកន្លងមកសមមិត្តយើងមានទស្សនៈយ៉ាងណា? បើក្តាប់នូវលោកទស្សនៈរបស់ខ្លួនបានហើយ អាចស្គាល់នូវជីវទស្សនៈរបស់ខ្លួនបានត្រឹមត្រូវ ។

ការកសាងឲ្យបក្ខជនមានលោកទស្សនៈបដិវត្តនិងជីវទស្សនៈបដិវត្តគឺជាការកសាងគោលជំហរជាមូលដ្ឋានឲ្យបក្ខជនយើង ឲ្យបក្សយើង ។ ចង់បំពាក់បំប៉នខាងគោលជំហរនយោបាយ សតិអារម្មណ៍ ចាត់តាំងរបស់បក្សឲ្យបានរឹងប៉ឹង ត្រូវមានគោលជំហរជាមូលដ្ឋានរឹងប៉ឹង ទើបទទួលបានមាគ៌ានយោបាយ សតិអារម្មណ៍ ចាត់តាំងរបស់បក្ស ។ មូលដ្ឋាននោះគឺលោកទស្សនៈបដិវត្ត និងជីវទស្សនៈបដិវត្ត ។ តាមពិសោធន៍ បើសមមិត្តណាខស្សាហ៍ពិនិត្យលោកទស្សនៈបដិវត្តនិងជីវទស្សនៈបដិវត្តរបស់ខ្លួនដោយខ្លួនឯងផ្ទាល់ក្តីឬដោយសមូហភាពក្តី សមមិត្តនោះច្រើនមានគោលជំហរជាមូលដ្ឋាន

រឹងប៉ឹង ។ ពេលជួបឧបសគ្គ សមមិត្តមិនបាត់ស្មារតី ។ ពេលទទួលបានជ័យជំនះមិនភ្លើតភ្លើន ។

ត្រួតពិនិត្យជីវទស្សនៈបដិវត្តគឺជួយរំឭកយើងថា តើយើងរស់នៅដើម្បីអ្វី? ។ ជួយតឿនសតិសម្បជញ្ញៈយើងជានិច្ចថាហេតុដូចម្ដេចបានជាយើងមកធ្វើបដិវត្តន៍? តើយើងធ្វើបដិវត្តន៍ដើម្បីអ្វី? តើយើងធ្វើបដិវត្តន៍បម្រើអ្នកណា? បើបានសំលៀងជីវទស្សនៈបដិវត្តឲ្យមុតថ្លាជាប់ជានិច្ច វាគ្មានអ្វីស្មុគស្មាញក្នុងបញ្ហាកម្មសិទ្ធិឯកជនទៀតទេ ។ សមមិត្តយើងខ្លះដែលនៅស្មុគស្មាញពីកម្មសិទ្ធិឯកជនមកពីទស្សនៈបដិវត្តនិងជីវទស្សនៈបដិវត្តមិនស្រួច មិនមុតជាប់ជានិច្ច ។

បច្ចុប្បន្ននេះក៏ដូចជាទៅអនាគតទៀត យើងត្រូវមានលោកទស្សនៈបដិវត្តនិងជីវទស្សនៈបដិវត្តជាក់ស្ដែងជារូបីយ៉ាងម៉េច? លោកទស្សនៈបដិវត្តរបស់យើងគឺឃើញច្បាស់ថាកម្ពុជាយើងកំពុងត្រូវខ្មាំងយួនឈ្លានពាន វាតទីលេបទឹកដី បំបាត់ពូជសាសន៍ ។ បច្ចុប្បន្ននេះក៏អ៊ីចឹង ទៅថ្ងៃអនាគតក៏អ៊ីចឹង ។ យើងឃើញច្បាស់ទៀតថាប្រជាជនកម្ពុជាក្រោមការដឹកនាំរបស់បក្សកុម្មុយនិស្តកម្ពុជាកំពុងប្រយុទ្ធយ៉ាងអង់អាចក្លាហានកម្ចាត់យួន ហើយកំពុងសស្រាក់សស្រាំធ្វើបដិវត្តន៍សង្គមនិយមនិងកំពុងសស្រាក់សស្រាំកសាងសង្គមនិយមបានទទួលជ័យជំនះជាបន្តបន្ទាប់ ។

បើមានលោកទស្សនៈបដិវត្តច្បាស់លាស់យ៉ាងនេះហើយ តើយើងកសាង យើងកំណត់នូវទស្សនៈបដិវត្តរបស់យើង គឺកំណត់ការរស់នៅរបស់យើង កំណត់គោលជំហរនយោបាយ សតិអារម្មណ៍ ចាត់តាំង មនោសញ្ចេតនា ។ល។ របស់យើងយ៉ាងដូចម្ដេចដើម្បីឲ្យស្របកុំឲ្យជំទាស់នឹងលោកទស្សនៈបដិវត្ត? ។ ជីវទស្សនៈបដិវត្តដែលសមស្របបំផុតត្រឹមត្រូវបំផុតរបស់យើងគឺដាច់ខាតវាយខ្មាំងយួនឈ្លានពានដាច់ខាតធ្វើបដិវត្តន៍សង្គមនិយម កសាងសង្គមនិយមតាមមាគ៌ារបស់បក្ស ។ កុំអាដែងគេម៉ាប្រទេសកំពុងវាយខ្មាំងយួនឈ្លានពាន ឯងម្នាក់ឯងឱនក្បាលគគ្រុកទៅធ្វើឆ្អែបម្រើយួន ។ កុំអាដែងគេម៉ាប្រទេសកំពុងសស្រាក់សស្រាំធ្វើបដិវត្តន៍សង្គមនិយម ឯងម្នាក់ឯងរវល់តែរឿងកម្មសិទ្ធិឯកជនកំប៉ិកកំប៉ុក ។ កុំអាដែងគេម៉ាប្រទេសកំពុងដុតដៃដុតជើងកសាងសង្គមនិយម ឯងម្នាក់ឯងដេកយោលអង្រឹងកូតទ្រ ឯដីជុំវិញផ្ទះសល់គគោករកតែម្ទេសមួយដើម ស្លឹកគ្រៃមួយគុម្ពគ្មានផង ។ បញ្ហានេះមិនអ៊ីចឹងសមមិត្ត! អ៊ីចឹងមែនហើយ បានជាបក្សយើងកំណត់ច្បាស់ថាត្រូវកសាងគោលជំហរបដិវត្តរឹងប៉ឹងខាងការធ្វើ និងត្រួតពិនិត្យប្រវត្តិរូបជីវទស្សនៈបដិវត្ត ។

បក្សជនម្នាក់ៗត្រូវមានគោលជំហរបដិវត្តត្រឹមត្រូវនិងរឹងប៉ឹងដោយស្មារតីទទួលខុសត្រូវខ្ពស់ក្នុងការធ្វើការត្រួតពិនិត្យ និងកសាងប្រវត្តិរូបបដិវត្ត ជីវទស្សនៈបដិវត្តរបស់ខ្លួនជាបន្តបន្ទាប់ ។ ត្រូវស្មោះត្រង់ក្នុងការត្រួតពិនិត្យប្រវត្តិរូបនិងជីវទស្សនៈបដិវត្តរបស់ខ្លួន ហើយក្នុងការកែប្រែគុណសម្បត្តិតូចធំរបស់ខ្លួនដាច់ខាត ហើយនិងជំរុញការកសាងពង្រឹងពង្រីកគុណសម្បត្តិខ្លួនឲ្យរីកចម្រើនឆាប់រហ័សជាបន្តបន្ទាប់ ។

## ៨) កសាងគោលជំហរបដិវត្តរឹងប៉ឹងខាងវណ្ណៈភាព

សំណូមពរបក្ស គឺវណ្ណៈណាក៏ដោយដែលចូលមកនៅក្នុងជួរបដិវត្តន៍ ក្នុងជួរបក្ស ត្រូវតែកម្ចាត់ចោលនូវគោលជំហរនៃវណ្ណៈដើមរបស់ខ្លួនដោយកសាងគោលជំហរវណ្ណៈកម្មកររបស់បក្សឲ្យបានរឹងប៉ឹង ។ ជាការប្រសើរណាស់ហើយដែលយើងម្នាក់ៗបានខំប្រយុទ្ធធ្វើបដិវត្តន៍ ហើយបានទទួលកិត្តិយសធ្វើជាបក្សជននៃបក្សកុម្មុយនិស្តកម្ពុជា ។ តែដើម្បីឲ្យប្រសើរលើសនេះទៅទៀត គឺយើងម្នាក់ៗត្រូវខិតខំកសាងខ្លួនឲ្យទៅជាបក្សជននៃបក្សកុម្មុយនិស្តកម្ពុជាល្អរហូតអស់មួយជីវិត ។ មានសមមិត្តខ្លះបានចូលធ្វើបដិវត្តន៍តាំងពីសក់ខ្មៅរហូតដល់ឥឡូវសក់សតែដោយមិនបានយកចិត្តទុកដាក់អប់រំកសាងខ្លួនតាមគោលជំហរនៃវណ្ណៈកម្មកររបស់បក្សក៏មិនបានចម្រើនជឿនលឿនវិលចុះវិលឡើងតែពីរឿងកម្មសិទ្ធិឯកជន ជាមុខមាត់បុណ្យសក្តិ គ្រួសារនិយម ។ល។ ហើយមានខ្លះទៀតធ្លាក់ចេញពីជួរបដិវត្តន៍ ជួរបក្សក៏មានដែរ ។ ឃើញយ៉ាងនេះបានជាគួរសរសើរខ្លាំងណាស់ដល់សមមិត្តយើងគ្រប់ជំនាន់ដែលបានខិតខំប្រយុទ្ធកសាងខ្លួនតាមការដឹកនាំរបស់បក្ស ។ សមមិត្តទាំងនោះចេះស្រឡាញ់ ចេះគិតគូរសុខទុក្ខម៉ែឪប្រពន្ធកូន តែគេទាំងឡាយចេះស្រឡាញ់បក្សគិតគូរដល់ផលប្រយោជន៍បក្ស ផលប្រយោជន៍ប្រទេសជាតិប្រជាជនបដិវត្តន៍លើសអ្វីៗទាំងអស់សូម្បីជីវិតគេក៏ហ៊ានលះបង់ដោយគ្មានលក្ខខណ្ឌ ដើម្បីបក្សប្រទេសជាតិ ប្រជាជន និងបដិវត្តន៍ ។

ការលំបាក ការស្រួល ក្តៅត្រជាក់យ៉ាងណាក៏ដោយ សមមិត្តទាំងនោះចុះជាប់ប្រឡូកជាប់ក្នុងចលនាមហាជន ធ្វើជាគំរូក្នុងគ្រប់កិច្ចការការងារពលកម្មបង្កបង្កើនផលដោះស្រាយជីវភាពប្រជាជន ។ សមមិត្តទាំងនោះទោះជាមានជោគជ័យ មានថ្វីដៃក្នុងការប្រយុទ្ធក្នុងការធ្វើការងារពលកម្មយ៉ាងណាក៏ដោយ ក៏នៅតែសុភាពរាបសា គោរពអង្គការវិន័យដោយឥតលក្ខខណ្ឌ ដាក់ខ្លួនឲ្យប្រជាជនកសាងជានិច្ច ។ រស់នៅជាជនកុម្មុយនិស្តសាមញ្ញធម្មតាមួយរូប ។

បក្សយើងកក់ក្តៅណាស់ចំពោះសមមិត្តទាំងនេះ ។ សមមិត្តទាំងនេះបានទទួលនូវការទំនុកទុកចិត្តពីបក្ស បានទទួលនូវការជឿជាក់ពីប្រជាជន មហាជន ។ នេះជារង្វាន់ដែលគេបានទទួល ។ រង្វាន់នេះមានតម្លៃខ្ពង់ខ្ពស់ ...

កម្មាភិបាលយុទ្ធជនយើងធ្វើការនៅជាប់ព្រំដែនយួនត្រូវប្រុងប្រយ័ត្នឲ្យខ្ពស់មែនទែនខាងសីលធម៌រស់នៅ ។ តាមពិសោធន៍កន្លងមកខ្មាំងយួនវាយកស្រីយួនមកទាក់ទងកម្មាភិបាលយុទ្ធជនយើង ធ្វើឲ្យពុករលួយ ពាលាអាវាសែ ដើម្បីវាអូសទាញឲ្យបម្រើនយោបាយឈ្លានពាន វាតទីលេបទឹកដី បំបាត់ពូជសាសន៍កម្ពុជាយើងរបស់វា ។ នេះជានយោបាយរបស់បងយួនឡេ យន់ ដាំ វ៉ាន់ដុង តែម្តង ។

ខ្មាំងបង្កប់ស៊ីរូងផ្ទៃក្នុងជាភ្នាក់ងារសេ.អ៊ី.អា ភ្នាក់ងារ

# ចាមដែលជាកម្មាភិបាលខ្មែរក្រហម

"ពេលធ្វើទារុណកម្ម ខ្ញុំគិតតែពីវៃ អត់គិតរឿងដេញដោលទេ ធ្វើយ៉ាងម៉េចឲ្យអ្នកទោសទុរន់ទុរាធ្វើការលែងកើតក្នុងពួកខ្ញុំផ្ទាល់វៃអ្នកទោសងាប់អស់បួននាក់" ចម្លើយរបស់ ស៊ឹម ម៉េល ហៅ ម៉ាន មួយឃ្លានេះជាភស្តុតាងបញ្ជាក់នូវទង្វើសាហាវឃោរឃៅរបស់អ្នកសួរចម្លើយនៅគុកទួលស្លែងមកលើអ្នកទោសស្លូតត្រង់ ។

ម៉ាន បានធ្វើការនៅក្នុងគុកទួលស្លែងជាអ្នកសួរចម្លើយ ចាប់ពីខែកក្កដា ឆ្នាំ១៩៧៦ និងរហូតដល់បក្សបញ្ឈប់ពីការងារនេះនៅខែមីនា ឆ្នាំ១៩៧៧ ។

បន្ទាប់ពីធ្វើការងារនៅគុកទួលស្លែង ម៉ាន ត្រូវបានបក្សបញ្ជូនឲ្យទៅធ្វើស្រែនៅព្រៃស (ស-២១យ ឬមន្ទីរ២៤) ជាសាខារបស់ទួលស្លែង រហូតត្រូវចាប់ខ្លួន ហើយបញ្ជូនមកដល់ទួលស្លែងវិញនៅថ្ងៃទី២៨ ខែតុលា ឆ្នាំ១៩៧៧ ។ នៅពេលក្លាយជាអ្នកទោស ម៉ាន ត្រូវបានឈ្មោះ "ឈិន" និង "វុន" សួរចម្លើយវិញម្តងគឺចាប់ផ្តើមសួរនៅថ្ងៃទី៣ ខែវិច្ឆិកា ឆ្នាំ១៩៧៧ និងបញ្ចប់ការសួរនៅថ្ងៃទី១៣ ខែមករា ឆ្នាំ១៩៧៨ ។ តាមឯកសារចម្លើយសារភាពរបស់ ម៉ាន មានចុះកាលបរិច្ឆេទ២២ លើកផ្សេងៗគ្នា អាចបញ្ជាក់ថា ម៉ាន ត្រូវបានសួរចម្លើយ២២ លើកដែរ ។ ក្រោយពីការសួរចម្លើយផ្តែកផ្តួន់ហើយពួកខ្មែរក្រហមនៅតែឃុំឃាំង ម៉ាន បន្តទៀត រហូតដល់ថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៧៨ ទើបមានបញ្ជាពីថ្នាក់លើឲ្យយក ម៉ាន ទៅកម្ទេចចោល ។ ឯកសារចម្លើយសារភាពរបស់ ម៉ាន ចំនួន៩៧ ទំព័រ ត្រូវបានរក្សាទុករហូតមកដល់សព្វថ្ងៃនេះ ។



ម៉ម កេង
អ្នកទោសដែលម៉ានធ្វើទារុណកម្ម
រហូតដល់ស្លាប់

ក្នុងរយៈពេល៨ខែជាអ្នកសួរចម្លើយអ្នកទោសនៅគុកទួលស្លែង ម៉ាន បានធ្វើបាប និងវាយសម្លាប់អ្នកទោសស្លូតត្រង់និងអ្នកចេះដឹងអស់ជាច្រើននាក់ ។ ខាងក្រោមនេះគឺជាការដកស្រង់សម្តី ម៉ាន ដែលបានរៀបរាប់សកម្មភាពរបស់ខ្លួនទៅលើអ្នកទោស÷ "ខ្ញុំវៃឈ្មោះ ម៉ម កេង ហៅ សាក់ ទុរន់ទុរាយកមកធ្វើការលែងកើត ។ សួរឈ្មោះ កែ មាស មន្ត្រីរោង វាតឹងតែងមិនព្រមនិយាយ ខ្ញុំខ្ជិលសួររួមជាមួយ ហ៊ីង វៃទាល់តែយកមកធ្វើការលែងកើតរហូតស្លាប់នៅក្នុងគុក ។ ខ្ញុំបានធ្វើសកម្មភាពជាមួយ ហ៊ីង ពេលសួរឈ្មោះ គិត ស៊ឹម ហៅ និន ។ ខ្ញុំ ឡេង និង ថុង បានវៃឈ្មោះ ឈឿន នាទីវរសេនាតូចកងពល៩២០ និងឆន មេក្រុម៣១០ ដោយវាមិនព្រមនិយាយ វៃទុរន់ទុរាយកមកធ្វើលែងកើត ។ ខ្ញុំវៃស្លាប់ម្នាក់ឈ្មោះ ដែន មកពីមន្ទីរពេទ្យ ព ៩៨ ។ ឡេង រួមជាមួយ ហ៊ីង វៃអាសក្តិបួននៅក្រសួងភូមិសាស្ត្រ បណ្តាលឲ្យទុរន់ទុរាគ្មានបានចម្លើយរហូតស្លាប់ក្នុងគុក ។ ខ្ញុំបានសួរឈ្មោះ ទា ម៉េងគេក មកពីម៉ាឡេស៊ី ។ ខ្ញុំបានសួរឈ្មោះ នីន មេក្រុមពេទ្យ ព-៩៨" ។



កែ មាស
អ្នកទោសដែលម៉ានធ្វើទារុណកម្ម
រហូតដល់ស្លាប់



ទា ម៉េងគេក

នៅខែមីនា ឆ្នាំ១៩៧៧ បក្សបានបញ្ជូន ម៉ាន ឲ្យទៅនៅមន្ទីរអប់រំព្រៃសហើយបានផ្តល់តួនាទីជាសមាជិកកងអនុសេនាធំ១៣ នៃមន្ទីរ២៤ ឬ ស-២១យ ។ នៅខែសីហា ឆ្នាំ១៩៧៧ បក្សបានដក ម៉ាន ឲ្យមកកាន់តួនាទីជាសមាជិកគណៈកសិកម្មមន្ទីរ២៤វិញ ។ មានថ្ងៃមួយប្រធានមន្ទីរឈ្មោះ ហ៊ុយ (ហ៊ុយស្រែ) ប្រុងចាប់ខ្លួន ម៉ាន

ដោយមូលហេតុបូមទឹកមិនទាន់អ្នកស្នង ប៉ុន្តែ ម៉ាន ដឹងគម្រោងការនេះមុនតាមរយៈមិត្តភក្តិក៏ភៀសខ្លួនទៅតំបន់២៥ ។ នៅថ្ងៃទី២៤ ខែតុលា ឆ្នាំ១៩៧៧ ម៉ាន បានជិះកង់រត់តាមផ្លូវលេខ៣៨ មានបំណងទៅជួបបង "ជា" លេខាតំបន់២៥ ដើម្បីលាក់ខ្លួននៅក្នុងតំបន់នោះដោយមានមិត្តភក្តិណែនាំបង "ជា" ឲ្យស្គាល់ ម៉ាន តាមរយៈសំបុត្រមួយច្បាប់ដែល ម៉ាន កាន់យកទៅ ។ សំបុត្រនោះសរសេរថា "ស្នើឲ្យបង ជា លេខាតំបន់២៥ ទទួលយក ម៉ាន នេះលាក់បាំងផង ព្រោះនៅមន្ទីរអប់រំព្រៃសនេះ បក្សបម្រុងមានផែនការចាប់ខ្លួនមិត្តដែលកាន់សំបុត្រនេះ" ។

ពេល ម៉ាន ទៅដល់ខាងលិចសាលាស្រុកស្អាង ឈ្លបបានឃាត់ដំណើរ ។ "ខ្ញុំឃើញសភាពការណ៍មិនស្រួល មុនពេលឈ្លបមកឆែកខ្ញុំ ខ្ញុំលបហែកសំបុត្រនេះចោលក្នុងស្មៅពេលឈ្លបឆែកខ្ញុំ ខ្ញុំអត់សំបុត្រដើរផ្លូវ ឈ្លបនោះក៏ចាប់ខ្ញុំ" សម្តី ម៉ាន ក្នុងចម្លើយសារភាព ។ ម៉ាន ត្រូវបានយកទៅឃុំឃាំងនៅកោះគរ ក្នុងឃុំរកាខ្ពស់ ស្រុកស្អាង ខេត្តកណ្តាល រយៈពេល៤ថ្ងៃ បន្ទាប់មកក៏បានបញ្ជូនមកឃុំឃាំងបន្តនៅគុកទួលស្លែងជាកន្លែងដែល ម៉ាន ធ្លាប់ធ្វើការ ។ ត្រង់នេះ ជឹម អាមីណះ បច្ចុប្បន្នរស់នៅភូមិបារ៉ែនក្រោម ឃុំស្វាយប្រទាល ស្រុកស្អាង ខេត្តកណ្តាល ដែលបានឃើញហេតុការណ៍នៃការចាប់ខ្លួន ម៉ាន ដោយផ្ទាល់ភ្នែក បានអះអាងខុសពីក្នុងចម្លើយសារភាព ។ ជុំវិញការចាប់ខ្លួន ម៉ាន អាមីណះ បាននិយាយថា "ម៉ាន មកដល់ផ្ទះខ្ញុំផងនឹតម៉ោងប្រហែលជា៤ភ្លឺ កាលណោះផ្ទះខ្ញុំនៅភូមិវាលហៅភូមិដីស្លាប់ មកមានតែម្នាក់ឯងទេមានកង់មួយ អង្រឹងមួយ ស្បែកជើងមួយគូ ។ ខ្ញុំសួរទៅ ម៉ាន តើឯងមកហ្នឹងមកយ៉ាងម៉េច វាថាមីងកុំមាត់ ខ្ញុំមកហ្នឹងខ្ញុំរត់ដោយគេចាប់ខ្ញុំយកទៅសម្លាប់...គេសម្លាប់តាមមេហើយខ្ញុំ (ម៉ាន) នៅជាមួយបង ណាត ហើយឥឡូវបង ណាត និងបង ពីន គេយកទៅសម្លាប់អស់ហើយបានជាខ្ញុំមកហ្នឹង" ។ អាមីណះ បន្តទៀតថា "ខ្មែរក្រហមធ្លាប់ប្រកាសថា បើមានទ័ពឬមានបងប្អូនមកពីណាពីណីត្រូវជម្រាបគេ បើគ្នា (ម៉ាន) មកអីចឹង... បើយើងទៅជម្រាបគេ គេយកទៅសម្លាប់ ម៉្លោះហើយខ្ញុំយកវាទៅលាក់ក្នុងត្រង់សេលាក់បានពីរថ្ងៃ ហើយខ្ញុំចេះតែលាក់បាយយកមកឲ្យស៊ី...ពេលគេឃើញកង់គេសង្ស័យដល់ពេលគេចូលទៅឃើញវា (ម៉ាន)...គេសង្ស័យគេចាប់វា ចាប់វាវារត់ គេដេញផុតពីភ្នែកខ្ញុំ ខ្ញុំមិនដឹងជាគេចាប់បានឬអត់ទេ ខ្ញុំអត់ហ៊ានឈរមើលទេ" ។ ក្រោយពីនោះមក គ្រួសាររបស់ អាមីណះ ទាំងអស់ត្រូវបានជាប់ចោទពីបទស៊ុមគ្រលុំលាក់ខ្មាំង ហើយត្រូវបញ្ជូនទៅដាក់គុកនៅកោះខ្សាច់ទន្លេរហូតដល់ឆ្នាំ១៩៧៩ ។ តាមការបំភ្លឺរបស់ អាមីណះ មានមនុស្សពីរនាក់ដែលទៅចាប់ ម៉ាន សព្វថ្ងៃនៅរស់នៅឡើយ ។

ទោះជា ម៉ាន បាននិយាយក្នុងចម្លើយសារភាពខុសពីសាក្សីឃើញហេតុការណ៍នោះក៏ដោយ ក៏យើងគង់ដឹងច្បាស់ថាការចាប់ខ្លួន ម៉ាន នោះពិតជានៅភូមិដីស្លាប់មែន ។ បន្ទាប់ពីចាប់ខ្លួនបានហើយ ម៉ាន ត្រូវបានយកទៅឃុំឃាំងនៅគុកទួលស្លែងនៅបន្ទប់តូចលេខ១១ ក្នុងបន្ទប់ធំលេខ៥ ។ ដោយសារតែ ម៉ាន ធ្លាប់ធ្វើការនៅទីនោះស្រាប់ ក៏មានមិត្តភក្តិចាស់ៗជាអ្នកយាមស្គាល់គ្នាពីរ-បីនាក់ សម្រាប់ឲ្យការណ៍សម្ងាត់ដូចជាប្រាប់ផ្លូវជួយផ្តល់សម្លៀកបំពាក់ទាហានដើម្បីក្លែងខ្លួន និងចាក់សោររបងក្រៅឲ្យរត់ចេញ ។ ត្រឹមប៉ុណ្ណេះ ម៉ាន មានសង្ឃឹមច្រើនក្នុងការលួចរត់ចេញពីគុកបាន ប៉ុន្តែនៅមានឧបសគ្គមួយតូចប៉ុណ្ណោះដែលត្រូវដោះស្រាយដោយខ្លួនឯង ព្រោះគ្មានអ្នកណាម្នាក់ហ៊ានជួយ ម៉ាន នោះគឺត្រូវកាច់បំបាក់សោរខ្នោះដោយខ្លួនឯង ។

នៅយប់មួយ មិត្តភក្តិឲ្យសញ្ញាថាសភាពការណ៍ខាងក្រៅស្ងាត់ល្អហើយ ម៉ាន បានព្យាយាមកាច់បំបាក់ខ្នោះ កាច់ហើយកាច់ទៀតរហូតទាល់តែខ្នោះនោះត្រូវរបើកដាច់ចេញពីកជើង ។ "ពេលខ្ញុំកាច់សោរបានហើយ ខ្ញុំបានចេញពីបន្ទប់តូចជួយកាច់សោរឲ្យអ្នកជិតខាងបានម្នាក់ រួចខ្ញុំក៏ចូលទៅរកបង វ៉ាង (ម៉ាន ធ្លាប់ស្គាល់ វ៉ាង តាំងពីមុនជាប់គុក) ក្នុងបន្ទប់តូចរបស់គាត់ ប៉ុន្តែមិនបានឃើញគាត់ ពេលនោះមានអ្នកយាមដើរមកពីទិសខាងត្បូង ខ្ញុំបានប្រយុទ្ធ (វាយតប់) គ្នាជាមួយអ្នកយាម បន្តិចមកសភាពការណ៍ក៏ផ្អើលឆោឡោ ពេទ្យក៏បានចាប់ខ្ញុំជាប់" ម៉ាន សារភាព ។

ទីបញ្ចប់ ម៉ាន នៅតែជាប់ឃុំឃាំងនិងបន្តទទួលទារុណកម្មក្នុងគុកទួលស្លែងដដែលដោយគ្មានវិធីណាអាចរំដោះខ្លួនបានឡើយ គឺមានតែការរស់នៅក្រោមទារុណកម្មគ្រប់ពេលវេលា និងបានជួបប្រទះនូវអ្វីដែលខ្លួនធ្លាប់ប្រព្រឹត្តទៅលើអ្នកទោសទាំងប៉ុន្មានពី

ពេលមុនដូចជាការវាយដំបន្ទុំឲ្យឆ្លើយជាដើម ។ ពេលនេះទោះជា ម៉ាន ប្រឹងរត់គេចដល់ទីណាក៏ដោយ ក៏នៅតែគេចមិនផុតពីបាបកម្មទាំងនោះត្រូវតែធ្លាក់មកលើខ្លួនឯងវិញម្ដងរហូតដល់ថ្ងៃចុងក្រោយនៃជីវិតគឺ «កម្មុច» នៅថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៧៨ ។

ម៉ាន បានចូលធ្វើទាហានខ្មែរក្រហមតាំងពីឆ្នាំ១៩៧១ នៅស្រុកស្អាង ខេត្តកណ្ដាល ព្រោះតែខឹងនឹងទាហាន លន់ ណុល ដែលបានទម្លាក់គ្រាប់បែកនៅភូមិរបស់ខ្លួនបណ្ដាលឲ្យអ្នកភូមិស្លាប់និងឆេះផ្ទះអស់ជាច្រើន ជាពិសេសជីដូនរបស់ ម៉ាន ត្រូវស្លាប់ដោយត្រូវគ្រាប់ផ្លោងរបស់ពួកទាហាន លន់ ណុល ។ ម៉ាន ធ្លាប់ធ្វើជានិរសា តាណាត នៅមុនឆ្នាំ១៩៧៥ ហើយ តាណាត នោះជាប្រធានកងពលលេខ១១ (ក្រោយមកប្តូរឈ្មោះថាកងពល ៧០៣វិញ) ។ នៅមុនឆ្នាំ១៩៧៥ តាណាត និងនិរសាឈ្មោះ ម៉ាន ប្រចាំការនៅភូមិដីរស្លាប់ ឃុំស្អាងភ្នំ ស្រុកស្អាង ខេត្តកណ្ដាល ។

ម៉ាន មានឈ្មោះដើម «ស៊ឹម ម៉េល» អាយុ២២ឆ្នាំ (១៩៧៧) មានស្រុកកំណើត នៅភូមិបារ៉ែន ឃុំស្វាយប្រទាល ស្រុកស្អាង ខេត្តកណ្ដាល ។ ឪពុកឈ្មោះ សាស កើ ម្ដាយឈ្មោះ គះ និងមានប្អូន៧នាក់ ។ តាំងពីតូចមក ម៉ាន បានរៀនសូត្រខាងសាសនាឥស្លាមនៅក្នុងភូមិកំណើតនិងដើររៀនជាមួយតួន (គ្រូបង្រៀនសាសនាឥស្លាម) ល្បីនៅកម្ពុជា ។ ម៉ាន ទៅរៀននៅជ្រោយចង្វារភ្នំពេញ ភូមិដំនឹក ភូមិទ្រា ក្នុងស្រុកក្រូចឆ្មារ និងភូមិរកាពរប្រាំ ក្នុងស្រុកត្បូងឃ្មុំ ខេត្តកំពង់ចាម ។ ក្រោយពេលមានបាតុកម្មផ្តួលរំលំសម្ដេចសីហនុនៅឆ្នាំ១៩៧០ ម៉ាន ឈប់រៀនត្រឡប់មករស់នៅក្នុងភូមិកំណើតវិញ ។ មានសាក្សីម្នាក់ឈ្មោះ អេល ហ៊ីម ជាមិត្តភក្តិរបស់ ម៉ាន ធ្លាប់រៀនជាមួយគ្នាបាននិយាយថា ម៉ាន ចេះដឹងជ្រៅជ្រះផ្នែកសាសនាឥស្លាម ។ សព្វថ្ងៃ អេល ហ៊ីម រស់នៅភូមិចាមក្រោម ឃុំព្រែកថ្មី ស្រុកកោះធំ ខេត្តកណ្ដាល ជាតួន (គ្រូបង្រៀន) និងជាអ្នកដឹកនាំសាសនាក្នុងភូមិ ។

តាមធម៌វិន័យរបស់សាសនាឥស្លាម ដែលបានចែងនៅក្នុងគម្ពីរគួរអានត្រង់ចំណុច១២៦ ស៊ូរ៉ស់១៦ ចែងថា «ប្រសិនបើអ្នកដាក់ទណ្ឌកម្ម (សងសឹកសត្រូវរបស់អ្នក) ត្រូវដាក់ឲ្យស្មើនឹងទារុណកម្មដែលអ្នកបានទទួលរង ។ ប៉ុន្តែបើអ្នក (ភាគីជនរងគ្រោះ) អត់ធ្មត់នោះជាប្រការល្អប្រសើរ» ។

បើយោងតាមសាសនាព្រះពុទ្ធវិញមានលក្ខណៈខុសគ្នាពីសាសនាឥស្លាម ព្រោះព្រះពុទ្ធបានសម្ដែងថា «មនុស្សលោកត្រូវវៀរចាកនូវអំពើសម្លាប់ជីវិតអ្នកដទៃ មិនថាតែជីវិតមនុស្ស ឬសត្វ» ។ ក្នុងសេចក្ដីនេះ ទោះ ម៉ាន ជាឃាតករសម្លាប់មនុស្សក៏ដោយ ក៏ព្រះពុទ្ធមិនអនុញ្ញាតឲ្យមនុស្សលោកឬភាគីជនរងគ្រោះណាម្នាក់តបតឬសងសឹកចំពោះ ម៉ាន វិញឡើយ ហើយទុកឲ្យម៉ាន ទទួលខុសត្រូវចំពោះបាបកម្មដែលខ្លួនបានសាងទាំងប៉ុន្មានដោយខ្លួនឯង ។

នៅក្នុងមាត្រា២នៃ «អនុសញ្ញាស្ដីពីការបង្ការនិងផ្ដន្ទាទោសចំពោះបទឧក្រិដ្ឋនៃអំពើប្រល័យពូជសាសន៍» ដែលបានអនុម័តដោយមហាសន្និបាតអង្គការសហប្រជាជាតិនៅថ្ងៃទី៩ ខែធ្នូ ឆ្នាំ១៩៤៨ បានកំណត់និយមន័យនៃអំពើប្រល័យពូជសាសន៍ថាៈ «ប្រល័យពូជសាសន៍មានន័យថា អំពើណាមួយក្នុងចំណោមអំពើទាំងប៉ុន្មានខាងក្រោមនេះដែលត្រូវបានធ្វើឡើងក្នុងចេតនាបំផ្លាញទោះទាំងស្រុងក្ដី ឬក៏ផ្នែកខ្លះក្ដីដល់ប្រជាជាតិមួយ ជាតិពន្ធុមួយ សញ្ជាតិ ឬក្រុមសាសនាមួយ ដូចជាៈ ក) ការសម្លាប់សមាជិកទាំងឡាយនៅក្នុងក្រុម ។ ខ) បង្កការឈឺចាប់និងខូចខាតជាដំណំខាងផ្នែករាងកាយ ឬផ្នែកសតិបញ្ញាដល់សមាជិកទាំងឡាយនៅក្នុងក្រុម ។ គ) បង្កមហន្តរាយ ឬហិនហោចដល់ស្ថានភាពរស់នៅរបស់សង្គមមនុស្សដោយកម្មុចបំផ្លាញក្រុមទាំងមូលឬផ្នែកខ្លះៗនៃសង្គម ។ ឃ) ដាក់បង្ខំនូវវិធានការនានាដែលបង្ការមិនឲ្យមានកំណើតទារកនៅក្នុងសង្គម ។ ង) ការយកកុមារចេញពីសង្គមមួយទៅដាក់នៅក្នុងសង្គមមួយទៀតដោយបង្ខិតបង្ខំ» ។

អំពើរបស់ ម៉ាន ដែលជាជនជាតិភាគតិចហើយដែលបានប្រព្រឹត្តអំពើកាប់សម្លាប់ទៅលើជនជាតិភាគតិច និងភាគច្រើនដទៃទៀត តើនឹងត្រូវរាប់បញ្ចូលទៅក្នុងបទឧក្រិដ្ឋអ្វីនៅក្រោមបទដ្ឋាននៃច្បាប់អន្តរជាតិ? តើជាអំពើប្រល័យពូជសាសន៍រវាងជនជាតិភាគតិចនិងជនជាតិភាគតិច ឬក៏ជាអំពើឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិរវាងជនជាតិភាគតិចនិងជនជាតិភាគច្រើន?

**អ៊ីសា ឧស្មាន**

# យុវ័នស្នេហាជាតិ



យុវ័នស្នេហាជាតិជាកម្លាំងពិសេសរបស់អង្គការចាត់តាំងខ្មែរក្រហមដែលបានបង្កើតឡើងដើម្បីយាមកាមផែកឆេរនៅតាមផ្លូវក្នុងភូមិនិងតម្រូវការចាំបាច់ផ្នែកយោធា ។

ឯកសារលេខ N៥២៨៩ ឈ្មោះ សុខ សាខុន មានអាយុ ២០ឆ្នាំ (ឆ្នាំ១៩៧៣) ស្រុកកំណើតនៅភូមិព្រៃឈើទាល ឃុំស្វាយតាសាន ស្រុកស្វាយទាប ខេត្តស្វាយរៀង ដែលបានរត់ចេញពីតំបន់រំដោះ (គ្រប់គ្រងដោយរបបខ្មែរក្រហម) ទៅរួមរស់ជាមួយនឹងរបបសាធារណរដ្ឋខ្មែរ (ក្រោមការគ្រប់គ្រងរបស់លន់ ណុល) នៅថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ១៩៧៣ ក្នុងខណៈដែលខ្លួនត្រូវបានប្រធានភូមិជ្រើសរើសបញ្ចូលទៅក្នុងកងទ័ពតំបន់ ។ សាខុន បានសារភាពចំពោះយោធាយោធភូមិភាគទី៦ ផ្នែកសឹករង ស្វាយរៀងថា៖ «ខ្ញុំបានរៀនដល់ត្រឹមថ្នាក់ទី៨ នៅសាលាបឋមសិក្សាវត្តរំដួល ។ក្រោយមកខ្ញុំត្រូវបានប្រធានភូមិព្រៃឈើទាល ជ្រើសរើសឲ្យធ្វើជាបុគ្គលិកយុវ័នស្នេហាជាតិប្រចាំភូមិ ។»

ឯកសារលេខ N៥២៨ ឈ្មោះ រ័ត្ន វាសនា ហៅ ផ្លូន អាយុ២១ឆ្នាំ (ឆ្នាំ១៩៧៣) បម្រើការក្នុងកងឯកភាពយុវ័នភូមិនាទីជាអ្នកយាមផ្លូវ រស់នៅក្នុងភូមិព្រៃរំដួល សង្កាត់ប្រសូត្រ ស្រុកកំពង់រោទិ៍ ខេត្តស្វាយរៀង បានសរសេរថា៖ អង្គការយុវ័នស្នេហាជាតិត្រូវបានអង្គការចាត់តាំងខ្មែរកុម្មុយនិស្តបង្កើតឡើងនាដើមឆ្នាំ១៩៧២ នៅភូមិព្រៃឈើទាល ឃុំស្វាយតាសាន ស្រុកស្វាយទាប ខេត្តស្វាយរៀង មានបុគ្គលិក៣០នាក់នៅក្រោមបញ្ជាការឈ្មោះ គង់ ពុត ជាប្រធាន ម៉ៅ សុត ជាអនុប្រធាន និង សារ៉េត ជាទីស្តីការ ។

សុខ សាខុន បាននិយាយថា ចាប់តាំងពីឆ្នាំ១៩៧៣មក អង្គការយុវ័នស្នេហាជាតិក្នុងភូមិនេះនៅតែជ្រើសរើសបន្ថែមទៀតចំពោះយុវ័ននៅក្នុងភូមិចាប់ពីអាយុ១៦ឆ្នាំឡើងទៅនិងនៅលីវទាំងអស់ ។ ប្រសិនបើយុវ័នណាម្នាក់មានប្រពន្ធ ត្រូវបញ្ចូលក្នុងកងសេនាជនវិញ ។

ឯកសារលេខ N៥២៨៧ ឈ្មោះ ព្រុំ ពិសី ហៅ ព្រុំ វណ្ណថន អាយុ២០ឆ្នាំ (ឆ្នាំ១៩៧៣) ដែលរស់នៅក្នុងភូមិស្រុកជាមួយ រ័ត្ន វាសនា បានសរសេរថាអង្គការយុវ័នស្នេហាជាតិនេះខ្មែរកុម្មុយនិស្តគ្រាន់តែកត់ឈ្មោះតែងតាំងជាយុវ័នភូមិនិងចាត់

ឲ្យធ្វើការប៉ុណ្ណោះ ដោយមិនបានហាត់ហ្វឹកហ្វឺនក្បួនយុទ្ធសាស្ត្រអ្វីទាំងអស់មានតែ គង់ ពុត ប្រធានក្រុមយុវ័នម្នាក់ប៉ុណ្ណោះដែលបានទទួលការអប់រំពីអង្គការថ្នាក់លើ ។ យុវ័នស្នេហាជាតិធ្វើការតែក្នុងភូមិរបស់ខ្លួនមិនដែលចេញទៅធ្វើការនៅកន្លែងដទៃក្រៅពីភូមិទេ ។ សាខុន សរសេរបន្ថែមថាៈ “តាំងពីខ្ញុំបានធ្វើជាយុវ័នប្រចាំភូមិព្រៃឈើទាលប្រហែល៧ខែមក ខ្ញុំពុំដែលឃើញអង្គការផ្តល់ឬផ្គត់ផ្គង់អ្វីដល់ក្រុមខ្ញុំឡើយ មានតែទារពីក្រុមខ្ញុំរាល់ខែក្នុងម្នាក់២រៀល ។ អង្គការយុវ័នស្នេហាជាតិមានមុខងារយាមកាមឆែកឆេរលិខិតស្នាមពីប្រជាជនដែលធ្វើដំណើរឆ្លងកាត់ពីភូមិមួយទៅភូមិមួយដោយធ្វើសហប្រតិបត្តិការជាមួយឈ្លបឃុំ និងនារីស្នេហាជាតិនៅក្នុងភូមិ ។ ម្យ៉ាងទៀត យុវ័នភូមិមានភារកិច្ចត្រួតពិនិត្យមើលការនាំចេញនាំចូលនូវគ្រឿងឧបភោគនិងឥវ៉ាន់ផ្សេងៗដែលគ្មានលិខិតអនុញ្ញាត ដោយចាប់បញ្ជូនទៅឲ្យប្រធានរបស់ខ្លួន ។ ប្រធានយុវ័នបានបែងចែកវេនយាមក្នុងមួយថ្ងៃមានយុវ័នស្នេហាជាតិ២នាក់ នារីស្នេហាជាតិ៣នាក់ ដោយធ្វើការពីម៉ោង៧ព្រឹករហូតដល់ម៉ោង៥ល្ងាចជារៀងរាល់ថ្ងៃនិងផ្លាស់វេនគ្នាជម្មតា ។ ក្នុងពេលយាមកាម ក្រុមយុវ័នភូមិមិនប្រើប្រាស់កាំភ្លើងទេ មានតែកាំបិតពូថៅប៉ុណ្ណោះ ។ ប្រសិនបើមានហេតុភេទចម្លែកនៅក្នុងភូមិរបស់ខ្លួនប្រធានយុវ័នត្រូវតែធ្វើសេចក្តីរាយការណ៍ដោយផ្ទាល់មាត់ដល់ប្រធានភូមិឲ្យបានដឹងភ្លាមៗ ។ ប្រធានភូមិត្រូវតែរាយការណ៍ជាបន្តទៅប្រធានសង្កាត់ទៀត ។ នៅទីនោះប្រធានសង្កាត់សម្រេចអនុម័តផ្សះផ្សារកខុសត្រូវ ។ ប្រសិនការណ៍នោះមិនសម្រេចត្រឹមនេះទេ ប្រធានសង្កាត់ត្រូវរាយការណ៍ឡើងទៅអង្គការថ្នាក់លើជាបន្ទាន់ ។ ក្រោយពេលបញ្ចប់ភារកិច្ចហើយ ក្រុមយុវ័ន និងនារីស្នេហាជាតិត្រឡប់ទៅផ្ទះសម្បែងរៀងៗខ្លួន លុះដល់វេនទើបមកយាមវិញទៀត ។

ព្រុំ វណ្ណថន បានសរសេររៀបរាប់ថា ក្រៅពីសកម្មភាពយាមការពារភូមិ ក្រុមយុវ័នស្នេហាជាតិមានភារៈចម្បងពីរទៀត គឺបង្កបង្កើនផលនិងត្រៀមខ្លួនចាំសែងអ្នករបួស ។ ការបង្កបង្កើនផលដាំដំណាំផ្សេងៗធ្វើរួមទាំងអស់គ្នា រួចបញ្ជូនផលដំណាំទាំងអស់នេះផ្តល់ទៅឲ្យកងទ័ពក្នុងសមរភូមិនានា ។ ពេលមានសង្គ្រាមកើតឡើង យុវ័នស្នេហាជាតិមានភារកិច្ចដឹកជញ្ជូនស្បៀងឲ្យកងទ័ពពីសមរភូមិក្រោយទៅសមរភូមិមុខនិងសែងអ្នករបួសពីសមរភូមិមុខមកសមរភូមិក្រោយវិញឬគ្រាន់តែសែងចម្លងឲ្យផុតភូមិរបស់ខ្លួនចូលទៅក្នុងភូមិដទៃទៀតប៉ុណ្ណោះ ។ អង្គការយុវ័នស្នេហាជាតិនេះបានធ្វើការប្រជុំគ្នារៀងរាល់ថ្ងៃអាទិត្យដោយធ្វើរួមជាមួយនារីភូមិក្រោមអធិបតីភាពប្រធានយុវ័ននិងប្រធាននារីដើម្បីរិះគន់នូវកំហុសទាំងឡាយដែលអ្នកណាមាន ហើយនាំគ្នាកសាងគ្នាឡើងវិញនៅចំពោះមុខអង្គប្រជុំ ។ ប្រសិនបើអ្នកណាមានកំហុសមិនអាចកសាងបានប្រធានអង្គប្រជុំត្រូវរាយការណ៍ទៅប្រធានភូមិជាបន្ទាន់ ។ ទីកន្លែងប្រជុំវិញមិនពិតប្រាកដទេ ច្រើនធ្វើឡើងនៅផ្ទះអ្នកស្រុក ។ អង្គការយុវ័នស្នេហាជាតិមិនត្រឹមតែមានតួនាទីយាមកាមភូមិបង្កបង្កើនផលនិងដឹកជញ្ជូនស្បៀងឬសែងអ្នករបួសប៉ុណ្ណោះទេ ថែមទាំងត្រូវបានគណៈស្រុកជ្រើសរើសចូលក្នុងកងទ័ពទៀតផង ។

ព្រុំ វណ្ណថន បានបន្ថែមថា មុននឹងធ្វើការជ្រើសរើសកងទ័ព ឈ្មោះ សាផន គណៈស្រុកកំពង់រោទិ៍ ពុំបានធ្វើការទាក់ទងនឹងប្រជាជនទេ គឺធ្វើការទាក់ទងនឹងប្រធានភូមិជាមុន ។ ពេលនោះប្រធានភូមិកោះហៅប្រជាជនព្រមទាំងយុវ័នភូមិដោយធ្វើការឃោសនាជ្រើសរើសរកយុវ័ននិងប្រជាជនដែលស្ម័គ្រចិត្តចូលបម្រើជាកងទ័ពតំបន់ ។ ការជ្រើសរើសកងទ័ពត្រូវបានធ្វើឡើងក្នុងរយៈពេលមួយថ្ងៃក្នុងភូមិនីមួយៗ ។ អ្នកដែលត្រូវបានជ្រើសរើសឲ្យចូលបម្រើក្នុងកងទ័ពភាគច្រើនជាយុវ័នភូមិ ក្រៅពីនេះជាប្រជាជនស្ម័គ្រចិត្ត (អ្នកស្ម័គ្រចិត្តនេះមិនថាមានមុខរបររួចហើយជាគ្រូបង្រៀនក្មេង ឬជាប្រជាជនក្រីក្រ ត្រូវបានជ្រើសរើសបញ្ជូនទៅជាកងទ័ពទាំងអស់) ។ នៅក្នុងខែមិថុនា ឆ្នាំ១៩៧៣ អង្គការជ្រើសរើសទាហានបានចំនួនជាង២០០នាក់ ដើម្បីចូលជាកងទ័ពភូមិភាគ២០៣ ។

នៅសេចក្តីបញ្ចប់នៃចម្លើយសារភាព ព្រុំ វណ្ណថន បានសរសេរថាៈ ក្រៅពីការជ្រើសរើសឲ្យចូលធ្វើជាកងទ័ព យុវ័នភូមិមួយចំនួនក៏ត្រូវបានជ្រើសរើសឲ្យចូលបម្រើជាឈ្លបឃុំទៀតផង ។ ការជ្រើសរើសទាំងនេះមានយុវ័ននិងក្រុមគ្រួសារយុវ័នមួយចំនួនមានការមិនពេញចិត្ត ថែមទាំងខ្លះបានបញ្ចេញយោបល់ជំទាស់ ប៉ុន្តែត្រូវអង្គការចាប់ខ្លួនយកទៅអប់រំគ្មានត្រាប្រណី ។ **ហ៊ុយ វណ្ណៈ**

**(តពីលេខមុន)** នៅក្នុងប្រទេសកម្ពុជា យុទ្ធនាការមនុស្សឃាតនៅខែមិថុនា ឆ្នាំ១៩៧៥ ត្រូវបានកាត់បន្ថយដោយមជ្ឈិមបក្ស ។ បន្តិចក្រោយមកដំណើរការតាមលិខិតស្នាមដែលគ្រប់គ្រងដោយសន្តិបាលទាក់ទងនឹងចំណាត់ការប្រឆាំងនឹង «ខ្មាំង» ត្រូវបានអនុវត្តខ្លាំងឡើងៗជាលំដាប់ ។ ចាប់ពីខែតុលា ឆ្នាំ១៩៧៥ ជនដែលត្រូវបានសង្ស័យថាប្រឆាំងនឹងបដិវត្តន៍លែងត្រូវបានសម្លាប់ភ្លាមៗទៀតហើយ ប៉ុន្តែបែរជាត្រូវយកមកសួរចម្លើយនិងតម្រូវឲ្យសរសេរចម្លើយសារភាពរបស់ខ្លួនសិនទើបចាត់ការតាមក្រោយ ។ អ្នកទោសទាំងអស់រួមទាំងមន្ត្រីរបបលន់ ណុល ជនជាតិខ្មែរដែលបានសិក្សានៅបរទេស អ្នករត់ចោលជួរ មនុស្សដែលមានពុតត្បុត ជនជាតិខ្មែរដែលមានទំនាក់ទំនងខ្សែរយៈជាមួយរបបធីវគីនៅក្នុងក្រុងសៃហ្គន និងប្រជាជនដែលហៅថាខ្មែរហាណូយ ដែលមជ្ឈិមបក្សមានការសង្ស័យ និងត្រូវបានបោសសម្អាតដោយបក្សកុម្មុយនិស្តកម្ពុជាតាំងពីឆ្នាំ១៩៧២មក ។




## សម្លេងពីមន្ទីរ ស-២១

**វគ្គទី៣: ការជ្រើសរើសសត្រូវ**

**ដោយសាស្ត្រាចារ្យ ដេវីដ ឆេនដល័រ**

នៅក្នុងឆ្នាំ១៩៧៦ ពេលដែលវិសុទ្ធកម្មឡើងខ្លាំងដល់កម្រិតកំពូលហើយនោះ ខ្មែរក្រហមបានប្រឹងប្រែងយ៉ាងខ្លាំងក្នុងការពង្រីកអំណាចរបស់ខ្លួននៅក្នុងប្រទេស និងកសាងកិត្តិស័ព្ទរបស់ខ្លួននៅលើឆាកអន្តរជាតិ ។ នៅខែមករា រដ្ឋធម្មនុញ្ញរបស់កម្ពុជាប្រជាធិបតេយ្យត្រូវបានផ្សព្វផ្សាយជាសាធារណៈ ។ នៅខែមេសា ការបោះឆ្នោតមួយត្រូវបានរៀបចំឡើង រដ្ឋាភិបាលកណ្តាលក៏ត្រូវបានបង្កើត ហើយវិធានការផ្សេងៗក៏ត្រូវបានធ្វើឡើងដើម្បីបង្កើតកងទ័ពជាតិ ។ វិទ្យុភ្នំពេញបានប្រកាសថា «កម្មកររោងចក្រចម្ការកៅស៊ូ» ឈ្មោះ ប៉ុល ពត ដែលគ្មាននរណាម្នាក់ស្គាល់ឈ្មោះក្រៅពីបក្សនោះគឺជានាយករដ្ឋមន្ត្រីថ្មី ។ នៅខែឧសភា សន្តិបាលបានផ្ទេរប្រតិបត្តិការរបស់ខ្លួនមកទួលស្លែងវិញ ។ មិនបានយូរប៉ុន្មានផង រលកវិសុទ្ធកម្មលើកទីពីរក៏ចាប់ផ្តើម ។

ដោយសារតែទួលស្លែងជាគុកនយោបាយធំនៅក្នុងទីក្រុងភ្នំពេញ ប្រភេទជនរងគ្រោះដែលរៀបរាប់ខាងលើត្រូវបានបន្តនាំចូលក្នុងគុកនេះដើម្បីសួរចម្លើយ និងសម្លាប់ ប៉ុន្តែបើតាមអាលីហ្សាបែ៊ត បេកឃ័រ និយាយថា «ឥឡូវនេះបក្សបានប្តូរពីការកម្ទេចពួកគហបតីមកកម្ទេចពួកនិន្នាការគហបតីនៅក្នុងបក្សវិញ ។ ការផ្លាស់ប្តូរនេះបាននាំឲ្យមានរបបមួយដែលពោរពេញដោយក្តីវន្ទត់ ដែលបន្តរហូតដល់ពេលដួលរលំនៃរបបកម្ពុជាប្រជាធិបតេយ្យ» ។ ដូច ហាណាស អារ៉េន បានបញ្ចេញទស្សនៈរបស់គាត់ថា «ទើបតែក្រោយពេលដែលខ្មាំងពិតៗត្រូវបានកម្ទេចអស់និងមានការចាប់ផ្តើមស៊ើបរកមុខសញ្ញាខ្មាំង ទើបគ្រប់គ្នាដឹងថាមានរបបផ្តាច់ការមែន» ។

### រលកវិសុទ្ធកម្មលើកទី២

ការតាមរកខ្មាំងត្រូវបានបង្កើនល្បឿនតាមរយៈព្រឹត្តិការណ៍ពីរដែលធ្វើឲ្យរំជួលនិងមានអាថ៌កំបាំងដែលមិនអាចពន្យល់បាន ។ នៅថ្ងៃទី២៥ ខែតុលា ឆ្នាំ១៩៧៦ មានការផ្ទុះអាវុធមួយនៅទីក្រុងសៀមរាប ស្របពេលដែលប្រជាជនមើលឃើញយន្តហោះរបស់បរទេសដែលកំពុងតែហោះហើរ ។ នៅដើមខែមេសា ការផ្ទុះដោយចៃដន្យមួយនៅក្នុងក្រុងភ្នំពេញនោះ ចំពោះប៉ុល ពត ព្រមទាំងអ្នកដែលធ្វើការនៅកៀកខ្លួនហាក់បីដូចជាគិតថាវាជាការផ្ទុះចេញដ៏ពេញទំហឹងមួយនៃរដ្ឋប្រហារ ។ ពិតណាស់ព្រឹត្តិការណ៍ដែលកើតឡើងពីរលើកនេះនៅតែមិនមានលក្ខណៈច្បាស់លាស់នៅឡើយ ។

ជាទូទៅរបបកម្ពុជាប្រជាធិបតេយ្យបានដាក់កំហុសការផ្ទុះនោះទៅលើ«ភ្នាក់ងារសេ.អ៊ី.អា» ដែលការចោទនោះធ្វើឡើងនៅចុងឆ្នាំ១៩៧៨ ហើយចោទថាការផ្ទុះទៅលើកងទ័ពកម្ពុជា

ប្រជាធិបតេយ្យនៅក្នុងទីក្រុងជាសកម្មភាពរបស់វៀតណាម ។ ថ្នាក់ដឹកនាំបក្សបានសង្ស័យថា កុយ ធួន ហៅ ឃួន លេខាភូមិភាគឧត្តមានការពាក់ព័ន្ធក្នុងរឿងផ្ទុះនៅខេត្តសៀមរាប ។ ថ្នាក់ដឹកនាំបក្សក៏មានការសង្ស័យចំពោះលេខាភូមិភាគបូព៌ាដែលជាទាហានដើងចាស់ឈ្មោះ សោ ភឹម ហៅ សុវណ្ណ ថាជាអ្នកនាំបង្កការផ្ទុះគ្រាប់នៅក្នុងរាជធានី ។ ជនទាំងពីរនាក់នេះនៅតែទទួលភារកិច្ចដដែលទោះជាមួយរយៈពេលខ្លីក្រោយពីការផ្ទុះ កុយ ធួន ត្រូវបានកោះហៅទៅភ្នំពេញដើម្បីមើលការខុសត្រូវចំពោះពាណិជ្ជកម្មជាមួយបរទេស និងសួរចម្លើយអំពីកំហុសសីលធម៌ក៏ដោយ ។ នៅថ្ងៃទី៨ ខែមេសា ឆ្នាំ១៩៧៦ ជិតមួយសប្តាហ៍ក្រោយពីការផ្ទុះនៅក្នុងភ្នំពេញ កុយ ធួន ត្រូវបានយកមកឃុំខ្លួនក្នុងគុកនៅក្នុងសាលាពិសេសជិតព្រះបរមរាជវាំង ស្ថិតនៅមិនឆ្ងាយប៉ុន្មានពីអគារដែលមានឆ្មាំយ៉ាងកកកុញការពារ «បងធំៗ» ស្នាក់នៅ ។ នៅក្នុងខែឧសភានិងខែមិថុនារលកវិសុទ្ធកម្មទីពីរបានចាប់ផ្តើមឡើងដូចការគ្រោងទុក ។

ក្នុងការបង្ហាញពីលំដាប់លំដោយនៃការធ្វើវិសុទ្ធកម្មទាំងនេះដោយប្រើទិន្នន័យយកមកពីចម្លើយសារភាពធ្វើឡើងជាបន្តបន្ទាប់ ខ្ញុំមិនបានកាន់ជំហរថាតើចម្លើយសារភាពនោះមានការពិតឬទេ ឬថាអ្នកទោសមានកំហុសឬអត់យ៉ាងណានោះទេ ។ ដោយសារតែការសម្រេចចិត្តទាំងនេះអាចធ្វើឲ្យមេដឹកនាំដែលស្វែងរកប្រវត្តិគួរឲ្យទុកចិត្តបាននៃអ្នកដែលប្រឆាំងនឹងកម្ពុជាប្រជាធិបតេយ្យមានការខកចិត្តនោះ ខ្ញុំត្រូវតែបង្ហាញនូវហេតុផលរបស់ខ្ញុំ ។

ហេតុផលទី១ ដោយគ្មានការបញ្ជាក់អះអាងពីប្រភពផ្សេងៗ មាន «ការពិត» តិចតួចណាស់នៅក្នុងចម្លើយសារភាពលើកលែងតែប្រវត្តិរូបផ្ទាល់ខ្លួនដែលអាចយកធ្វើជាការពិតបាន ។ យើងមិនអាចសម្រេចឡើយថាតើអ្នកទោសសារភាពពីការពិតក្រោមការធ្វើទារុណកម្ម និយាយអ្វីដែលអ្នកសួរចម្លើយឲ្យនិយាយ និយាយអ្វីដែលអ្នកសួរចម្លើយចង់ស្តាប់ ឬប្រឌិតការពិតពាក់កណ្តាល កុហកពាក់កណ្តាលលាយជាមួយគំនិតស្រមើស្រមៃពាក់កណ្តាល ឬយ៉ាងណានោះទេ ។ ប៉ុន្តែទោះជាយ៉ាងនេះក្តីក៏យើងនៅតែអាចសន្និដ្ឋានបានមិនត្រឹមតែថាភាគច្រើន




នៃចម្លើយសារភាពរបស់អ្នកទោសគឺសុទ្ធតែប្រឌិតឡើងឲ្យសមតាមអ្វីដែលថ្នាក់ដឹកនាំនៅមន្ទីរសន្តិសុខ ស-២១ យល់ថាសមរម្យតាមការចង់បានរបស់មជ្ឈិមបក្សប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងថាការនិយាយរឿងជាខ្សែសង្វាក់និងការសន្ទនាដោយអំពើគ្រេវគ្រោធ ជួនកាលត្រូវបានផ្សំធ្វើជាចម្លើយសារភាពទៀតផង ។

ហេតុផលទី២ គឺមានឯកសារតិចតួចណាស់ដែលនៅសេសសល់ស្តីអំពីការសម្រេចចិត្តធ្វើឡើងដោយមជ្ឈិមបក្សទាក់ទងនឹង«ខ្មាំង» ។ យើងគ្រាន់តែដឹងថាដៃដើងរបស់អ្នកទោសត្រូវបានតាមដានចាប់ខ្លួនរួចហើយនិងបានប្រព្រឹត្តកំហុសឆ្គងផ្សេងៗព្រមទាំងស្ថិតនៅក្រោមការសង្ស័យ ប៉ុន្តែយើងពិបាកកំណត់បានថាហេតុអ្វីបានជាអ្នកទោសត្រូវបានចាប់ខ្លួន ។ ចំពោះអ្នកទោសថ្នាក់ទាប ទំហំនៃ «បទឧក្រិដ្ឋ» គឺដូចៗគ្នា ទៅនឹងបក្ខពួកដែលត្រូវបានសេពគប់ ។ ផ្ទុយមកវិញអ្នកទោសដែលមាន

ឋានៈខ្ពស់ៗត្រូវបានបង្ខំឲ្យឆ្លើយថាបានរៀបចំផែនការ ផ្តួលរំលំ ឬធ្វើវិទ្ធង្សនាប្រឆាំងនឹងបដិវត្តន៍ ដោយបង្កើតជាបក្សប្រឆាំង ប៉ុនប៉ងធ្វើឃាតថ្នាក់ដឹកនាំ ឬដោយរិះគន់នយោបាយរបស់មជ្ឈិមបក្ស ។ ពិបាកកំណត់ណាស់ថាតើការសមគំនិតពិតជាមានលក្ខណៈច្បាស់លាស់មែន ឬអ្នកសមគំនិតពិតជាត្រូវបានចុចឈ្មោះពិតប្រាកដមែនដែរឬអត់ ។

ទោះបីជាគ្មានតុលាការឬ ចៅក្រមក្នុងរបបកម្ពុជាប្រជាធិបតេយ្យក៏ដោយ តែការកាត់ទោសត្រូវផ្អែកលើចម្លើយសារភាពសង្ខេបៗ ។ ច្បាស់ជាងនេះទៀត ផ្អែកលើប្រភេទភ័ស្តុតាងប្រមូលឲ្យចៅក្រមត្រួតពិនិត្យតាមប្រព័ន្ធយុត្តិធម៌ប្រទេសបារាំងដែលត្រូវបានអនុវត្តនៅក្នុងប្រទេសកម្ពុជា ។ ចម្លើយសារភាពត្រូវបានរៀបចំនៅមន្ទីរសន្តិសុខស-២១ ជូន «ចៅក្រម» មជ្ឈិមបក្សដែលគ្មានអ្នកណាស្គាល់មុខ ។ ដោយសារតែភាពមិនចេះខុសដែលអះអាងដោយមជ្ឈិមបក្សនិងភាពសម្ងាត់នៅជុំវិញមន្ទីរសន្តិសុខស-២១ លទ្ធភាពនៃកំហុសភាពគ្មានទោសនិងការដោះលែង គឺមិនត្រូវបានរាប់បញ្ចូលឡើយ ។

លើសពីនេះទៀត ការប្រើពាក្យ «មានទោស» ឬ «មិនមានទោស» ចំពោះអ្នកទោសនៅមន្ទីរស-២១ គឺមិនត្រឹមត្រូវឡើយ ។ ការប្រើពាក្យទាំងនេះផ្តល់នូវភាពស្របច្បាប់នៃប្រព័ន្ធយុត្តិធម៌មួយចំពោះគម្រោងការដ៏គួរឲ្យស្អប់ខ្ពើមដែលតាមរយៈគម្រោងនេះ អ្នកទោសទាំងអស់ទោះបីជាបានប្រព្រឹត្តអ្វីក៏ដោយ ហើយមុនពេលដែលខ្លួនរៀបនិយាយត្រូវបានផ្តន្ទាទោសដល់ជីវិតរួចស្រេច ។ ដំណើរការធ្វើឡើងនៅមន្ទីរសន្តិសុខស-២១ ពេលខ្លះហាក់ដូចជាមានលក្ខណៈដូចគ្នានឹងដំណើរការរបស់ វ៉េតឃ្វីន រដ្ឋអាលីសនៃប្រទេសវនដ័រលែន និងការជំនុំជម្រះក្តីរបស់កាហ្វកា ។ មយ៉ាងទៀតអ្នកដែលមាន«កំហុស» ច្បាស់ក្រឡែតប្រឆាំងនឹងកម្ពុជាប្រជាធិបតេយ្យអាចសមតែ(បើផ្អែកការយល់ឃើញពីខាងក្រោយ)ជាវីរបុរសពិតៗ ចំណែកឯជនរងគ្រោះដែលជា«ជនស្លូតត្រង់គ្មានកំហុស»ប្រឆាំង ហើយសមគំនិតជាមួយនឹងមាគ៌ាដឹកនាំ និងការអនុវត្តជាក់ស្តែងមិនគួរចាំបាច់ត្រូវបានផ្តល់កិត្តិយសថាជាពលរដ្ឋគោរពច្បាប់ដោយរបបមួយដែលធ្វើការបោសសម្អាតទាំងកំហុសតាមរយៈប្រព័ន្ធតុលាការឡើយ ។ នៅក្នុងពិភព ពេញដោយការជ្រួលច្របល់នៃរបបកម្ពុជាប្រជាធិបតេយ្យ ក៏ដូចជាបដិវត្តន៍បារាំងនិងប្រទេសអឺរ៉ុបដែលត្រូវបានកាន់កាប់កាលពីសង្គ្រាមលោកលើកទី២ដូច្នោះដែរ ភាពមានទោសនិងភាពគ្មានទោសតែងតែទទួលឥទ្ធិពលដោយសារការឡើងចុះពីអំណាចរបស់ថ្នាក់ដឹកនាំ ។

ការឆ្លើយតបរបស់ប្រជាជនបារាំងចំពោះការកាន់កាប់របស់ជនជាតិអាល្លឺម៉ង់ក្នុងសង្គ្រាមលោកលើកទី២បង្ហាញពីការប្រៀបធៀបយ៉ាងមានប្រយោជន៍ទៅនឹងព្រឹត្តិការណ៍ដែលបានកើតឡើងនៅក្នុងប្រទេសកម្ពុជា ដោយពាក្យផ្សេងៗគ្នាដូចជា «អាត្មានិយម» «ជាតិនិយម» និង «ការក្បត់» ដែលអំពើទាំងនេះអាស្រ័យថាតើអ្នកណាខ្លះធ្វើបដិវត្តន៍ ហើយនៅកន្លែងណាពេលណា និងដល់កម្រិតណា ។ បើធ្វើការប្រៀបធៀបឲ្យជ្រៅជាងនេះទៀត គឺឃើញថាព្រឹត្តិការណ៍ទាំងនេះបានកើតឡើងចំពោះកម្មាភិបាលបក្សកុម្មុយនិស្តកម្ពុជាក្រោយឆ្នាំ១៩៧៧ ឬក៏មុននេះដែលដឹកនាំគាំទ្រដោយបរទេស (វៀតណាម) ឬក៏បដិវត្តន៍របៀបវៀតណាមនាំឲ្យមានការលួចឆក់ភាពរាលដាលនៃភាពទុរ្ភិក្ស និងអំពើឃោរឃៅមិនរើសមុខ និងគ្មានព្រំដែននៃកម្ពុជាប្រជាធិបតេយ្យ ។ នៅត្រឹមឆ្នាំ១៩៧៨ មានប្រជាជន







កម្ពុជារាប់ពាន់នាក់បានបន្ថយនូវការបាត់បង់របស់ខ្លួនត្រូវបានដាក់ឲ្យស្ថិតនៅក្រោមអំណាចរបស់វៀតណាមនិងលទ្ធភាពនៃការគ្រប់គ្រងថ្មី ។ តាំងពីដើមមកហាក់ដូចគ្មាននរណាម្នាក់យល់ថាកម្ពុជាប្រជាធិបតេយ្យមានការដឹកនាំគម្រក់ឡើយ ។ ករណីប្រហាក់ប្រហែលនេះដែរ មានពលរដ្ឋបារាំងតិចណាស់ដែលបានប្រឆាំងនឹងប៉ើតាំង (ក្រុម) ក្នុងឆ្នាំ១៩៤០ ប៉ុន្តែក្រោយមកដល់ឆ្នាំ១៩៤៣ ពលរដ្ឋបារាំងជាច្រើនបែរជាធ្វើការប្រឆាំងនឹងប៉ើតាំង (ក្រុម) ទៅវិញ ។ ប៉ុន្តែនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យនាឆ្នាំ១៩៧៧ និងឆ្នាំ១៩៧៨ អ្នកចុះចូលរបស់របបកម្ពុជាប្រជាធិបតេយ្យត្រូវដាក់ទោសដោយរដ្ឋាភិបាលដែលយល់ថាអ្នកទាំងនោះបានរត់ចូលមកខាងឈ្នះវិញ ។

ការធ្វើវិសុទ្ធកម្មនៅក្នុងភូមិភាគបូព៌ានៃប្រទេសកម្ពុជាក្នុងឆ្នាំ១៩៧៨ ក្នុងគោលបំណងបំបាត់ការប្រឆាំងតវ៉ានិងទប់ស្កាត់កុំឲ្យប្រជាជនរត់ទៅប្រទេសវៀតណាមកាន់តែច្រើនទៅៗនោះ បានបង្កឲ្យមានផលប៉ះពាល់ដោយមិនដឹងខ្លួនដល់ការប្រឆាំងរបស់អ្នកដែលនៅរស់រានមានជីវិត ។ អ្នកដែលបានរួចផុតពីការធ្វើវិសុទ្ធកម្មដូចជាមេដឹកនាំសំខាន់ៗ ហេង សំរិន ជា ស៊ីម និង ស ខេង ក៏បានចូលរួមជាមួយ «ខ្មែរហាណូយ» ដែលរួចខ្លួន និងអ្នកចុះចូលតាំងពីមុនមួយចំនួនទៀត ដើម្បីបង្កើតជារបបមួយចាប់ផ្តើមគ្រប់គ្រងប្រទេស ក្រោយពីមានការឈ្លានពានលុកលុយរបស់វៀតណាម ។

ហេតុផលចុងក្រោយគឺថាអំពើឃោរឃៅគួរឲ្យភ្ញាក់ផ្អើលនៃរបបកម្ពុជាប្រជាធិបតេយ្យប្រឆាំងនឹងប្រជាជនខ្លួនឯងដែលត្រូវបានចងក្រងនៅបណ្ណសារដ្ឋានរបស់មន្ទីរសន្តិសុខ ស-២១ បានរួមបញ្ចូលលទ្ធភាពដែលថា ប៉ុល ពត និងដៃដើងរបស់ខ្លួនក្នុងករណីណាមួយនោះមានភ័ស្តុតាងបញ្ជាក់អំពីការសមគំនិតផ្តួលរំលំរបបខ្លួនដឹកនាំ ។ ដូច ស៊ីវ ហេង៉រ មានប្រសាសន៍យ៉ាងដូច្នោះដែរថា មានចម្លើយសារភាពច្រើនណាស់ដែលមានបញ្ជាក់ត្រង់ចំណុចនេះ ទោះបីជាគ្មានការអះអាងថាវាពិតក៏ដោយ ហើយវាជាការខុសឆ្គងមួយក្នុងការចាត់ទុកអ្នកទាំងអស់នៅមន្ទីរស-២១ សុទ្ធតែជា «ជនគ្មានកំហុស» មិនពាក់ព័ន្ធក្នុងការរួមគំនិត ពីព្រោះចម្លើយសារភាពរបស់ខ្លួននិយាយអ្វីដែលមិនសមហេតុផលដោយសារតែរបបដែលខ្លួនរស់នៅនោះវាអាក្រក់ ឬដោយសារតែអ្នកទោសទាំងនោះត្រូវបានធ្វើទុកបុកម្នេញយ៉ាងឃោរឃៅព្រៃផ្សៃ ។

## មូលហេតុដែលនាំឲ្យមានបណ្ណសារ

ដោយទុកនូវសំណួរស្តីអំពីយុត្តិធម៌ ការពិតភាពគ្មានទោស និងភាពមានទោសដោយឡែក យើងចាំបាច់ត្រូវសួរថាហេតុអ្វីបានជាបណ្ណសារមន្ទីរ ស-២១ មានឯកសារសន្ទឹកសន្ធាប់ម្ល៉េះ ហើយហេតុអ្វីបានជាបណ្ណសារនេះត្រូវបានថែរក្សាទុកបើឯកសារសុទ្ធតែជាឯកសារសម្ងាត់ ភាគច្រើនសុទ្ធតែមិនពិត ហើយអ្នកទោសទាំងអស់ត្រូវបានសម្លាប់នោះ ។

យើងដឹងថារបបកម្ពុជាប្រជាធិបតេយ្យត្រូវបានចងក្រងជាឯកសារទុកយ៉ាងច្រើនសន្ទឹកសន្ធាប់លើសពីការគិតរបស់អ្នកសង្កេតការណ៍កាលពីទសវត្សរ៍ឆ្នាំ៨០ទៅទៀត ហើយគ្មានអ្នកក្រៅណាអាចមានឱកាសប្រើប្រាស់ឯកសារទាំងនោះដោយងាយឡើយ លើកលែងតែឯកសារនៅគុកទួលស្លែងប៉ុណ្ណោះ ។ នៅពេលនោះ ដោយមានការចាប់អារម្មណ៍នឹងបណ្ណសារនៅមន្ទីរ ស-២១ ដ៏ច្រើនហូរហៀរ និងប្រហែលជាប្រភពឯកសារដើមដែលនិយាយពីរបបកម្ពុជាប្រជាធិបតេយ្យយើងក៏មានការជឿជាក់ថា ឯកសារដទៃៗទៀតរបស់របបនេះប្រសិនបើនៅមានវាពិតជាមិនខុសគ្នាទៅនឹងរូបភាពទូទៅដែលស្តែងចេញតាមរយៈការរៀបរាប់របស់អ្នកនៅរស់រានមានជីវិតឡើយ ។ ប៉ុន្តែចាប់តាំងពីឆ្នាំ១៩៩៤មក ឯកសារកម្ពុជាប្រជាធិបតេយ្យរាប់សែនសន្លឹករួមមានឯកសារនិយាយអំពីមន្ទីរស-២១ត្រូវបានរកឃើញ ។ ភាគច្រើននៃឯកសារទាំងនេះត្រូវបានផ្ទេរដោយរដ្ឋាភិបាលកម្ពុជាទៅឲ្យកម្មវិធីសិក្សាអំពីអំពើប្រល័យពូជសាសន៍នៅកម្ពុជាដែលចាត់ចែងដោយសកលវិទ្យាល័យយែល ។ ឯកសារផ្សេងៗទៀតត្រូវបានរកឃើញនៅមន្ទីរស-២១ផ្ទាល់ ក្រោយពីថតចម្លងដោយឧបករណ៍អេឡិចត្រូនិករួចកាលពីឆ្នាំ១៩៩៣ ។

ឯកសារទាំងនេះភាគច្រើនសុទ្ធតែជាឯកសារវាយអង្គុលីលេខ ហើយជាច្រើនផ្សេងទៀតជាឯកសារចម្លង ។ សម្លេងរបស់ម៉ាស៊ីនវាយអត្ថបទឯកសារ (អង្គុលីលេខ) ចាស់ៗនៅក្នុងអគារទ្រុឌទ្រោមនៅរាយប៉ាយគ្មានសណ្តាប់ធ្នាប់ប្រហែលជាសំឡេងមួយបញ្ជាក់ពីសកម្មភាពរបស់មនុស្សនៅ

ទីក្រុងភ្នំពេញ ។ មិនតែប៉ុណ្ណោះ យើងដឹងទៀតថាឯកសារច្រើនដូចភ្នំរបស់របបកម្ពុជាប្រជាធិបតេយ្យដែលឥឡូវនេះត្រូវបានអ្នកសិក្សាជាន់ខ្ពស់យកមកប្រើប្រាស់ក្នុងការសិក្សាស្រាវជ្រាវរបស់ខ្លួនគឺគ្រាន់តែជាឯកសារមួយភាគនៃឯកសារដែលបានផលិតឡើងកាលពីសម័យនោះតែប៉ុណ្ណោះ ។ មានឯកសារជម្រើសដ៏ក្រាស់ក្រែលផ្សេងទៀតនៃរបបកម្ពុជាប្រជាធិបតេយ្យដែលមិនទាន់បានយកមកប្រើប្រាស់ ស្ថិតនៅក្នុងប្រទេសកម្ពុជានិងប្រទេសវៀតណាមនៅឡើយ ។

ដូច្នេះបណ្ណសារនៅមន្ទីរស-២១ មិនមែនធម្មតាទាំងចំនួននិងផ្នែកបច្ចេកទេស ។ ប៉ុន្តែហេតុអ្វីបានជាខ្មែរក្រហមដកស្រង់ចម្លើយសារភាពដ៏វែងក្បោះក្បាយពីមនុស្សដែលខ្លួនបានផ្តោលទោសអស់មួយជីវិតហើយរៀបចំឯកសារទុកក្រោយពីអ្នកទោសត្រូវបានសម្លាប់ចោលទៅវិញ? ។ លទ្ធភាពទីមួយ ច្បាស់ណាស់បើតាមចម្លើយដ៏ច្រើនលើសលប់របស់បុគ្គលិកធ្វើការនៅមន្ទីរស-២១បង្ហាញថា ខ្លួនមិនចង់ឲ្យអ្នកត្រួតត្រានៅពីលើខ្លួនខឹង ទោះជាត្រូវលះបង់អ្វីក៏សុខចិត្តដែរ ។ ដើម្បីឲ្យមានសុវត្ថិភាពចំពោះខ្លួនឯង បុគ្គលិកនៅមន្ទីរស-២១ របស់ខ្មែរក្រហមបានចាត់ការចំពោះ «ខ្មាំង» របស់របបខ្លួនយ៉ាងហ្មត់ចត់តាមតែអាចធ្វើទៅបាន ហើយរក្សាទុកនូវឯកសារទាំងអស់ជាភស្តុតាងដើម្បីបញ្ជាក់ថាខ្លួនពិតជាបានធ្វើការយ៉ាងសកម្ម ។ លទ្ធភាពទីពីរប្រហែលជាការពិតដែរថាអ្នកគ្រប់គ្រងគុកដែលមានជំនឿស៊ប់ទៅលើរបបកម្ពុជាប្រជាធិបតេយ្យអន្ទះសារចង់ដឹងពីអំពើក្បត់ចំពោះ «បក្សជាទីស្រលាញ់របស់ខ្លួន» និងសង្ឃឹមថានឹងបានដឹងស៊ីជម្រៅតាមដានចំពោះផែនការរបស់អ្នកប្រឆាំងនឹងបដិវត្តន៍ ។ លទ្ធភាពទីបី អ្នកទោសចេះតែឆ្លើយសារភាពប៉ាតណាប៉ាតណីដើម្បីរួចខ្លួន ឬបង្អាក់ការធ្វើទារុណកម្មនិងការយកជីវិតរបស់ខ្លួន ។ លទ្ធភាពចុងក្រោយគឺហាក់ដូចជាការច្បាស់ណាស់ថា សុន សេន និងអតីតគ្រូបង្រៀនផ្សេងទៀតដែលចាត់ចែងការងារនៅក្នុងគុកចង់គ្រប់គ្រងប្រតិបត្តិការសន្តិសុខដោយប្រុងប្រយ័ត្នដើម្បីឲ្យអន្តរជាតិទទួលស្គាល់នូវរបបកុម្មុយនិស្តរបស់ខ្លួន និងដើម្បីបំពេញបំណងខ្លួនឯងផ្ទាល់តែម្តង ។

ការពន្យល់ហេតុផលទាំងនេះពិតអាចជួយបង្ហាញផ្លូវប៉ុន្តែការឲ្យយោបល់មួយដោយលោក ស៊ីវ ហេឌ័រ កាលពីយូរណាស់មកហើយដែលផ្តល់ផ្លែផ្កាគឺថា បណ្ណសារនេះត្រូវបានប្រមូលផ្តុំដើម្បីផ្តល់ឲ្យមជ្ឈិមបក្សនូវឯកសារដើមសរសេរដោយដៃយ៉ាងច្រើនក្រាស់ក្រែលស្តីអំពីប្រវត្តិរបស់បក្ស ។ ព័ត៌មានលម្អិតស្តីអំពីការសមគំនិតក្បត់អាចកាត់បន្ថយនូវការអន្ទះសារចង់ដឹងចង់យល់របស់ ប៉ុល ពត ព្រមទាំងបក្ខពួកដែលធ្លាប់ជាអ្នកក្បត់ចំពោះអ្វីដែលកំពុងកើតឡើងនៅក្រោយខ្នងក្នុងពេលបន្តប់ខ្លួនក្នុងទសវត្សរ៍ឆ្នាំ៥០ លាក់ខ្លួននៅទសវត្សរ៍ឆ្នាំ៦០ និងចល័តខ្លួនក្នុងអំឡុងសង្គ្រាមស៊ីវិល ។ លើសពីនេះទៅទៀត ដោយសារតែអ្នកទោសទាំងអស់ដែលត្រូវបានឃុំខ្លួននៅក្នុងគុកចុងបញ្ចប់ត្រូវ «កម្ទេច» គ្មានសល់ ។ ចម្លើយសារភាពរបស់អ្នកទោសទាំងអស់មិនត្រឹមតែបានបញ្ជាក់ពីឧក្រិដ្ឋកម្មរបស់ខ្លួនទេ តែថែមទាំងបញ្ជាក់ពីអំណាចនិងរឿងរ៉ាវសព្វបែបយ៉ាងរបស់បក្សទៀតផង ។ ដូចជាអត្ថបទប្រវត្តិសាស្ត្រដូច្នេះដែរ ចម្លើយសារភាពទាំងអស់បានប្រាប់មេដឹកនាំបក្សអំពីចំណុចងងឹតប្រឆាំងនឹងបក្សដែលធ្វើឲ្យប្រវត្តិជ័យជម្នះរបស់បក្សមានលក្ខណៈដូរផង់ ។ គំរូដែល ប៉ុល ពត និងអ្នកធ្វើការជិតខ្លួនកំពុងតែធ្វើគឺដើរតាមប្រវត្តិរបស់បក្សកុម្មុយនិស្តនៃសហភាពសូវៀតដែលបោះពុម្ពកាលពីឆ្នាំ ១៩៣៩ ។ នៅក្នុងឯកសារនោះមានខ្លឹមសារជាច្រើនមានលក្ខណៈស្រដៀងគ្នាទៅនឹងអ្វីដែលខ្លួនបានអនុវត្តនៅប្រទេសបារាំង ។ ឯកសារប្រវត្តិបក្សនេះមានរៀបរាប់ពីរឿងរ៉ាវនៃជ័យជម្នះរបស់ស្តាលីន ទៅលើខ្មាំងផ្ទៃក្នុងរបស់បក្ស ។

តាមលក្ខណៈចិត្តសាស្ត្រ ការអានចម្លើយសារភាពនិងរបាយការណ៍សម្លាប់មនុស្សនិងការមើលរូបថតរបស់ខ្មាំងដែលត្រូវបានសម្លាប់ច្បាស់ជាបានធ្វើឲ្យ «បងៗថ្នាក់លើ» មានអារម្មណ៍មុតមាំក្នុងចិត្តមួយអន្លើមិនខានឡើយ ។ មិនខុសពីមេដឹកនាំផ្តាច់ការផ្សេងៗទៀតឡើយ ប៉ុល ពត និងបក្ខពួកខ្លួន ជឿជាក់ថាខ្លួនត្រូវបានហ៊ុមព័ទ្ធដោយខ្មាំងសត្រូវដែលសមគំនិតក្នុងការផ្តួលរំលំខ្លួន ។ អ្នកទោសនៅមន្ទីរស-២១ ត្រូវបានធ្វើជាកម្មវត្ថុនៃគំនិតរវើរវាយរបស់បងៗថ្នាក់លើហើយបានធ្វើឲ្យសុបិនរបស់បងទាំងនោះក្លាយជាការពិតក្នុងរយៈពេលយូរល្មមគ្រប់គ្រាន់ដើម្បីឲ្យជឿថាសត្រូវរបស់ខ្លួនកំពុងតែត្រូវបានបង្ក្រាប ។ ដោយការដឹកនាំប្រទេស

ពោរពេញដោយអំពើភេរវកម្ម មេដឹកនាំកម្ពុជាប្រជាធិបតេយ្យ ហាក់ដូចជាបន្ទាចខ្លួនឯងដូចទៅនឹងអ្វីដែល អ៊ែង ដែល បានធ្វើការកត់សម្គាល់ទៅលើសម្តីរបស់ម៉ាក្សកាលពីខែកញ្ញា ឆ្នាំ១៩៧០ ក្នុងអំឡុងនៃការកាន់កាប់ទីក្រុងប៉ារីសថា «យើងយល់ថារបបដែលពោរពេញដោយអំពើភេរវកម្មជាការដឹកនាំរបស់មនុស្សមួយក្រុមដែលបង្កឲ្យមានអំពើភេរវកម្ម ។ ប៉ុន្តែផ្ទុយមកវិញគឺជាការគ្រប់គ្រងរបស់អ្នកដែលទទួលការបំភិតបំភ័យដោយអំពើភេរវកម្មរបស់ខ្លួនឯង ។ La Terreur មានន័យថាអំពើឃោរឃៅមិនចាំបាច់ដែលត្រូវបានប្រព្រឹត្តឡើងដោយអ្នកដែលត្រូវបានបំភិតបំភ័យ» ។

អ្នកសួរចម្លើយនៅមន្ទីរស-២១ ក៏ធ្វើការដូចជាអ្នកព្យាបាលរោគដែលមានការហាត់រៀនមិនដិតដល់ដោយជីកកាស់ ឆ្កឹះ ឆ្កៀល «អតីតកាល» ដែលកប់បាត់របស់អ្នកទោស ដូចជាអ្នកព្យាបាលរោគពិនិត្យតាមដានជំងឺឆ្កួតដូច្នេះដែរ ។ អ្នកជំងឺដែលលើកយកមកនិយាយនៅទីនេះមិនមែនជាអ្នកទោសដូចដែលមានអ្នកខ្លះបានគិតឡើយ ទោះបីជាមានការកែទម្រង់របៀបសួរចម្លើយមកតាមរបៀបចិនខ្លះក៏ដោយ ។ ប៉ុន្តែអ្នកជំងឺ ឬយ៉ាងហោចណាស់អ្នកដែលទទួលផលពីការព្យាបាលជំងឺ គឺជាអ្នកនៅក្នុងជួរមជ្ឈិមបក្សដែលការអន្ទះសារនិងកំហឹងរបស់ខ្លួនត្រូវបានរៀបចំបង្កើតឡើងដោយអ្នកទោសនិងនៅក្នុងឧក្រិដ្ឋកម្មរបស់អ្នកទោសដែលត្រូវបានជំរុញឲ្យខំ «ចងចាំ» និងសារភាពចេញមក ។ នៅពេលដែលខ្មាំងត្រូវបានកម្ទេចទាំងខ្សែៗនៅមន្ទីរស-២១ មេដឹកនាំកម្ពុជាប្រជាធិបតេយ្យអាចគិតថាខ្លួនជាអ្នកត្រូវនិងត្រូវបានធានា ។ ប៉ុន្តែទន្ទឹមពេលគ្នានេះដែរខ្មាំងមួយក្រុមផ្សេងទៀតបានបន្តសកម្មភាពរបស់ខ្លួនកាន់តែខ្លាំងឡើង ។


ស្រី (ជាង ថតរូបនៅមន្ទីរស-២១)

ដំណើរការសួរចម្លើយធ្វើឡើងនៅមន្ទីរស-២១មានលក្ខណៈសំខាន់និងគ្រោះថ្នាក់ប្រហាក់ប្រហែលទៅនឹងការផ្សៀងផ្ទាត់ផ្នែកចិត្តសាស្ត្រដែរ ។ ដោយដើរតួជាប្រភពសំខាន់ចំពោះប្រវត្តិសាស្ត្រច្បាប់ដែលមិនទាន់សរសេរនិងជាឧបករណ៍សម្រាប់ព្យាបាលរោគដែលមានសារៈសំខាន់ចំពោះមជ្ឈិមបក្ស ការសួរចម្លើយនិងចម្លើយសារភាពបានផ្តល់ដល់មជ្ឈិមបក្សនូវអ្វីដែលចិត្តវិទូឈ្មោះ ដូណាល់ ស្ពេនស៍ ហៅថា «ការពិតដែលចេញពីការរៀបរាប់តាមវគ្គតាមស្ទើ» ។ របៀបសួរចម្លើយនិងការឆ្លើយសារភាពមានលក្ខណៈដូចជាមេដឹកនាំនយោបាយនិងប្រហែលជាមនុស្សទូទៅដូច្នេះដែរ ។ ប៉ុន្តែទំនាក់ទំនងរវាងចម្លើយសារភាពទៅនឹងគំនិតផ្ទុយរបស់ ស្ពេនស៍ «ការពិតជាប្រវត្តិសាស្ត្រ» មិនអាចត្រូវបានបញ្ជាក់ឲ្យបានច្បាស់ឡើយ ទើបតែពេលដែលបណ្ណសាររបស់កម្ពុជាប្រជាធិបតេយ្យត្រូវបានស្រាវជ្រាវរកឃើញ ឬពេលដែលអតីតសមាជិករបស់បក្សនិយាយចេញមក ទេទើបការពិតនៃទំនាក់ទំនងត្រូវបានបញ្ជាក់ច្បាស់ ។ ទន្ទឹមពេលនេះដែរការអានចម្លើយសារភាពនាំឲ្យយើងទៅដល់ដំណើរ

គំនិតរបស់របបមួយប្រកាន់គំនិតចាស់គំរិលដែលធ្លាប់ត្រូវបានធ្វើឲ្យភ័យខ្លាចនិងធ្វើឲ្យមានការភ័យខ្លាច មានគំនិតដាច់ខាតពោរពេញដោយល្បិចកលខ្ពស់និងស្ថិតក្រោមការគំរាមកំហែងឥតឈប់ឈរ ។ ចម្លើយសារភាពផ្តល់នូវការរៀបរាប់អំពីការភ័យខ្លាចដែលចេះតែកើនឡើងជាលំដាប់និងការគិតមមៃរបស់មជ្ឈិមបក្សក្នុងខណៈដែលយុវជនយុវនារីដែលពោរពេញដោយគំនុំ និងមានគំនិតហួសនិស្ស័យ តស៊ូស៊ិតស្វាញក្នុងការថែរក្សាជាតិមួយប្រកបដោយជំហរធ្វើសង្គ្រាមសមូហភាវូនីយកម្មសម្រេចឯករាជ្យម្ចាស់ការផ្នែកសេដ្ឋកិច្ច ការបង្ក្រាប ការខ្វែងគំនិតនិងធ្វើមជ្ឈការទៅលើអំណាចរបស់ខ្លួន ។

## ព្រឹត្តិការណ៍ថ្ងៃ១៧ ខែមេសា ឆ្នាំ១៩៧៦

នៅថ្ងៃទី៣០ ខែមីនា ឆ្នាំ១៩៧៦ កិច្ចប្រជុំមួយដែលរៀបចំឡើងដោយមជ្ឈិមបក្សមានការបង្កើតជាជំហានៗជាច្រើនក្នុងគោលបំណង «កម្ទេច (មនុស្ស) ខាងក្នុងនិងខាងក្រៅជួរ» ។ ជំហានទាំងនេះបានបង្ហាញពីការគ្រប់គ្រងទៅលើ «ការកម្ទេច» ខ្លាំងធ្វើឲ្យអង្គការមានលក្ខណៈសមរម្យ «ដើម្បីពង្រឹងអំណាចរបស់រដ្ឋយើង» ។ អង្គការនៅទីនេះគឺមានការទទួលខុសត្រូវចំពោះមជ្ឈិមបក្ស ។

...សេចក្តីយោងពីខាងដើមដែលនៅមានលក្ខណៈអាថ៌កំបាំងនៅឡើយមានភាពខ្វះចន្លោះមិនគ្រប់គ្រាន់ដូចដែលអ្នកស្រាវជ្រាវបានធ្វើដែរក្នុងការបង្ហាញភ័ស្តុតាងចោទប្រកាន់មេដឹកនាំកម្ពុជាប្រជាធិបតេយ្យពីបទធ្វើមហាមនុស្សឃាតដែលត្រូវបានប្រព្រឹត្តឡើងនៅក្នុងរបបរបស់ខ្លួនកាន់កាប់ ។

កិច្ចប្រជុំនោះក៏បានលើកបញ្ហាមួយចំនួនដូចជាការរុញសម្តេចសីហនុ ចេញឲ្យធ្វើប្រមុខរដ្ឋបំបិទវិហារគ្រិស្តកាតូលិក នៅក្នុងទីក្រុងភ្នំពេញប្រវត្តិរបស់បក្ស ផែនការសេដ្ឋកិច្ចថ្ងៃឈប់សម្រាកជាផ្លូវការ និងអំពីអង្គការចាត់តាំងរបស់រដ្ឋាភិបាល ។ បើយកមកអានពេលនេះ អ្នកអានពិតជាដឹងនូវភាពគ្មានសណ្តាប់ធ្នាប់របស់របបមួយដែលទើបតែបានកាន់អំណាច ហើយដែលមេដឹកនាំរបស់របបនេះកំពុងតែរង់ចាំពង្រីកនិងផ្សព្វផ្សាយជ័យជម្នះ ១៧ មេសា ឆ្នាំ១៩៧៥ របស់ខ្លួនទៅលើ «អាមេរិក» ឲ្យប្រជាជនទូទាំងប្រទេសបានឮ ។

បីថ្ងៃក្រោយមក នៅពេលព្រលឹមស្រាងៗមានគ្រាប់បែកផ្ទុះនៅជិតព្រះបរមរាជវាំង ហើយមានបាញ់កាំភ្លើងដាក់សារមន្ទីរជាតិដែលស្ថិតនៅក្នុងក្រុងភ្នំពេញ ។ សារមន្ទីរជាតិនិងព្រះបរមរាជវាំងស្ថិតនៅមិនឆ្ងាយប៉ុន្មានពីបរិវេណអគារដែលមានការយាមកាមយ៉ាងប្រុងប្រយ័ត្នដែលមាន «បងថ្នាក់លើ» ចូលមកនៅដោយសម្ងាត់នោះ ។ ប៉ុន្តែការផ្ទុះនោះមិនមានភ័ស្តុតាងច្បាស់ណាមួយបញ្ជាក់ពីការបាត់បង់ជីវិត ខូចខាតសម្ភារ ឬក៏សកម្មភាពក្បត់ឡើយ ។ មូលហេតុដែលនាំឲ្យកើតព្រឹត្តការណ៍ឡើងមិនទាន់មានលក្ខណៈច្បាស់លាស់ឡើយ ប៉ុន្តែ «បងៗថ្នាក់លើ» យល់ថាវាជារឿងមួយធ្ងន់ធ្ងរជាទីបំផុត ។ នៅក្នុងថ្ងៃដដែល សម្តេច សីហនុ បានត្រៀមខ្លួនលាលែងពីតំណែងជាប្រមុខរដ្ឋ ។ ទាហានសំណាងអាក្រក់ដែលបានចោលគ្រាប់បែកហើយមិនដឹងអំពីការកើតឡើងនៅក្រោយខ្លួនឡើយ ។ មេដឹកនាំប្រទេសដែលប្រាសប្រាលនៅមិនស្រណុកយល់ថា ឧបទ្ទវហេតុនេះជាសញ្ញាបង្ហាញពីការធ្វើរដ្ឋប្រហារ ។ ពេលនោះអ្នកចោលគ្រាប់បែកត្រូវបានចាប់ខ្លួនក្នុងអំឡុងមួយសប្តាហ៍ ហើយកាស្សែតថតចម្លើយសារភាពរបស់ជនដែលត្រូវបានចាប់ខ្លួនរួមទាំងចំណាររបស់ ឌុច ត្រូវបានបញ្ជូនជាបន្ទាន់ទៅឲ្យមជ្ឈិមបក្ស ។ **(នៅមានត)**


១៧ មេសា ១៩៧៥

# ការដកស្រង់មាត្រាដែលពាក់ព័ន្ធនឹងការលើកលែងទោស

ការដកស្រង់មាត្រាដែលទាក់ទិនដល់ការលើកលែងទោស នៅក្នុងមាត្រាទាំងឡាយនៃអនុសារណៈស្វែងយល់រវាងអង្គការសហប្រជាជាតិនិងរាជរដ្ឋាភិបាលកម្ពុជាស្តីអំពីការកាត់ទោសតាមច្បាប់របស់កម្ពុជាចំពោះឧក្រិដ្ឋកម្មដែលត្រូវបានប្រព្រឹត្តឡើងក្នុងអំឡុងនៃរបបកម្ពុជាប្រជាធិបតេយ្យៈ

ពង្រាងច្បាប់ថ្ងៃទី៥ ខែកក្កដា ឆ្នាំ២០០០ ត្រូវបានពិភាក្សានិងផ្លាស់ប្តូរយោបល់យ៉ាងល្អិតល្អន់រវាងអង្គការសហប្រជាជាតិដែលដឹកនាំដោយលោក ហេន កូរែល និងតំណាងគណៈប្រតិភូកម្ពុជាដែលដឹកនាំដោយឯកឧត្តម សុខ អាន។ បន្ទាប់ពីការពិភាក្សានេះមានចេញជាពង្រាងច្បាប់ថ្ងៃទី៧ ខែកក្កដា ឆ្នាំ២០០០ ដែលពង្រាងច្បាប់នេះជាលទ្ធផលកើតចេញពីការពិភាក្សាលើពង្រាងច្បាប់ថ្ងៃទី៥ ខែកក្កដា ឆ្នាំ២០០០។ ពង្រាងច្បាប់ក្រោយនេះមានទីតាំងហត្ថលេខាដោយលោក ហេន កូរែល និងឯកឧត្តម សុខ អាន។ ក្នុងនោះមាត្រាទី៩ស្តីអំពីការលើកលែងទោសត្រូវបានព្រមព្រៀងគ្នាថាៈ

ភាគីទាំងអស់យល់ព្រមថានឹងគ្មានការលើកលែងទោសទេចំពោះបទឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មសង្គ្រាមនិងបទឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ។ ការលើកលែងទោសដែលបានផ្តល់ដល់ជនណាម្នាក់ហើយដែលជននោះស្ថិតនៅក្នុងដែនសមត្ថកិច្ចរបស់សភាតុលាការក៏ដោយ ក៏មិនមែនជាឧបសគ្គរារាំងមិនឲ្យមានការកាត់ទោសនោះដែរ។

មានការកំណត់សម្គាល់នៅក្នុងសេចក្តីព្រាងច្បាប់ថ្ងៃទី៧ ខែកក្កដា ឆ្នាំ២០០០ ក្នុងមាត្រាទី៩ ដដែលសរសេរថា «នៅថ្ងៃទី២០ ខែមីនា ឆ្នាំ២០០០ ប្រធានគណៈប្រតិភូរបស់អង្គការសហប្រជាជាតិត្រូវបានជូនដំណឹងជាលាយលក្ខណ៍អក្សរដោយប្រធានគណៈប្រតិភូខាងភាគីកម្ពុជាដូចខាងក្រោមនេះ ដែលពាក់ព័ន្ធទៅនឹងសេចក្តីសម្រេចចិត្តនានាដែលបានធ្វើឡើងរួចមកហើយទាក់ទិននឹងការលើកលែងទោសចំពោះខ្មែរក្រហម៖

រដ្ឋធម្មនុញ្ញកម្ពុជាប្រទានសិទ្ធិថ្វាយព្រះមហាក្សត្រក្នុងការផ្តល់ការលើកលែងទោស (មាត្រាទី២៧) ហើយសភាជាតិក៏បានធ្វើច្បាប់ដែលទាក់ទិននឹងការលើកលែងទោសនេះដែរ (មាត្រា៩០)។ ពីមុនៗមក ព្រះមហាក្សត្របានអនុវត្តន៍សិទ្ធិនេះតែម្តងគត់ពាក់ព័ន្ធទៅនឹងខ្មែរក្រហមដោយមានសំណើពីរាជរដ្ឋាភិបាលកម្ពុជារួមនឹងសំឡេងគាំទ្រយ៉ាងច្បាស់ក្រឡែតចំនួន២ភាគ៣នៃសមាជិកសភាជាតិ។ ពង្រាងច្បាប់របស់យើង (មាត្រាទី៤០) ចែងបញ្ជាក់យ៉ាងច្បាស់អំពីចេតនារបស់រដ្ឋាភិបាលថាមិនស្នើសុំឲ្យមានការលើកលែងទោសសម្រាប់នរណាមួយដែលបានប្រព្រឹត្តបទឧក្រិដ្ឋកម្មពាក់ព័ន្ធនឹងច្បាប់ដែលអាចអនុវត្តន៍បានមានចែងក្នុងមាត្រា៣ដល់៨នៃពង្រាងច្បាប់នេះ។ នេះបង្ហាញនូវចេតនារបស់យើងក្នុងការទម្លាយបញ្ហាក្នុងដំណើរការ។ ដូចតែពីមុនអ៊ីចឹង ខ្ញុំសូមជម្រាបលោកថាពាក់ព័ន្ធទៅនឹងបញ្ហាដែលមានទៅលើពង្រាងច្បាប់នេះគឺមានតែមួយករណីប៉ុណ្ណោះ កាលពីថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ១៩៩៦ ដែលការលើកលែងទោសត្រូវបានផ្តល់ជូនមនុស្សតែម្នាក់គត់ ដោយយោងទៅលើការកាត់ឲ្យជាប់ទោសឆ្នាំ១៩៧៩ ពីបទចោទប្រកាន់ថាប្រព្រឹត្តបទឧក្រិដ្ឋកម្មប្រល័យពូជសាសន៍។ សូមអានទំព័រលេខ៣៤ ប្រកាសរបស់រាជរដ្ឋាភិបាលកម្ពុជាស្តីអំពីពង្រាងច្បាប់កាត់ទោសមេដឹកនាំខ្មែរក្រហម។

**ម៉ាន់ថាន់ ពៅដារ៉ា**



# គំរូមួយនៃភ័ស្តុតាងឯកសារដែលធ្លាប់មេដឹកនាំជាន់ខ្ពស់នៃបក្សកុម្មុយនិស្តកម្ពុជា ដែលនៅរស់ ទៅនឹងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ (ភាគ២)

**(តពីលេខមុន)** ជាពិសេស សុន សេន បានប្រាប់កម្មាភិបាលយោធាដឹកនាំថា "ត្រូវតែមានជំហរដាច់ខាតក្នុងការបោសសម្អាតពួកប្រឆាំងនឹងបដិវត្តន៍ កុំចេះតែធ្វើដោយគ្មានផែនការត្រឹមត្រូវ" ។ មុត និង ម៉េត ក៏បានស្តាប់របាយការណ៍ពីកម្មាភិបាលដឹកនាំកងពលដូចជាលេខាកងពល៣១០ ឈ្មោះ ស្បូវ ហ៊ិម ហៅ អឿន (ក្រោយមកត្រូវបានបោសសម្អាត) ។ អឿន មិនគ្រាន់តែរាយការណ៍ម្តងទៀតអំពីការចាប់ខ្លួនក្មេងប្រុសម្នាក់នៅព្រែកក្តាមទេ ថែមទាំងរាយការណ៍ថា "ពួកក្បត់មួយចំនួន" ត្រូវបាន "វែកមុខ" នៅក្នុងកងពលតាមរយៈអ្វីដែល អឿន និយាយថា "សភាពការណ៍សម្ងាត់" និងតាម "ចម្លើយពីខាងក្រៅ" តាម "ចម្លើយសារភាព" ស្រង់ពីមន្ទីរស-២១ ។ អឿន ពន្យល់ថា "បញ្ហាលួចនៅមានជាបន្តបន្ទាប់" ហើយថា "បញ្ហាលួចលេចចេញជានយោបាយមិនមែនលួចធម្មតា" ។ អឿន ត្អូញត្អែរថា "ក្រោយអប់រំ ពួកល្អកែប្រែភាគច្រើន តែមួយចំនួនតិចនៅរឹងរូសចចេសមិនកែប្រែ" ។ មិនតែប៉ុណ្ណោះទោះបីជាមានការអប់រំនយោបាយទូទៅយ៉ាងណាក៏ដោយក៏ "បក្ខជនកម្មាភិបាលមួយផ្នែកពុំទាន់ស្មោះត្រង់នៅវៀចវេរក្បត់នឹងបក្ស មិនពេញចិត្តរីករាយនឹងផែនការ៤ឆ្នាំរបស់បក្ស" ដូចដែលបានពិភាក្សានៅថ្នាក់លើតាំងពីខែកក្កដា ឆ្នាំ១៩៧៦ ។

នៅក្នុងរបាយការណ៍របស់ខ្លួន មុត បានសម្តែងការព្រួយបារម្ភថា "ចូលមកដល់ខែ៩នេះមានការប្រែប្រួលខ្លាំង" ។



ទីមួយ មុត រាយការណ៍ថា «លេចចេញសកម្មភាពលួចស្លឹកលួច» ។ ទីពីរ មានសកម្មភាពបំផុសថា «មានបាតុភាពបំផុសថាមានខ្មាំង» នៅតំបន់ប្រតិបត្តិការក្នុងកងពល១៦៤ ។ ទីបី «មានយុទ្ធជនខាងបើកឡាន៧នាក់ បានចាត់តាំងជាអង្គភាពសេរី មានស្នងការ មានបញ្ជាការ មានអ្នកទទួលភារៈភ័ស្តុភាររបស់គេ» ។ ទីបួន «យុទ្ធជននិងកម្មាភិបាលមកដេកពេទ្យ ដើរហើរសេរី ក្តាប់មិនបាន» ។ ចុងបញ្ចប់ មុត រាយការណ៍ថា «កម្មាភិបាលខ្លះបោកខាងក្រោមថាអង្គការហៅប្រជុំ លួចជិះម៉ូតូដើរលេង» ។

ចំពោះផ្នែកនេះ ម៉េត បានរាយការណ៍អំពី «សភាពការណ៍ខ្មាំង» ទាក់ទងនឹងការរកឃើញកាំភ្លើងកាប៊ីនមួយដើមនៅសាលាកងពល៥០២ ដែលត្រូវត្រៀមបើកវគ្គ ។ ការរកឃើញកាំភ្លើងមួយដើមនេះនាំឲ្យ ម៉េត សន្និដ្ឋានថា «ខ្មាំងមានបំណងចង់សម្លាប់កម្មាភិបាលយើងពេលរៀន» ។ ម៉េត រាយការណ៍ទាំងពេញចិត្តថា «ខាងបាត់ដំបង កងទ័ពភូមិភាគ (ពាយ័ព្យ) ការពារព្រលានយន្តហោះមានសមាសភាពមិនល្អដែលមូលដ្ឋានចាត់វិធានការសម្រិតសម្រាំងហើយ» ។ ប៉ុន្តែទន្ទឹមគ្នានេះដែរ «ការកសាងសន្តមនិយមភាគច្រើនសកម្មភាពល្អ តែបុគ្គលខ្លះនៅធាក់ក្រាញ» ។ ជាពិសេស «កម្មាភិបាលអនុសេនាធំម្នាក់ឲ្យយាមនារីជាខ្មាំងមានចោទពាក់ព័ន្ធសីលធម៌» ពោលគឺការរួមភេទមិនត្រឹមត្រូវ ។

មុត ស្ថិតនៅក្នុងក្រុងភ្នំពេញមួយរយៈក្រោយពីចូលរួមប្រជុំហើយក្នុងមួយរយៈនោះ មុត បានទទួលរបាយការណ៍សកម្មភាពកងពល១៦៤ ពីអនុលេខារបស់ខ្លួនឈ្មោះ ហឹង ឌឿន ហៅ ឌឹម (ក្រោយមកត្រូវបានបោសសម្អាត) ។ នៅក្នុងទូរលេខថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ១៩៧៦ ឌឹម បានពន្យល់ថា បន្ទាប់ពីកងពលបាន «ចាត់វិធានការផ្សេងៗចំពោះខ្មាំង» ដែល មុត «បានសម្រេច» មាន៥នាក់ «រត់ចូលព្រៃ» ប៉ុន្តែត្រូវបាន «ដេញចាប់បាន» វិញហើយ ។ ពីរ-បីថ្ងៃក្រោយមក ឌឹម បានផ្ញើទូរលេខមួយទៀតជម្រាប មុត ថា «នៅយប់ថ្ងៃទី២៣ កញ្ញា យើងចាប់បានកុមារម្នាក់អាយុ១៦ឆ្នាំ» ។ តាមកុមារនេះ «សារភាព» ថា ខ្លួន «មានភារៈជាគិញស៊ើបការណ៍ឲ្យពួកចោរព្រៃថាពួកវាមានកាំភ្លើងអាកា៣ដើម កាំភ្លើងខ្លី៥ដើម វាសារភាពយ៉ាងនេះ» ។

ការចាប់ខ្លួននានារបស់កងពល៥០២ ត្រូវបានរាយការណ៍ជូនកិច្ចប្រជុំអគ្គសេនាថ្ងៃ៣០ ខែកញ្ញា ដែលដឹកនាំដោយសមាជិកឈ្មោះ ស៊ាត តែ ហៅទុំ (ក្រោយមកត្រូវបានបោសសម្អាត) ។ ក្រោមរបៀបវារៈ «សភាពការណ៍ខ្មាំង» កំណត់ហេតុប្រជុំសរសេរថាអង្គភាពរបស់ ម៉េត បាន «ចាប់យុទ្ធជន១៥នាក់» ដែល «រត់ចោលជួរក្នុងខែកញ្ញា» ហើយឥឡូវនេះត្រូវបានចាត់ទុកថាជា «ពួកមាននិន្នាការនិងសេរី» ។ នាថ្ងៃទី៩ ខែតុលា ឆ្នាំ១៩៧៦ អនុរបស់ ម៉េត ឈ្មោះ ញ៉ែម សាន បានផ្ញើរបាយការណ៍មកអគ្គសេនាធិការរាយការណ៍អំពីសភាពការណ៍ខ្មាំងថា កងពល៥០២បានចាប់ខ្លួនមនុស្សម្នាក់ឈ្មោះ ឌី ព្រីង ដែលពេលសួរចម្លើយឆ្លើយថា «បានធ្វើសកម្មភាពក្នុងឃុំបឹងធំ ស្រុក៥២ តំបន់៣៣ ក្នុងគោលបំណងចង់ធ្វើបាតុកម្មនៅថ្ងៃទី១២ ខែតុលា ឆ្នាំ១៩៧៦ ប្រឆាំងនឹងបដិវត្តន៍» ។ ព្រីង បាន «ប្រាប់» ឈ្មោះ «បក្ខពួករបស់ខ្លួន» ចំនួន៣៣នាក់ ។ ឈ្មោះទាំងអស់នេះក៏ត្រូវបានកត់ចូលបញ្ជីក្នុងរបាយការណ៍រួចដែរ ។

មុត និង ម៉េត ពេលនោះបានចូលរួមកិច្ចប្រជុំកម្មាភិបាលកងពលថ្ងៃទី៩ ខែតុលា ឆ្នាំ១៩៧៦ រៀបចំឡើងដោយ សុន សេន ។ កម្មាភិបាលដែលចូលរួមប្រជុំបានស្តាប់របាយការណ៍របស់លេខាកងពល៤៥០ ដែលនិយាយអំពី «កម្មាភិបាលដែលឪពុកម្តាយត្រូវបានបោសសម្អាត» មុនពេលស្តាប់របាយការណ៍របស់អនុលេខា ឌឹម និង សាន ។ ឌឹម បានរាយការណ៍អំពីការចាប់ខ្លួននានាដោយកងពល១៦៤ ។ ទី១ «ចាប់បានកុមារម្នាក់ជាកូនរបស់ទាហានត្រូវចោរចាប់ឲ្យទៅនៅជាមួយវា ហើយចោរព្រៃឲ្យចេញមកស៊ើបការណ៍ ។ កុមារនេះថាទីបញ្ជាការចោរព្រៃនៅលើកំពូលភ្នំកណ្តាលមានគ្នាប្រាំនាក់រស់នៅជាជម្រកបោះតង់និងគ្រែប៉ោអ៊ី» ។ ទី២ «ចាប់បាននារីអាយុ១៣ឆ្នាំ មុំទឹកសាប (ស្រុកព្រៃនប់) សារភាពថាមានគ្នា៣នាក់ ប្រហែលនៅអូរជុស» ។ ទី៣ «ចាប់បានម្នាក់លួចអង្ករនៅកំពង់សោមថាមកតាំងពីវាលរេញ» ។ ទី៤ «យុទ្ធជនម្នាក់ទៀតឈ្មោះ សាន ចង គ្រាប់បែក៥ក្រោមគ្រែសមមិត្ត រឿន ចាប់មកតែរត់រួច» ។

សាន រាយការណ៍ថា «មានចាប់បានមួយចំនួនតាមមុខសញ្ញា៥០២» រួមទាំងឈ្មោះ ឌី ព្រីង ។ សាន និយាយថា

"វាជាពួករៀបចំធ្វើបាតុកម្មដែលមូលដ្ឋានចាប់" ។ "ខាងអគ្គភាពមានសភាពរត់ទៅមូលដ្ឋានទាក់ទងនឹងចោរព្រៃ" ។ ទាក់ទងនឹងបញ្ហានេះ សាន បានលើកឧទាហរណ៍ជាក់ស្តែងថា "អាសុខា ឆ្លើយបានមួយចំនួនតែវាចង់កសម្លាប់ខ្លួនទៅ" ។ រឿងមួយទៀតគឺជារឿងរបស់កម្មាភិបាលអនុសេនាធំដែលរផ្ញើថា "ស្លូតក្នុងបដិវត្តន៍ប្រជាធិបតេយ្យទៅមុខ ស្លូតក្នុងបដិវត្តន៍សង្គមនិយមទៅក្រោយ មុនហូបអង្ករគោ ឥឡូវហូបអង្ករកំប៉ុង" ។ ចុងបញ្ចប់ សាន រាយការណ៍ថា "បានដកសមាសភាពនិន្នាការនយោបាយជាង៨០នាក់ហើយ" ។

ជាងនេះទៅទៀត សុន សេន បានធ្វើបទឧទ្ទេសនាមអំពី "ភារកិច្ចការពារប្រទេស" តើត្រូវចាត់វិធានការរបៀបណាចំពោះ "ជនក្បត់មួយចំនួននៅក្នុងបក្សដែលយើងបានចាប់" ។ សុន សេន និយាយថា "តាមចម្លើយរបស់ពួកនេះ យើងដឹងពីផែនការខ្មាំងមួយចំនួន" ។ "សូមជម្រាបពីវិធានការរបស់យើងនិងពិសោធន៍មួយចំនួនចំពោះកិច្ចការការពារប្រទេស" ។ សុន សេន នៅបានពន្យល់ថា "ខ្សែក្បត់ដែលយើងចាប់បានបន្តមកគឺ៣ខ្សែ នៅទីបំផុតជាខ្សែតែមួយទេ ។ ដំបូងយើងចាប់បានខ្សែក្បត់កងពល១៧០ ។ ...កាលនោះយើងវិភាគថា ចំពោះខ្មាំងខាងលិចមានទិសវិវត្តន៍ទៅធូរស្រាល បដិវត្តឈ្នះលទ្ធភាពល្អដល់យើង...តែយើងមិនចាប់អារម្មណ៍ពីខ្មាំងធ្វើសកម្មភាពវាយយើងពីក្នុងខ្លាំងទេ..." ។

សុន សេន បានពន្យល់យ៉ាងក្បោះក្បាយអំពីការចាប់ខ្លួន ចាន់ ចក្រី នៅថ្ងៃទី១៩ ខែឧសភា ឆ្នាំ១៩៧៦ថា៖ "កន្លងមកមានព្រឹត្តិការណ៍បាញ់កាំភ្លើងនៅក្បែរសាលារចនាខិត្តប័ណ្ណបោះក្បែរវាំង ។ ដើមខែ៤-៧៦ វាបោះគ្រាប់បែកនិងបាចខិត្តប័ណ្ណម្តងទៀត ។ យើងចាប់អារម្មណ៍ថាវាជាសកម្មភាពខ្មាំង ។ យើងចាប់បានវាឆ្លើយដាក់បន្ទុកហូតដល់អា ចក្រី ។ ពេលមុនចាប់យើងឃើញភ័ស្តុតាងពីរៈ មួយសរសេរសំបុត្រទៅអា សុផាន ថាប្រពន្ធវាជិតគ្រប់ខែឲ្យទៅរកគ្រូខ្មែរនៅទិសខាងកើតនិងសំបុត្រឆ្លើយរបស់អាសុផាននឹងគោរពតាមបងទាំងអស់" ។

ចំពោះលទ្ធផលនៃការសួរចម្លើយរបស់ចក្រី សុន សេន បកស្រាយថា៖ "ពេលចាប់វាឆ្លើយច្បាស់ថា វាជាខ្មែរសេរី មេវាគឺ ឈូក លេខាតំបន់២៤ ។ យើងចាប់បាន ឈូក ឆ្លើយថាខ្លួន


សុន សេន

ទាក់ទងវៀតណាមរៀបចំវាយក្បាលម៉ាស៊ីនដឹកនាំបក្សយើង ។ ខ្លួនជាអ្នកវាយពីក្នុងវៀតណាមវាយពីក្រៅ ។ យួន ឈ្មោះ បៃ ម៉ាប់ ។ ឈូក ឆ្លើយមកដល់ឈ្មោះ យ៉ា ។ យើងចាប់ យ៉ា ឆ្លើយថាវាក្បត់តាំងពី១៩៦២ ដែលមានម្នាក់ទៀតឈ្មោះ កែវ មាស ។ ខ្សែនេះបង្កើតបក្សថ្មីតាំងពីឆ្នាំ១៩៦២ មក...ដូច្នេះបញ្ហាបះបោរនៅកោះកុង បញ្ហាតំបន់២៥ទំនាស់នឹងតំបន់៣៣ យើងដឹងអស់ហើយ» ។

សុន សេន ប្រកាសថា «ខ្សែមេៗយើងកម្ទេចជាមូលដ្ឋានអស់ហើយ» នូវខ្សែបី ដែលជាខ្សែក្បត់តែមួយ ។ ដោយប្រើពាក្យសម្គាល់អ្នកដែលត្រូវបានផ្ដន្ទាទោសដល់ជីវិត សុន សេន និយាយថា ខ្សែមេៗគឺជា «ខ្សែមហាក្បត់ជាតិ ក្បត់បក្សដ៏ធំនៃប្រវត្តិសាស្ត្រយើង ។ ពួក សេ.អ៊ី.អា ខាងក្នុង ព្រមទាំងខ្សែមេៗក្បត់ត្រូវយើងវាយខ្ទេចជាមូលដ្ឋាន» ។ សុន សេន បានព្រមានចំពោះអ្នកដែលមានវត្តមាននៅក្នុងកិច្ចប្រជុំថា «ប៉ុន្តែនៅតែមានបក្ខពួកវា» ។ ដូច្នេះ សុន សេន ណែនាំថា៖ «លើកកម្ពស់ស្មារតីប្រុងប្រយ័ត្នបដិវត្តន៍ខ្ពស់ថែមទៀត ។ ពីមុនយើងលើកបញ្ហានេះតែយើងពុំទាន់មានឯកសារអ្វីដែលច្បាស់ដែលរស់ដូចឯកសារថ្មីនេះ ។ ដូច្នេះត្រូវប្រុងប្រយ័ត្នបដិវត្តន៍ឲ្យខ្ពស់ ការពារបក្សបដិវត្តន៍ឲ្យបាន ។ ន័យអនុវត្តជាក់ស្ដែងខាងប្រុងប្រយ័ត្នបដិវត្តន៍គឺក្ដាប់អង្គភាពយើងឲ្យជាប់ កុំឲ្យខ្មាំងស៊ីរូងផ្ទៃក្នុងបានធ្វើយ៉ាងម៉េចឲ្យកងទ័ពយើងស្អាត ។ ផ្នែកចក្រពត្តិអាមេរិក សេ.អ៊ី.អា ក៏ដូចជាពួកយួន-សូវៀតសេរី សុទ្ធតែមានផែនការស៊ីរូងផ្ទៃក្នុង បង្កើតក្រុមថ្មីប្រឆាំងនឹងយើង» ។

ចំពោះបញ្ហាសម្ងាត់ សុន សេន និយាយពន្យល់ដល់អ្នកដែលមានវត្តមាននៅក្នុងកិច្ចប្រជុំថា «ត្រូវក្ដាប់ទំនាស់នៅក្នុងសង្គមកម្ពុជាបច្ចុប្បន្នឲ្យជាប់ព្រោះទំនាស់រវាងយើងនិងវណ្ណៈជិះជាន់កាន់តែស្រួចស្រាល់ជាងមុន ។ នេះជាទំនាស់រវាងបដិវត្តន៍ត្រឹមត្រូវនិងបដិវត្តន៍ក្លែងក្លាយ ទំនាស់រវាងបដិវត្តន៍និងចក្រពត្តិអាមេរិក ទំនាស់រវាងជំហរឯករាជ្យនិងជំហរខ្ញុំកញ្ជះគេ ។ ត្រូវអប់រំបងប្អូនឲ្យយល់ពីសភាពទំនាស់ពីខ្មាំងស៊ីរូងផ្ទៃក្នុងពីខបាយកលខ្មាំងឲ្យជ្រួតជ្រាបដល់ក្រោម ។ ត្រូវដាច់ខាតសម្រិតសម្រាំងសមាសភាពមិនល្អ» ។

កងពល១៦៤ របស់ ឌឹម គឺជាកងពលទីមួយ ហើយដែលនិយាយថា «សុំឯកភាពតាមបទឧទ្ទេសនាមរបស់អង្គការចំពោះសភាពការណ៍ខ្មាំង» ។ ឌឹម បន្ថែមថា «ពីមុនខ្លះសង្ស័យខ្លះមិនសង្ស័យ ដោយបុគ្គលទាំងនោះនៅក្នុងនាទីដឹកនាំសំខាន់ ។ ដូច្នេះនាំឲ្យមានការប្រុងប្រយ័ត្នកាន់តែខ្ពស់ថែម» ។ ឌឹម ពន្យល់អង្គប្រជុំថា «កន្លងមកកងពលធ្លាប់មានខ្មាំងធ្វើសកម្មភាពតែវិធានការវាយខ្មាំងតែងខ្លះខាតមិនបានយកចិត្តទុកដាក់ខ្ពស់ ។ បញ្ហានេះបើគិតដល់សកម្មភាពខ្មាំងម្នាក់ឬពីរនាក់ផ្ទៃក្នុង សុទ្ធតែអាចបំផ្លិចបំផ្លាញកម្លាំងបដិវត្តន៍បាន ។ ឧទាហរណ៍ លួចដុតឃ្លាំងជាដើម ។ បញ្ហាខ្មាំងបង្កើតបក្សថ្មីគ្រាន់តែដឹងតាមការណែនាំជាបន្តបន្ទាប់របស់បក្ស តែមិនស៊ីជម្រៅដូចជាការស្ដាប់ពត៌មានរបស់បក្សនេះទេ ។ ពិនិត្យកម្លាំងអាចមានពី៩០ទៅ៩៥ភាគរយដែលស្មោះត្រង់ជាមួយបក្ស ។ តែជំនឿជ្រះស្រឡះថាកងទ័ពនេះស្អាតហើយដូចនៅមិនទាន់ស្អាតទេ ត្រូវតែតាមដានសម្រិតសម្រាំងតទៅទៀត» ។

ក្រោយពីស្ដាប់សេចក្ដីរាយការណ៍ពីកម្មាភិបាលដឹកនាំមកពីអង្គភាពផ្សេងៗទៀត មុត បានសម្ដែងការឯកភាពជាមួយនឹងវិធានការ សុន សេន បានលើកឡើងព្រមទាំងធានាថានឹងសម្រាំងកងពល១៦៤ ឲ្យបានស្អាត ។ មុត អះអាងថា «សុំចាប់អារម្មណ៍អំពីសកម្មភាពពួកក្បត់ក្នុងបក្សយើង ។ មេរៀននេះបានពង្រឹងគោលជំហរប្រុងប្រយ័ត្នបដិវត្តមួយកម្រិតថែមទៀត ។ គោលជំហរវិភាគចំពោះខ្មាំងជាចក្រពត្តិអាមេរិកនិងពួកសេរីនិយមរបស់បក្សដែលមានផែនការវាយបដិវត្តន៍យើងនេះជាជំហរត្រឹមត្រូវបានបំពាក់ឲ្យយើង ។ បញ្ហាក្ដាប់អង្គភាពកម្មាភិបាល យុទ្ធជន នៅមិនទាន់រឹងមាំទេ ។ សមាសភាពមិនល្អឬខ្មាំងនៅតែពួនបន្ទំបង្កប់ក្នុងជួរបានទៀត ។ បញ្ហាក្ដាប់សតិអារម្មណ៍ជាប្រចាំថ្ងៃរបស់អង្គការស្នូលជាកត្តាសំខាន់បំផុត ។ ត្រូវរៀបចំវិធានការម្ចាស់ការជាមុន ។ ខ្ញុំយល់ព្រមឯកភាពជាមួយបក្សទាំងស្រុង ។ ធ្វើយ៉ាងម៉េចកុំឲ្យស្ថានការណ៍ជ្រុលជ្រួស...និងកុំឲ្យវាពង្រីងពង្រីកខ្លួនបានឲ្យសោះ» ។

**(នៅមានត)**

**ស៊្រីវ រេហ៊ុរ**

# សេចក្តីប្រកាសរបស់រាជរដ្ឋាភិបាលកម្ពុជាស្តីអំពីពង្រាងច្បាប់កាត់ទោសមេដឹកនាំខ្មែរក្រហម

បច្ចុប្បន្ននេះហាក់ដូចជាមានតម្រូវការចាំបាច់ក្នុងការបញ្ជាក់ឲ្យបានច្បាស់លាស់អំពីអំណះអំណាងផ្សេងៗពីគ្នាជាច្រើនទៅលើពង្រាងច្បាប់បង្កើតតុលាការខ្មែរក្រហម ពីព្រោះការភ័ន្តច្រឡំខ្លះប្រហែលជាបណ្តាលមកពីអត្ថបទចុះផ្សាយដោយកាសែតភ្នំពេញប៉ុស្តិ៍ សម្រាប់ថ្ងៃ២៧តុលា-វិច្ឆិកា ឆ្នាំ២០០០ ដែលមានចំណងជើងថា «ការសម្ងាត់នៃរឿងតុលាការខ្មែរក្រហម» លើកឡើងដោយកញ្ញា អាណេត ម៉ាឈ័រ និងការចុះផ្សាយរបស់កាសែតភ្នំពេញប៉ុស្តិ៍តាមរយៈប្រព័ន្ធអ៊ីនធ័រនែតនូវអត្ថបទមួយដែលឆ្លុះបញ្ចាំងអំពី «ការផ្លាស់ប្តូរមួយចំនួន» ដែលយល់ស្របដោយអគ្គលេខាធិការរងអង្គការសហប្រជាជាតិ ហេន កូរែល និងរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សុខ អាន នាថ្ងៃទី៧ ខែកក្កដា ឆ្នាំ២០០០ ។

អត្ថបទដែលនិយាយអំពីពង្រាងច្បាប់តុលាការខ្មែរក្រហមត្រូវបានចេញផ្សាយដោយកាសែតភ្នំពេញប៉ុស្តិ៍តាមរយៈប្រព័ន្ធអ៊ីនធ័រនែត ហើយពង្រាងអនុស្សរណៈនៃការយោគយល់គ្នា (ឬមាត្រាមួយចំនួននិយាយអំពីកិច្ចប្រត្តិបត្តិការរួម) មានការខុសប្លែកគ្នាជាច្រើនចំណុចពីអ្វីដែលថ្លែងដោយលោក ហេន កូរែល នៅថ្ងៃទី៧ ខែកក្កដា ។ គួរកត់សម្គាល់ថាអត្ថបទចេញផ្សាយនៅថ្ងៃទី៧ ខែកក្កដា មិនអាចត្រូវបានយល់ព្រមជាមួយគ្នានៅក្នុងកិច្ចចរចាទេពីព្រោះកិច្ចប្រជុំពិភាក្សាទើបតែត្រូវបានធ្វើឡើងនៅថ្ងៃទី៥ និង៦ ខែកក្កដា ។

អត្ថបទទាំងពីរស្តីពីពង្រាងច្បាប់ដែលកើតចេញពីកិច្ចចរចានៅក្នុងខែកក្កដាមានសំបុត្របញ្ជាក់មួយភ្ជាប់ជាមួយដែលនិយាយយ៉ាងច្បាស់ថាបញ្ហាក្នុងអត្ថបទនេះជាកិច្ចការដែល «អង្គការសហប្រជាជាតិនិងគណៈប្រតិភូរាជរដ្ឋាភិបាលកម្ពុជាបានយល់ព្រមធ្វើការជាមួយគ្នា» ហើយមិនមានការចុះហត្ថលេខាពីសំណាក់ភាគីទាំងពីរដូចឯកសារផ្សេងៗដែលត្រូវបានយល់ព្រមព្រៀងជាមួយគ្នាឡើយ ។ រាជរដ្ឋាភិបាលកម្ពុជានៅតែគិតថាពង្រាងច្បាប់ដែលត្រូវបានព្រមព្រៀងជាមួយគ្នានាខែមករា ដោយទីស្តីការគណៈរដ្ឋមន្ត្រីថាជាឯកសារផ្លូវការដែលកំពុងតែត្រូវបានពិភាក្សាដេញដោលដោយរដ្ឋសភាជាតិជាមួយនឹងសំណើធ្វើវិសោធនកម្មជាច្រើនផ្សេងទៀតដែលស្នើឡើងក្នុងខែកន្លងមក ជាពិសេសឯកសារដែលត្រូវបានព្រមព្រៀងគ្នានៅវគ្គទីពីរនៃកិច្ចចរចាជាមួយនឹងអង្គការសហប្រជាជាតិ ។

នៅក្នុងអំឡុងពេលនៃកិច្ចចរចាធ្វើឡើងនៅក្នុងខែកក្កដាភាគីទាំងពីរយល់ស្របជាមួយគ្នាថា ខ្លួននឹងមិនផ្សព្វផ្សាយជាសាធារណៈនូវព័ត៌មានទាំងនេះទេ ពីព្រោះឯកសារដែលមានការយល់ព្រមរវាងភាគីទាំងពីរមិនទាន់មានតម្លៃជាឯកសារផ្លូវការនៅឡើយទេ វៀរលែង តែមានការអនុម័តពីរដ្ឋសភាជាតិកម្ពុជានិងមានការចុះហត្ថលេខារបស់ភាគីទាំងពីរទៅលើមាត្រាផ្សេងៗស្តីអំពីកិច្ចសហប្រតិបត្តិការរួមផង ។ នៅក្នុងកិច្ចប្រជុំលើកទីបួនជាមួយនឹងគណៈកម្មការនីតិកម្ម ទេសរដ្ឋមន្ត្រី សុខ អាន ដែលជាប្រធានក្រុមការងារបាននឹងកំពុងពិភាក្សាមួយមាត្រាម្តងៗទៅលើឯកសារធ្វើឡើងកាលពីខែមករា ព្រមទាំងសំណើវិសោធនកម្មចំណុចផ្សេងៗលើកឡើងដោយសមាជិកនៃគណៈកម្មការនីតិកម្មនិងយោបល់មួយចំនួនទៀតស្នើឡើងដោយគណបក្សនានារួមទាំងអង្គការក្រៅរដ្ឋាភិបាលផង ។

ដោយសារមានការពន្យារពេលដូចជាសកម្មភាពផ្សេងៗទៀតរបស់រដ្ឋាភិបាលដែរកិច្ចប្រជុំពិភាក្សាជាមួយនឹងគណៈកម្មការនីតិកម្មត្រូវបានផ្អាកនៅអំឡុងពេលទឹកជំនន់និងវិស្សមកាលរបស់រដ្ឋសភាជាតិ ។ ប៉ុន្តែវិស្សមកាលនឹងចប់ឆាប់ៗ ហើយសភាជាតិនឹងចាប់ផ្តើមការងាររបស់ខ្លួនឡើងវិញ ។ នៅតាមវេទិការផ្សេងៗលោកនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជាបានបញ្ជាក់ច្បាស់ថានេះជាបញ្ហាមួយក្នុងចំណោមបញ្ហាច្បាប់ដែលមានអទិភាពចម្បងៗផ្សេងទៀត ។

សង្ឃឹមថាការចុះផ្សាយនូវរបាយការណ៍ខុសរបៀបនេះនឹងមិនកើតឡើងជាថ្មីម្តងទៀតឡើយពីព្រោះរបាយការណ៍នេះមិនបានសាច់ការអ្វីឡើយបានត្រឹមតែធ្វើឲ្យមានការភ័ន្តច្រឡំប្របូកប្របល់តែប៉ុណ្ណោះ ហើយថែមទាំងរារាំងដល់ដំណើរការពង្រាងច្បាប់និងការអនុមត័នូវច្បាប់ជាតិសំខាន់ៗដែលមានសារៈប្រយោជន៍ចាំបាច់សម្រាប់ពលរដ្ឋកម្ពុជាទូទៅទៀតផង ។

(ប្រែសម្រួលក្រៅផ្លូវការដោយ ស្វ ប៊ុនស៊ួ)

# យុត្តិធម៌ដែលត្រូវបានពន្យារពេលនៅកម្ពុជា

**(តពីលេខមុន)** ទស្សនាវដ្តី ហ្វារអ៊ីស្ទើន អ៊ីកូណូមិក រីវយូ បានរាយការណ៍ថា កាលពីឆ្នាំ១៩៨៩ "មន្ត្រីសហរដ្ឋអាមេរិកមួយចំនួនបានព្រមានថាប្រសិនបើប្រទេសថៃបោះបង់ចោលនូវចលនាតស៊ូខ្មែរនិង សីហនុ ដែលជាមេដឹកនាំរបស់ចលនានេះ ដើម្បីជាប្រយោជន៍ក្នុងការធ្វើពាណិជ្ជកម្មជាមួយក្រុងភ្នំពេញ នោះប្រទេសថៃត្រូវតែលះបង់អ៊ីម៉្យាងធ្វើជាថ្នូរ" ។ បន្តិចក្រោយមកឯកអគ្គរដ្ឋទូតសហរដ្ឋអាមេរិកប្រចាំនៅប្រទេសថៃបានថ្លែងថាខ្មែរក្រហមមិនអាចត្រូវបានទាត់ចេញឲ្យនៅក្រៅរដ្ឋាភិបាលកម្ពុជានាពេលអនាគតទេ ។ រដ្ឋមន្ត្រីការបរទេសសហរដ្ឋអាមេរិកនៃរដ្ឋការលោក ប៊ូស លោក ជេម បេឃ័រ បានស្នើសុំឲ្យមានការដាក់បញ្ចូលខ្មែរក្រហមទៅក្នុងរដ្ឋាភិបាលកម្ពុជា ។

### កិច្ចព្រមព្រៀងទីក្រុងប៉ារីស

កត្តាមួយទៀតគឺសេចក្តីសម្រេចចិត្តក្នុងការរំកិលកិច្ចចរចាស្តីពីបញ្ហាកម្ពុជាពីវេទិកាតំបន់នៅទីក្រុងហ្សាកាតា ដែលមានការចូលរួមពីសំណាក់ប្រជាជាតិអាស៊ី-អាគ្នេយ៍ ឆ្ពោះទៅវេទិកាពិភពលោកនៅទីក្រុងប៉ារីសជំនួសវិញ ។ ក្នុងឆ្នាំ១៩៨៩ កិច្ចចរចាត្រូវបានពង្រីកកាន់តែធំឡើងដោយមានបញ្ចូលប្រទេសមហាអំណាច ។ វត្តមានរបស់ប្រទេសចិនបាននាំខ្មែរក្រហមត្រឡប់មកកណ្តាលឆាក ។

លក្ខន្តិកៈនៃកិច្ចចរចាដែលតម្រូវឲ្យមានមតិឯកច្ឆន្ទចំពោះរាល់កិច្ចព្រមព្រៀងនោះ ក៏បានធ្វើឲ្យខ្មែរក្រហមមានសិទ្ធិជំទាស់យ៉ាងមានប្រសិទ្ធភាពដែរ ។ ប៉ុល ពត បានប្រើសិទ្ធិនេះ ។ យោងតាមរបាយការណ៍របស់ខ្មែរក្រហមដែលចុះចូលជាមួយរដ្ឋាភិបាលកម្ពុជាដែលនិយាយថា ប៉ុល ពត បានប្រគល់របាយការណ៍នេះទៅឲ្យមេបញ្ជាការរបស់ខ្លួនកាលពីឆ្នាំ១៩៨៨ ។ ប៉ុល ពត បានបង្ហាញអំពីផែនការរបស់ខ្លួនក្នុងការពន្យារពេលការបោះឆ្នោតរហូតទាល់តែខ្លួនបានកាន់កាប់ប្រទេសកម្ពុជាទាំងស្រុង ។ ខៀវ សំផន ដែលជាគណៈប្រតិភូចរចារបស់ ប៉ុល ពត បាននិយាយថា "ពិភពលោកខាងក្រៅ នៅតែទាមទារឲ្យឈប់លេងនយោបាយដើម្បីបញ្ចប់សង្គ្រាមនៅកម្ពុជា ។ ខ្ញុំអាចបញ្ចប់សង្គ្រាមពេលណាក៏បានដែរឲ្យតែខ្ញុំចង់ពីព្រោះពិភពលោកខាងក្រៅកំពុងតែរង់ចាំខ្ញុំ ។ ប៉ុន្តែខ្ញុំត្រូវការពេលវេលាសម្រាប់ឲ្យសមមិត្តទាំងអស់គ្នាមានឱកាសក្នុងការបំពេញភារកិច្ចឲ្យចប់សព្វគ្រប់ស្រួលបួលសិន ។ បើមិនបញ្ចប់ខាងនយោបាយនិងយោធានោះវាជាការល្អ" ។

ក្នុងអំឡុងឆ្នាំ១៩៨៨-១៩៩១ មជ្ឈដ្ឋានទូទៅសង្កេតឃើញការរិះគន់ផ្នែកការទូតចំពោះអំពើប្រល័យពូជសាសន៍របស់ខ្មែរក្រហមបានចុះថយ ។ នៅឯសន្និសីទលើកទីមួយនៅហ្សាកាតាកាលពីថ្ងៃទី២៨ ខែកក្កដា ឆ្នាំ១៩៨៨ សេចក្តីប្រកាសចុងក្រោយរបស់ប្រធានសន្និសីទឥណ្ឌូនេស៊ីបានបញ្ជាក់អំពីការមូលមតិគ្នារបស់ប្រជាជាតិអាស៊ី-អាគ្នេយ៍ទៅលើការការពារមិនឲ្យមានការវិលត្រឡប់មកសាជាថ្មីនូវនយោបាយនិងការអនុវត្តអំពើប្រល័យពូជសាសន៍នៅកម្ពុជារបស់របប ប៉ុល ពត ។ ប៉ុន្តែនៅថ្ងៃទី៣ ខែកញ្ញា ឆ្នាំ១៩៨៩ មហាសន្និបាតរបស់អង្គការសហប្រជាជាតិបានសម្រាលការរួមមតិគ្នានេះមកត្រឹមតែ "នយោបាយនិងការអនុវត្តកាលពីអតីតកាលថ្មីៗដែលទើបតែកន្លងផុតទៅដែលត្រូវបានថ្កោលទោសជាសកល" ។ ក្រោយមកសំណើរបស់ប្រទេសអូស្ត្រាលី ខែកុម្ភៈ ឆ្នាំ១៩៩០ ដែលផ្អែកទៅលើផែនការរបស់អង្គការសហប្រជាជាតិបាននិយាយយោងដល់ត្រឹមតែថា "ការរំលោភសិទ្ធិមនុស្សនាអតីតកាលថ្មីៗដែលទើបតែកន្លងផុតទៅ" ប៉ុណ្ណោះ ។ ឯផែនការរបស់អង្គការសហប្រជាជាតិវិញបានសម្រាលនូវឃ្លានៅក្នុងកាលមូលមតិគ្នាកាលពីខែសីហា ឆ្នាំ១៩៩០ ដោយយល់ព្រមត្រឹមតែថា "នយោបាយ និងការអនុវត្តកាលពីអតីតកាល" ។ ប៉ុល ពត អាចនឹងទទួល "សិទ្ធិសេរីភាពនិងឱកាសស្មើគ្នាក្នុងការចូលរួមក្នុងដំណើរការបោះឆ្នោត" ដូចជាប្រជាជនកម្ពុជាទូទៅដែរ ។

កិច្ចព្រមព្រៀងទីក្រុងប៉ារីសត្រូវបានចុះហត្ថលេខាក្នុងទម្រង់

បែបនេះនៅឆ្នាំ១៩៩១ ។ ក៏ប៉ុន្តែសហរដ្ឋអាមេរិកនិងប្រទេសអូស្ត្រាលីបានសន្យានៅពេលកំពុងចុះហត្ថលេខាថា «យើងនឹងគាំទ្ររាល់កិច្ចខិតខំទាំងឡាយណាក្នុងការនាំយកមកកាត់ទោសនូវជនទាំងឡាយណាដែលទទួលខុសត្រូវចំពោះមហាឃាតកម្មនៅក្នុងអំឡុងទសវត្សរ៍ឆ្នាំ៧០ ប្រសិនបើរដ្ឋាភិបាលមានបំណងចង់ដើរតាមផ្លូវនេះ» ។

ស្ថិតនៅក្រោមការគ្រប់គ្រងរបស់អាជ្ញាធរបណ្ដោះអាសន្នអង្គការសហប្រជាជាតិនៅកម្ពុជាចន្លោះឆ្នាំ១៩៩១-១៩៩៣ ខ្មែរក្រហមត្រូវបានអនុញ្ញាតឲ្យមានវត្តមានផ្នែកនយោបាយរបស់ខ្លួននៅក្នុងទីក្រុងភ្នំពេញជាលើកទីមួយចាប់តាំងពីឆ្នាំ១៩៧៩មកដោយមានទីតាំងថ្មីនៅក្រោយព្រះបរមរាជវាំង ។ នៅក្រោមកិច្ចខិតខំប្រឹងប្រែងរបស់អង្គការសហប្រជាជាតិ ខៀវ សំផន និង សុន សេន ដែលជាប្រធាននិងជាឧបនាយករដ្ឋមន្ត្រីនៅក្នុងរបបប្រល័យពូជសាសន៍ ត្រូវបានបញ្ចូលទៅក្នុងក្របខ័ណ្ឌក្រុមប្រឹក្សាជាតិជាន់ខ្ពស់កម្ពុជាដែលជាអង្គការមួយតំណាងឲ្យអធិបតេយ្យភាពរបស់ប្រទេសកម្ពុជា ។ ទន្ទឹមពេលគ្នានោះដែរ គណៈកម្មការសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិក៏នឹងត្រូវពិចារណាអំពីពង្រាងដំណោះស្រាយស្ដីពីបញ្ហាកម្ពុជា ។ ពង្រាងដំណោះស្រាយនោះមាននិយាយអំពី «អំពើឃោរឃៅដែលឈានដល់កម្រិតអំពើប្រល័យពូជសាសន៍ដែលប្រព្រឹត្តឡើងជាច់ដោយឡែកនៅក្នុងអំឡុងពេលខ្មែរក្រហមកាន់កាប់» ហើយបានអំពាវនាវដល់គ្រប់រដ្ឋទាំងអស់ឲ្យ «ស៊ើបអង្កេតចាប់ខ្លួន ឬក៏នាំយកមកតុលាការដើម្បីកាត់ទោសនូវជនទាំងឡាយណាដែលទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មសង្គ្រាមដែលប្រព្រឹត្តឡើងនៅក្នុងទឹកដីកម្ពុជា និងទប់ស្កាត់ជនទាំងឡាយដែលទទួលខុសត្រូវចំពោះអំពើប្រល័យពូជសាសន៍ក្នុងអំឡុងឆ្នាំ១៩៧៥-១៩៧៩ មិនឲ្យមានការវិលត្រឡប់មកកាន់មុខតំណែងនៅក្នុងរដ្ឋាភិបាលកម្ពុជា» ។

ប៉ុន្តែ ប្រធាននៃគណៈកម្មការសិទ្ធិមនុស្សបានសម្រេចចិត្តមិនបញ្ចូលចំណុចនេះទៅក្នុងរបៀបវារៈទេក្រោយពីមានវាគ្មិននិយាយថាវានឹងមានការប៉ះពាល់ទៅដល់អង្គការសហប្រជាជាតិ ។ (១០ឆ្នាំក្រោយមកពង្រាងដដែលនេះត្រូវបានលើកមកដើម្បីបង្កើតការិយាល័យអង្គការសហប្រជាជាតិទទួលខុសត្រូវចំពោះការបញ្ចុះបញ្ចូលប្រទេសកម្ពុជាឲ្យគាំទ្រដល់នយោបាយថ្មីរបស់អង្គការសហប្រជាជាតិដែលចែងថា ខ្មែរក្រហមគួរតែត្រូវបាននាំយកមកកាត់ទោសចំពោះមុខតុលាការអន្តរជាតិ) ។

ទោះបីជាខ្មែរក្រហមបានទទួលផលប្រយោជន៍ពីការការពារតាមរយៈកិច្ចព្រមព្រៀងនិងកុងសង់ស៊ីសក៏ដោយ ក៏ខ្មែរក្រហមនៅតែបដិសេធមិនព្រមគោរពតាមដែរ ។ ខ្មែរក្រហមបានក្រាញមិនព្រមអនុវត្តបទឈប់បាញ់ ការដកអាវុធពីកងទ័ព ឬក៏រំសាយទ័ពឡើយ ។ មិនតែប៉ុណ្ណោះទៀតសោត ខ្មែរក្រហមបានបដិសេធមិនព្រមអនុញ្ញាតឲ្យអង្គការសហប្រជាជាតិមានវត្តមាននៅលើទឹកដីដែលខ្លួនកំពុងកាន់កាប់និងពង្រីក ក្នុងខណៈដែលភាគីនៃកិច្ចព្រមព្រៀងដទៃទៀតជាទូទៅគោរពបទឈប់បាញ់គ្នា ។ សភាពការណ៍បែបនេះបានអំណោយផលដល់ខ្មែរក្រហមក្នុងការកាប់ឈើលក់ទៅឲ្យថៃ ។

ខ្មែរក្រហមថែមទាំងធ្វើពហិការមិនព្រមចូលរួមក្នុងការបោះឆ្នោតដែលរៀបចំឡើងដោយអង្គការសហប្រជាជាតិនៅឆ្នាំ១៩៩៣ ហើយព្យាយាមធ្វើវិទ្ធង្សនារារាំងដល់ដំណើរការបោះឆ្នោតនេះ ។ ខ្មែរក្រហមមិនត្រឹមតែមិនបានចូលរួមទេ តែថែមទាំងបន្តយុទ្ធនាការប្រឆាំងនឹងរដ្ឋាភិបាលកម្ពុជាទៀតផងដែលជារដ្ឋាភិបាលចម្រុះរវាងអ្នករាជានិយមនិងជនកុម្មុយនិស្តដឹកនាំដោយ ហ៊ុន សែន ។ នៅឆ្នាំ១៩៩៤ ប្រទេសកម្ពុជាបានដាក់ខ្មែរក្រហមឲ្យនៅក្រៅច្បាប់ ។ ទើបតែបច្ចុប្បន្ននេះទេដែលសកម្មភាពរបស់អន្តរជាតិចាប់ផ្ដើមយឺតៗក្នុងការប្រឆាំងនឹងខ្មែរក្រហម ។

## ឆ្នាំ១៩៩៤ មកដល់បច្ចុប្បន្ន

នៅក្នុងឆ្នាំ១៩៩៤ សភាជាន់ទាបរបស់សហរដ្ឋអាមេរិកបានអនុម័តច្បាប់ប្រល័យពូជសាសន៍នៅកម្ពុជា ។ នេះជានយោបាយរបស់សហរដ្ឋអាមេរិកក្នុងការនាំយកជនដៃដល់ដែលប្រព្រឹត្តបទឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិនិងអំពើប្រល័យពូជសាសន៍នៅក្នុងប្រទេសកម្ពុជា ។ ក្រសួងការបរទេសសហរដ្ឋអាមេរិកបានសិក្សាទៅលើផ្នែកច្បាប់និងផ្ដល់ឥណទានដល់កម្មវិធីសិក្សាស្រាវជ្រាវអំពីអំពើប្រល័យពូជសាសន៍នៅកម្ពុជានៅសកលវិទ្យាល័យយែលដើម្បីប្រមែប្រមូលភ័ស្តុតាងជាប្រវត្តិសាស្ត្រ ។

នៅក្នុងឆ្នាំ១៩៩៧ មានសេចក្តីអំពាវនាវរួមគ្នាមួយធ្វើឡើងដោយសហនាយករដ្ឋមន្ត្រីកម្ពុជា សម្តេច ហ៊ុន សែន និងសម្តេចក្រុមព្រះ នរោត្តម រណឫទ្ធិ សុំឲ្យអង្គការសហប្រជាជាតិបង្កើតតុលាការមួយដើម្បីកាត់ទោសខ្មែរក្រហម ។ ជាលទ្ធផលតំណាងពិសេសរបស់អង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សនៅកម្ពុជាបាននាំយកនូវដំណោះស្រាយមួយតាមរយៈអង្គសន្និបាតរបស់អង្គការសហប្រជាជាតិដែលថ្កោលទោសចំពោះអំពើប្រល័យពូជសាសន៍ខ្មែរក្រហម ។ មួយឆ្នាំក្រោយមកអង្គការសហប្រជាជាតិក៏បានបញ្ជូនក្រុមអ្នកជំនាញការមួយក្រុមមកពិនិត្យភ័ស្តុតាងប្រឆាំងនឹងខ្មែរក្រហមនិងដើម្បីឲ្យយោបល់ថាតើគួរតែមានតុលាការដែរឬទេ ។

នៅក្នុងខែមីនា ឆ្នាំ១៩៩៩ របាយការណ៍របស់ក្រុមអ្នកជំនាញការត្រូវបានចេញផ្សាយដោយអគ្គលេខាអង្គការសហប្រជាជាតិ ។ របាយការណ៍នោះបានឲ្យយោបល់ថាគួរតែបង្កើតតុលាការកម្រិតអន្តរជាតិមួយ ប៉ុន្តែនៅទីក្រុងម៉ានីលនៃប្រទេសហ្វីលីពីន ឬទីក្រុងកង់បេរ៉ានៃប្រទេសអូស្ត្រាលី ឬអាចនៅទីក្រុងឡាអេ នៃប្រទេសហុល្លង់ មិនមែននៅក្នុងប្រទេសកម្ពុជាដែលអាចមានភ័ស្តុតាងនិងសាក្សីជាច្រើននោះឡើយ ។ នៅពេលទន្ទឹមគ្នានេះដែរ ទោះបីជា ប៉ុល ពត និង សុន សេន បានស្លាប់ទៅហើយក្តី ប៉ុន្តែមេដឹកនាំសេសសល់ដែលនៅរស់ទាំងប៉ុន្មានបានទម្លាក់អាវុធចុះចាញ់និងខ្លះទៀតត្រូវបានចាប់ខ្លួនអស់ហើយ ។

អ្វីដែលកើតឡើងនៅពេលនេះពិតជាពិបាកធ្វើការទស្សន៍ទាយកាលពីប្រាំឆ្នាំមុនណាស់ ។ ប្រទេសរុស្ស៊ី បារាំង អង់គ្លេសនិងសហរដ្ឋអាមេរិក សុទ្ធតែចង់ឲ្យមានតុលាការចំណែកឯប្រទេសចិនវិញនៅឈរម្នាក់ឯងគាំទ្រថានឹងមិនគាំទ្រឲ្យមានតុលាការទេ ។ តុលាការមួយអាចនឹងបង្កើតឡើងតាមរយៈសន្និបាតអង្គការសហប្រជាជាតិដែលនៅទីនោះចិនមិនអាចមានសិទ្ធិជំទាស់បានឡើយ ។

ការចរចាចេះតែបន្តមករហូតដល់សព្វថ្ងៃរវាងអង្គការសហប្រជាជាតិនិងរដ្ឋាភិបាលកម្ពុជាដែលកន្លងមកស្នើសុំឲ្យមានតុលាការអន្តរជាតិ ប៉ុន្តែឥឡូវបែរជាចង់ជំនុំជម្រះក្តីខ្មែរក្រហមដោយខ្លួនឯងទៅវិញ ។ ប្រទេសកម្ពុជាឥឡូវនេះកំពុងតែរៀបចំសំណុំរឿងចោទប្រកាន់ នួន ជា ខៀវ សំផន និងតាម៉ុកពីបទបានប្រព្រឹត្តអំពើប្រល័យពូជសាសន៍នៅកម្ពុជា ។ អតីតមេសន្តិសុខខ្មែរក្រហមឈ្មោះ កាំង ហ្កិចអៀវ ហៅ ឌុច ត្រូវបានចាប់ឃុំខ្លួននិងបញ្ជូនទៅតុលាការភ្នំពេញ ។

ប្រទេសកម្ពុជានិងអង្គការសហប្រជាជាតិនៅតែបន្តកិច្ចចរចាអំពីរឿងបង្កើតតុលាការ "ចម្រុះ" ជាតិនិងអន្តរជាតិ ។ អ្វីដែលនឹងអាចកើតឡើងគឺអាចជាការទទួលខុសត្រូវចំពោះមុខច្បាប់តាមទម្រង់ផ្សេងៗ ។ ប៉ុន្តែគួររំឭកដែរថាចាប់តាំងពីឆ្នាំ១៩៧៩ ដល់ឆ្នាំ១៩៩៨ សហគមន៍អន្តរជាតិចម្រុះបានសង្គ្រោះខ្មែរក្រហមពីការជម្រះទោសចំពោះមុខតុលាការពេលដែលខ្មែរក្រហមនៅជាការគំរាមកំហែងផ្នែកយោធាចំពោះប្រទេសកម្ពុជានៅឡើយហើយ ប៉ុល ពត នៅមានជីវិតប្រឈមមុខនឹងអ្នកចោទប្រកាន់ដែលជាជនរងគ្រោះរបស់ខ្លួននោះ ។

**វ៉ែន ឃៀងនិន**



ប៉ុល ពត ពីរសប្តាហ៍មុនថ្ងៃស្លាប់

ថតផ្តល់ឲ្យដោយ Roger Pin

# ការសងសឹកមកពីជំនាន់ប៉ុលពត

ចំពោះអ្នកក្រៅនិងជារឿយៗខ្លួនយើងផ្ទាល់តែម្តង តែងប្រមើលមើលថា ប្រទេសកម្ពុជាមើលទៅហាក់ដូចជាមានសន្តិភាពគ្រប់គ្រាន់អ្វីចឹង ។ ប្រជាកសិករក៏ចេះតែខំប្រឹងបង្កបង្កើនផលខួបប្រាំង ខួបវស្សា ។ អ្នកនេសាទត្រីរស់នៅលើទូក... ។ វិថីដ៏ធំទូលាយនៅរាជធានីភ្នំពេញមានដើមឈើបញ្ចេញផ្កាស្រស់បំព្រង ។ សម្រស់និងភាពស្ងប់ស្ងាត់បែបនេះយើងអាចមើលឃើញតាមរយៈចក្ខុវិស័យ ។ ប៉ុន្តែអ្វីដែលនៅខាងក្នុងមិនអាចមើលឃើញហើយលាក់ទុកជាយូរមកហើយនោះគឺ «គុំ» ។ «គុំ» គឺជាពាក្យខ្មែរសំដៅដល់គំនិតចង់សងសឹក បើនិយាយឲ្យច្បាស់ជាងនេះទៀត «គុំ» គឺជាកំហឹងយូរអង្វែងដែលនាំទៅដល់ការសងសឹកលើសពីអ្វីដែលជាការខូចខាតពីដើមដំបូងទៅទៀត ។ ប្រសិនបើខ្ញុំវាយអ្នកឯងមួយដៃ អ្នកឯងរង់ចាំប្រាំឆ្នាំទើបវាយខ្ញុំសងវិញពីក្រោយខ្នងក្នុងទីងងឹត ។ របៀបនេះ ហៅថា «គុំ»...ប្រជាជនកម្ពុជាយល់ច្បាស់ណាស់អំពីពាក្យថា «គុំ» នេះ ។ «នេះជាជំងឺឆ្លងដែលចេះតែរាលដាលឥតឈប់ឈរនៅក្នុងព្រលឹងជាតិយើង ។» នេះជាសម្តីរបស់លោក ហាំង ង៉ោ ។ ជីកស្មៅត្រូវជីកទាំងឫស (សុភាសិតរបស់ខ្មែរក្រហម) ។

ទាំងជនជាតិខ្មែរទាំងបរទេសបានចោទសួរថា «ហេតុអ្វីបានជាខ្មែរក្រហមសម្លាប់មនុស្សអស់ច្រើនម្ល៉េះនៅក្នុងជំនាន់ ប៉ុល ពត?» ។ ចំពោះសំណួរនេះពិតជាពិបាកឆ្លើយណាស់ ប៉ុន្តែយើងត្រូវពិនិត្យទៅលើដើមហេតុផ្សេងៗជាច្រើនចាប់ពីសង្គ្រាមស៊ីវិលរហូតដល់ការកម្ទេច «ខ្មែរ» របស់ ប៉ុល ពត ។ ដើមហេតុសំខាន់ផ្សេងទៀតគឺទ្រឹស្តីរបស់ខ្មែរក្រហមដែលលាយច្របល់ចូលគ្នាជាមួយនឹងគំនិត គុំកួន សងសឹក និងផ្ចាញ់ផ្ចាលជាទម្លាប់ដែលមិនល្អរបស់ខ្មែរ ។

ឥឡូវយើងនាំគ្នាគិតមើលពីសង្គមខ្មែរមុន និងក្នុងជំនាន់ ប៉ុល ពត ។ តាមការស្តែងឲ្យឃើញតាមរយៈការបះបោរនៅសំឡូតចលនាខ្មែរក្រហមធ្វើឲ្យប្រជាកសិករខ្សត់ក្រមួយក្តាប់តូចតែចេះកើនឡើងព្រមទាំងកូនចៅមានការពេញចិត្ត ។ អ្នកខ្លះអត់មានដីធ្លីធ្វើចម្ការច្បារដំណាំ ខ្លះទៀតជំពាក់បំណុលវ័ណ្ឌក ឬមានតែដីមួយដុំតូច ។ គ្មានអ្វីគួរឲ្យឆ្ងល់ឡើយថា ចំនួនប្រជាក្រីក្រនេះចេះតែកើនឡើងជាលំដាប់ នៅពេលដែលមានសង្គ្រាមស៊ីវិលចេះតែធ្ងន់ធ្ងរទៅ ហើយការទម្លាក់គ្រាប់បែករបស់សហរដ្ឋអាមេរិកចេះតែខ្លាំងទៅៗ ។ ភាគច្រើននៃប្រជាកសិករខ្សត់ក្រទាំងនេះមានកំហឹងយ៉ាងធំចំពោះអ្នកមាននិងអ្នកទីក្រុង ដូច្នេះហើយបានជាខ្លួនងាយនឹងទទួល



ទារុណកម្មចងព្យួករដើម្បីសម្លាប់ក្រោយរំដោះភ្លាមៗ ឃើញនៅក្នុងគុកទួលស្លែងទីក្រុងភ្នំពេញ

យកនូវមនោគមវិជ្ជាតស៊ូវណ្ណៈរបស់ខ្មែរក្រហម ។

បុព្វហេតុដ៏ធំដែលនាំមានការមិនពេញចិត្តដល់ប្រជាជនក្រីក្រគឺការដែលអ្នកមានទ្រព្យសម្បត្តិស្តុកស្តម្ភមានចរិតឈ្លើយដូចជាអ្នកខ្លះធ្វើបាបអ្នកក្រ ឲ្យតម្លៃទាប មើលងាយមើលថោកដល់អ្នកក្រធ្វើឲ្យបាក់មុខបាក់មាត់ ។ ការចងចាំនូវភាពអាម៉ាស់ទាំងអស់នេះបាន "កប់ទុកក្នុងចិត្ត" ហើយនាំដល់ការប៉ុនប៉ងសងសឹកវិញបើខ្លួនមានឱកាស ។ ការមិនពេញចិត្តទីពីររបស់អ្នកក្រចំពោះអ្នកមានគឺថាអ្នកក្រមានការឈឺចាប់ដោយសារការជិះជាន់កេងប្រវ័ញ្ចរបស់អ្នកមានទ្រព្យនិងអ្នកមានអំណាចបុណ្យសក្តិ ។ ក្នុងខណៈដែលប្រជាកសិករខ្មែរជាច្រើនជំពាក់បំណុលវ័ណ្ឌកចំពោះអ្នកឲ្យខ្ចីប្រាក់ដែលយកការប្រាក់លើសពី១០ភាគរយ ។ ជារឿយៗប្រជាកសិករដែលទ័លក្រតែងតែត្រូវបានបង្ខំឲ្យធ្វើការឲ្យម្ចាស់ដីដែលខ្លួនជំពាក់បំណុល ។ ហើយសូម្បីតែអ្នកដែលមានដីធ្វើស្រែចម្ការហើយក៏នៅតែមានការច្រណែនចំពោះអ្នកមានដែរ ព្រោះខ្លួនទទួលផលបានតិចពេកបើប្រៀបធៀបទៅនឹងអ្នកមាន ។

បុព្វហេតុចុងក្រោយមួយទៀតគឺបញ្ហាសង្គ្រាមស៊ីវិលដែលបណ្តាលឲ្យប្រជាជនក្រីក្រមានការខឹងសម្បារយ៉ាងខ្លាំង ។ ក្រោយពេលខ្លួនត្រូវបានទាត់ចេញពីតំណែងនិងចងសម្ព័ន្ធជាមួយនឹងខ្មែរក្រហម ពេលនោះមានសេចក្តីប្រកាសអំពាវនាវដល់ប្រជាជនខ្មែរនៅតាមជនបទឲ្យកាន់អាវុធងើបឈរឡើងប្រឆាំងនឹងពួកក្បត់និងខុសច្បាប់របស់រដ្ឋាភិបាល លន់ ណុល ។ ជនដែលខ្មែរក្រហមម្នាក់ឈ្មោះ ខែល (មិនមែនឈ្មោះពិតប្រាកដ) បានរំឭករឿងដើមថា ខ្លួនព្រមទាំងយុវជនជាច្រើននាក់ទៀតនៅក្នុងភូមិស្រុកជាមួយគ្នាបានចូលខ្មែរក្រហមដោយសារតែ "ប្រជាជនស្រលាញ់ស្តេច ហើយខ្លួនឯងផ្ទាល់ជាប្រធានរណសិរ្សរបស់ខ្មែរក្រហមទៀតផង" ។ ការទម្លាក់គ្រាប់បែករបស់សហរដ្ឋអាមេរិកក៏កាន់តែបង្កឲ្យមានការមិនពេញចិត្តថែមទៀត ។ នៅក្នុងអំឡុងពេលសង្គ្រាម អាមេរិកាំងបានទម្លាក់គ្រាប់បែកអស់ជាង៥សែន ៤ម៉ឺនតោន មកលើទឹកដីកម្ពុជា បណ្តាលឲ្យមានការស្រុតចុះផ្នែកសេដ្ឋកិច្ចនិងមនុស្សស្លាប់អស់រហូតដល់មួយសែនប្រាំម៉ឺននាក់ព្រមទាំងបណ្តាលឲ្យប្រជាជនរាប់ម៉ឺននាក់បង្ខំចិត្តចាកចេញពីលំនៅដ្ឋាន ។ ប្រជាជនខ្មែរជាច្រើនបានចូលធ្វើខ្មែរក្រហមដោយសារតែកំហឹងចំពោះការបំផ្លិចបំផ្លាញផ្ទះសម្បែងនិងការស្លាប់របស់អ្នកដែលជាទីស្រលាញ់របស់ខ្លួន ។ ខែល ពន្យល់យ៉ាងក្បោះក្បាយថា "អាមេរិកាំងបានទម្លាក់គ្រាប់បេ-៥២ជាច្រើនគ្រាប់ ។ ការទម្លាក់នេះបណ្តាលឲ្យប្រជាជនមានការឈឺចាប់យ៉ាងខ្លាំងហើយចង់វាយប្រឆាំងនឹងរបប លន់ ណុល" ។

មនោគមវិជ្ជារបស់ខ្មែរក្រហមបានស្រូបយកនូវការខឹងសម្បារទាំងអស់ដែលកើតចេញពីបុព្វហេតុទាំងប៉ុន្មានដែលបានរៀបរាប់មកខាងលើហើយដាក់ឈ្មោះថា "ការតស៊ូវណ្ណៈ" និងយកប្រជាជនទីក្រុងជាមុខសញ្ញារបស់ខ្លួនក្នុងការសងសឹក ។ វគ្គសិក្សានយោបាយរបស់ខ្មែរក្រហមផ្តោតសំខាន់ទៅលើការបណ្តុះគំនិត "លះបង់និងចងកំហឹង" ។ អ្នកដែលត្រូវបានជ្រើសរើសចូលទៅក្នុងចលនានេះត្រូវបានបង្រៀនអំពីលទ្ធិកុម្មុយនិស្តជាមូលដ្ឋានដែលថាវណ្ណៈអធនកើតឡើងដោយសារតែការជិះជាន់របស់វណ្ណៈនាយទុន ។ អតីតឆ្មាំនៅមន្ទីរសួរចម្លើយនិងធ្វើទារុណកម្មគុកទួលស្លែងបាននិយាយថាខ្មែរក្រហម "បានប្រាប់យើងថាអ្នកក្រគឺក្រដោយសារតែអ្នកមាន ហើយអ្នកមានគឺមានដោយសារតែអ្នកក្រ ។ ខ្មែរក្រហមចង់ឲ្យយើងមានកំហឹងចំពោះការជិះជាន់នេះ ហើយសម្អប់និងប្រយុទ្ធយ៉ាងក្លាហានប្រឆាំងនឹងវណ្ណៈនាយទុនសក្តិភូមិ ម្ចាស់ដី ដែលជាអ្នកមានធ្វើបាបអ្នកក្រ" ។

ការប្រជុំទិតៀននិងស្វ័យទិតៀន ការឃោសនា ការគោរពវិន័យនិងចម្រៀងបដិវត្តន៍ ពាក្យស្លោក និងការសម្តែងផ្សេងៗគឺរៀបចំឡើងក្នុងគោលបំណងបណ្តុះ "សតិអារម្មណ៍" ដែលនាំឲ្យមាន "កំហឹងឆេះរោលចំពោះខ្មាំងសត្រូវ" ។ គំនិតតស៊ូវណ្ណៈបានរំឭកដល់ពាក្យវប្បធម៌ចាស់ពីបុរាណ "អ្នកតស៊ូ" ដែល "ធ្វើការតស៊ូប្រឆាំងនឹងខ្មាំងសត្រូវយ៉ាងអង់អាចក្លាហាន" ។ អ្នកក្រត្រូវតែមានកំហឹងនិងវាយប្រយុទ្ធយ៉ាងអង់អាចក្លាហានប្រឆាំងនឹងពួកឈ្លានពាន ។ ដូច្នេះពេលដែលខ្លួនចូលខ្មែរក្រហម ឈ្មោះ ខែល ផាយចាប់យកនូវមនោគមវិជ្ជាកុម្មុយនិស្តណាស់ ។ ខែល បាននិយាយថា "វគ្គសិក្សានយោបាយមានអប់រំឲ្យយើងមានកំហឹងចំពោះវណ្ណៈជិះជាន់ ។ រាល់ពេលណាក៏និយាយអំពីរឿងនេះដែរ" ។ មនុស្សដែលមានវ័យក្មេងនិងមានចរិតត្រឹមត្រូវដែល

ម៉ៅ បានប្រៀបធៀបទៅនឹង "ក្រដាសសស្អាត" ដោយនឹងទទួលយកនូវការឃោសនារបៀបនេះណាស់ ។ ពេលត្រឡប់មកពីរៀននយោបាយមកអ្នកចូលថ្មីជាច្រើនត្រូវបានពិពណ៌នាថាជាអ្នកមានការលះបង់មានវិន័យល្អ និង "ដាច់ខាត" ។

មនោគមវិជ្ជារបស់ខ្មែរក្រហមគឺចង់ផ្តោតទៅលើ "កំហឹងឆេះរោល" របស់ជនដាច់ខាតចំពោះប្រជាជនទីក្រុងដែលជាកន្ទែងរបស់ពួកមូលធន ។ គោលដៅនេះមិនពិបាកនឹងសម្រេចទេដោយសារតែមានប្រជាជនភាគច្រើនមានការមិនពេញចិត្តចំពោះអ្នកមាននៅទីក្រុងដែលមើលងាយមើលថោកចំពោះពួកខ្លួនរស់នៅដោយសុខស្រួល គ្រាំទ្រដល់ លន់ ណុល ដែលជាអ្នកផ្តួលរំលំសម្តេច សីហនុ និងគាំទ្រដល់ការទម្លាក់គ្រាប់បែកយ៉ាងសុះដីនៅតាមជនបទនៃប្រទេសកម្ពុជា ។ ការឃោសនារបស់ខ្មែរក្រហមមានលើកឡើងពាក្យស្លោកដូចជា "ដើមនៅឯស្រែ ផ្លែនៅឯផ្សារ" ដើម្បីបញ្ឆេះកំហឹងប្រជាជនតាមជនបទឲ្យខឹងនឹងប្រជាជនទីក្រុងដែលទ្រព្យសម្បត្តិនិងអំណាចរបស់ខ្លួនបានមកពីការជិះជាន់កេងប្រវ័ញ្ចទៅលើអ្នកក្រ ។ មន្ត្រីរដ្ឋាភិបាលមួយរូបបានធ្វើការបំភ្លឺថា "ពួកខ្មែរក្រហមធ្វើការសម្អាតសតិអារម្មណ៍ប្រជាជនដើម្បីឲ្យប្រជាជនជឿថារបប លន់ ណុល ជារបបមូលធន ហើយថាអ្នកទ័លក្រដែលត្រូវបានជិះជាន់កេងប្រវ័ញ្ចត្រូវតែរើបម្រះយ៉ាងអង់អាចក្លាហានប្រឆាំងនឹងរបប លន់ ណុល" ។ មិនតែប៉ុណ្ណោះទីក្រុងត្រូវបានចាត់ទុកថាជាកន្លែងពុករលួយនិងគ្មានសីលធម៌ក្រោមឥទ្ធិពលរបស់ពួកបរទេស ។ ម្យ៉ាងវិញទៀតនៅតាមទីក្រុងប្រជាជនរស់នៅដោយសុខស្រួលនៅក្នុងផ្ទះដ៏ប្រណិតៗ ស៊ីឆ្ងាញ់ផឹកស្រា លេងស្រី ចំណែកឯប្រជាជនក្រីក្រនៅតាមជនបទវិញគិតតែពីចំទិតគួថធ្វើស្រែចម្ការច្បារដំណាំគ្មានពេលស្រាកស្រាន្តដើម្បីយកផលានុផលមកចិញ្ចឹមជីវិត ។ លើសពីនេះទៀតអ្នកនៅទីក្រុងជាពួក "បរិវារអាមេរិក" ហើយភាគច្រើនជាជនជាតិចិន និងវៀតណាម ។ ប្រជាជនទីក្រុងមិនត្រឹមតែជាពួកមូលធនកេងប្រវ័ញ្ចតែប៉ុណ្ណោះទេតែថែមទាំងមិនមែនជា "ខ្មែរសុទ្ធ" ទៀតផងដែលជាមុខសញ្ញាខ្មាំងត្រូវ "កម្ទេច" ។ ដោយលើកឡើងអំពីការមិនពេញចិត្ត និងផ្តោតទៅលើទីក្រុង មនោគមវិជ្ជាខ្មែរក្រហមបានជំរុញយ៉ាងមានប្រសិទ្ធភាពឲ្យវណ្ណៈក្រីក្រនៅតាមជនបទមានគំនុំចំពោះប្រជាជនទីក្រុង ។

កំហឹងវណ្ណៈនេះបានបណ្តាលឲ្យមានអំពើឃោរឃៅនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។ នៅពេលចប់សង្គ្រាម "កំហឹងដែលត្រូវបានអុជអាល" បានឆេះសន្ធោសន្ធៅពេញទំហឹង ។ ឧទាហរណ៍ នៅខេត្តបាត់ដំបងខ្មែរក្រហមប្រែជា "ច្រលើសបើសនិងច្រឡោងខាម" ក្រោយពីថ្ងៃរំដោះប្រទេសភ្លាម ហើយក្រោយមកក៏បានសារភាពថាខ្លួនបានធ្វើដោយកំហឹងខ្លាំងពេកទប់មិនបានចំពោះអ្នក "សង្គមចាស់" ។ មានម្នាក់និយាយថា "យើងខឹងខ្លាំងណាស់ពេលដែលចេញពីព្រៃភ្លាម ហើយមិនចង់ទុកជីវិតឲ្យឡើយ












សូម្បីតែកូនក្នុងអង្រឹងក៏មិនចង់ទុកដែរ" ។ កំហឹងសងសឹកនេះគឺផ្តោតសំខាន់ទៅលើរដ្ឋាភិបាលនិងយោធារបស់ លន់ ណុល ។ មេដឹកនាំត្រូវបានគៀងប្រមែប្រមូលយកមកសម្លាប់ចោល ហើយបំណងរួមចម្បងគឺចង់វែកមុខខ្មាំងដែលជាមេធំៗ ។ អ្នកទីក្រុងដែលកំពុងតែជម្លៀសចេញពីទីក្រុងត្រូវបានឈ្លេចសួរពីប្រវត្តិរូបយ៉ាងល្អិតល្អន់ (ពីមុនធ្វើអី នៅឯណា...?) ។ អ្នកណា

និយាយប្រាប់ត្រង់ត្រូវបានយកទៅសម្លាប់ចោល ។ អ្នកខ្លះទៀតត្រូវបានបញ្ជូនទៅ «អប់រំ» នៅក្នុងជំរំពិសេស ឬក៏ឲ្យរស់នៅជាមួយប្រជាជននៅតាមជនបទធ្វើស្រែចម្ការ ។ ប្រជាជនរាប់ម៉ឺននាក់ត្រូវបានសម្លាប់នៅក្នុងពេលធ្វើវិសុទ្ធកម្មលើកទីមួយ ។

ខ្មែរក្រហមមិនចង់បញ្ចប់ការសងសឹករបស់ខ្លួនទេ តែផ្ទុយទៅវិញកាន់តែបញ្ឆេះកំហឹងថែមទៀតក្រោយពីពេលកើតឡើងនូវអំពើឃោរឃៅដំបូង ។ ហាំង ង៉ោ ដែលជាប្រជាជន «ថ្មី» ក្នុងរបបកម្ពុជាប្រជាធិបតេយ្យបានរំឭកអំពីរបាំឃោសនារបស់ខ្មែរក្រហមថា កម្មាភិបាលដែលមានសំលៀកបំពាក់ឯកសណ្ឋានបានគក់ទ្រូងរបស់ខ្លួនហើយស្រែកបន្ទរយ៉ាងខ្លាំងកងរំពងថា «ឈាមត្រូវសងដោយឈាម...ឈាមសងដោយឈាម ។ បើអ្នកឯងសម្លាប់យើង យើងនឹងសម្លាប់អ្នកឯងវិញ» ។ យើងជាប្រជាជនថ្មីនៅម្ខាង ហើយខ្មែរក្រហមនៅម្ខាងនៅក្នុងកំឡុងពេលសង្គ្រាមស៊ីវិល...ដាទូទៅខ្មែរក្រហមបានស្រែកប្រកាសថាខ្លួននឹងធ្វើការសងសឹកវិញ ។ តាមពិតឈាមពណ៌ក្រហមគឺជាប្រធានបទយ៉ាងទូលំទូលាយមួយរបស់ខ្មែរក្រហមក្នុងការឃោសនាហើយជាពាក្យសម្រាប់ដាស់តឿនឲ្យប្រជាជនមានការសងសឹក ។ ចម្រៀងជាតិបានរៀបរាប់មូលហេតុយ៉ាងច្រើនដែលនាំដល់ការចងកំហឹងមិនចេះចប់មិនចេះហើយ ។ នៅក្នុងសុន្ទរថាកាលពីថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ១៩៧៧ ប៉ុល ពត បានចង្អុលបង្ហាញថា «ឈាមស្រែកស្បែកហៅត្រូវបានបញ្ចូលទៅក្នុងចម្រៀងជាតិយើងហើយ ។ ល្បះនិងពាក្យនីមួយៗបង្ហាញពីធាតុពិតនៃការតស៊ូរបស់ប្រជាជនយើង ។ ឈាមនេះបានប្រែក្លាយទៅជាវណ្ណៈនិងកំហឹង» ។ ស្រដៀងគ្នានេះដែរ ទង់ជាតិរបស់ខ្មែរក្រហមមានពណ៌ក្រហម ហើយអមដោយចម្រៀងមួយបទដែលតែងតែច្រៀងនៅរាល់ពេលមុនប្រជុំមានចំណងជើងថា «ទង់ជាតិក្រហម» ។ ***(នៅមានត)***

**អាធ្មិច ហ៊ីនគុន**



# ការលើកលែងទោស



ប្រទេសកម្ពុជាជាប្រទេសមួយដែលល្បីលើឆាកអន្តរជាតិ ខាង «ការរួចទោស» ។ ឧក្រិដ្ឋកម្មដ៏យង់ឃ្នងបំផុតដែលប្រព្រឹត្ត ជាពិសេសដោយខ្មែរក្រហមកាលពីមុន ក្នុងអំឡុងពេលនិងក្រោយ របបកម្ពុជាប្រជាធិបតេយ្យមិនទាន់ត្រូវបានផ្ដន្ទាទោសនៅឡើយទេ រហូតមកដល់សព្វថ្ងៃនេះ ។ សេចក្ដីថ្លែងការណ៍ជា «ផ្លូវការ» មួយក្នុងចំណោមសេចក្ដីថ្លែងការណ៍នានាស្ដីអំពីភាពរួចទោសមាន និយាយអំពីការលើកលែងទោសចំពោះ អតីតសមាជិកខ្មែរក្រហម ។ ការលើកលែងទោសក្រោមច្បាប់ស្ដីអំពីការដាក់ឲ្យនៅក្រៅច្បាប់ចាប់ពីឆ្នាំ១៩៩៤ និងការលើកលែងទោសដែលផ្ដល់ដោយព្រះរាជក្រឹត្យចំពោះ អៀង សារី បានធ្វើឲ្យមតិសាធារណៈមានការភ្ញាក់ផ្អើលខ្លាំងបំផុត ។ ការដែលថារដ្ឋាភិបាលបានឲ្យឧក្រិដ្ឋជនដ៏ឃោរឃៅឈ្មោះ នួន ជា និង ខៀវ សំផន នៅមានសេរីភាពដើរហើរដល់សព្វថ្ងៃនេះ គឺជាបទដ្ឋានព្រឹត្តន័យនៃការលើកលែងទោសដែលទោះជាយ៉ាងណាក្ដីមិនទទួលការប្រកាសជាផ្លូវការឡើយ ហើយមិនទាន់បញ្ជាក់ច្បាស់ជាចំហថានឹងជម្រះក្ដីចំពោះឧក្រិដ្ឋជនទាំងនេះឡើយ ។

នៅក្នុងអត្ថបទនេះ ខ្ញុំនឹងលើកយកមតិមួយចំនួនទាក់ទងនឹងមូលបទស្ដីអំពីការលើកលែងទោស ។ បន្ទាប់មកនឹងធ្វើការពិភាក្សាអំពីទំនាក់ទំនងរវាងការលើកលែងទោសនិងកាតព្វកិច្ចក្រោមច្បាប់អន្តរជាតិ ។

ជាគោលការណ៍ «ការលើកលែងទោស» អាចទាក់ទងទៅនឹងបាតុភូតពីរផ្សេងគ្នា÷

- ការលើកលែងទោស មុនពេលការជំនុំជម្រះក្ដី ។
- ការលើកលែងទោស ក្រោយពេលការជំនុំជម្រះក្ដីដែលចេញជាលទ្ធផលនៃការកម្រិតទោស ។

ក្នុងភាសាអង់គ្លេស អង្គហេតុទាំងពីរនេះត្រូវបានហៅថា “Amnesty” និង “Pardon” ។ ប៉ុន្តែផ្ទុយមកវិញនៅក្នុងភាសាខ្មែរ អង្គហេតុទាំងពីរនេះត្រូវបានប្រើដោយពាក្យតែមួយប៉ុណ្ណោះ (...) ។ ខ្ញុំនឹងធ្វើការពន្យល់ដោយសង្ខេបពីការខុសប្លែកគ្នាដូចខាងក្រោម ÷

ការលើកលែងទោស មុនពេលមានការជំនុំជម្រះក្តីអាចចាត់ទុកថាជាការសន្យាដោយរដ្ឋាភិបាលចំពោះបុគ្គល ឬក៏ក្រុមណាមួយដែលនឹងរួចខ្លួនពីការជំនុំជម្រះក្តី ទៅលើបទឧក្រិដ្ឋ (ណាមួយ) ដែលជាទូទៅស្ថិតក្នុងលក្ខខណ្ឌជាក់លាក់ផ្សេងៗ ។ ដូច្នេះឧក្រិដ្ឋកម្មនឹងមិនត្រូវបានលាតត្រដាងបញ្ជាក់នៅក្នុងតុលាការឡើយ ហើយទោសកំហុសរបស់ជនដែលពាក់ព័ន្ធក៏មិនបានបញ្ជាក់ចំពោះមុខច្បាប់ដែរ ។ ទង្វើបែបនេះធ្វើឲ្យជនរងគ្រោះមិនពេញចិត្តសោះឡើយ ។ ការលាតត្រដាងពីការពិតនៅក្នុងអង្គតុលាការពិតជាធ្វើឲ្យជនរងគ្រោះឬអ្នកដែលរស់រានមានជីវិតពីឧក្រិដ្ឋកម្មមានការធូរស្រាលក្នុងចិត្ត ។ គំរូមួយនៃការលើកលែងដែលមានលក្ខណៈរបៀបនេះគឺមានចែងនៅក្នុងមាត្រាទី៥ នៅក្នុងច្បាប់ស្តីពីការដាក់ក្រុមកម្ពុជាប្រជាធិបតេយ្យនៅក្រៅច្បាប់ឆ្នាំ១៩៩៤ ។ មាត្រានេះផ្តល់នូវភាពរួចទោសពីការជំនុំជម្រះទោសផ្នែកព្រហ្មទណ្ឌចំពោះបុគ្គលដែលឆ្លើយត្រូវនឹងលក្ខខណ្ឌដែលចែងនៅក្នុងច្បាប់÷ “ច្បាប់នេះអនុគ្រោះ ទុកពេល៦ខែក្រោយពីចូលជាធរមានឲ្យជនជាសមាជិកអង្គការនយោបាយ ឬជាកម្លាំងយោធានៃក្រុម “កម្ពុជាប្រជាធិបតេយ្យ” វិលត្រឡប់មករួមរស់ក្រោមការគ្រប់គ្រងរបស់រាជរដ្ឋាភិបាលក្នុងព្រះរាជាណាចក្រកម្ពុជាដោយមិនយកទោសពៃរ៍ចំពោះបទល្មើសដែលខ្លួនបានប្រព្រឹត្ត ។ ប៉ុន្តែ “៧” ស្តីអំពីការលើកលែងទោសមិនអាចអនុវត្តចំពោះមេដឹកនាំខ្មែរក្រហមបានឡើយ (មាត្រា ៦) ។



ប៉ុល ពត

រូបថតផ្តល់ឲ្យដោយ Roger Pin

ការលើកលែងទោសក្រោយពេលកម្រិតទោសមានន័យថាជនដៃដល់ដែលប្រព្រឹត្តបទល្មើសមិនចាំបាច់ទទួលទោសឡើយ ។ ឧទាហរណ៍ដែលមានលក្ខណៈបែបនេះគឺព្រះរាជក្រឹត្យ ខែកញ្ញា ឆ្នាំ១៩៩៦ ដែលក្នុងនោះ អៀង សារី ត្រូវបានផ្តល់ការលើកលែងទោសចំពោះការដាក់ទោសអស់មួយជីវិតដែលធ្វើឡើងដោយកំបាំងមុខនៅឆ្នាំ១៩៧៩ ។ តាមការសង្កេតរបស់ខ្ញុំឃើញថាការជំនុំជម្រះក្តីនេះត្រូវបានចាត់ទុកថាជាការជំនុំជម្រះក្តីដែលធ្វើឡើងឲ្យតែល្អមើល ហើយមិនបំពេញនូវតម្រូវការតាមនីតិវិធីឡើយ ។ ឧទាហរណ៍ជាក់ស្តែង មេធាវីការពារក្តីរបស់ អៀង សារី ផ្ទាល់ក៏ចង់ឲ្យកូនក្តីរបស់ខ្លួនត្រូវបានកាត់ទោសប្រហារជីវិតដែរ ។

នៅក្នុងមាត្រាទី២៧ នៃរដ្ឋធម្មនុញ្ញព្រះមហាក្សត្រមានអំណាចផ្តល់ការលើកលែងទោស ។ មាត្រានេះចែងថា "ព្រះមហាក្សត្រមានរាជ្យសិទ្ធិបន្ធូរបន្ថយនិងលើកលែងទោស" ។

អត្ថបទចេញផ្សាយនៅក្នុងសារពត៌មានភ្នំពេញប៉ុស្តិ៍បានទាញហេតុផលថា ការសន្មតថាគ្មានទោសដែលចែងនៅក្នុងមាត្រាទី៣៨នៃរដ្ឋធម្មនុញ្ញការពារមិនឲ្យមានការលើកលែងទោសដែលចែងនៅក្នុងមាត្រាទី២៧ ។ ប៉ុន្តែមាត្រារដ្ឋធម្មនុញ្ញដូចដែលបានរៀបរាប់ខាងលើមិនបានបញ្ជាក់ច្បាស់ថាព្រះមហាក្សត្រអាចត្រឹមតែមានអំណាចក្រោយពិរុទ្ធភាពរបស់ជនណាម្នាក់ត្រូវបានចេញដោយសាលក្រមតុលាការ ហើយដូចដែលបានឃើញនៅលើស្រាប់ ការផ្តល់នូវការលើកលែងទោសក្នុងន័យទប់ស្កាត់មិនឲ្យមានការជម្រះទោសគឺជាលិខិតូបករណ៍ដែលតែងតែត្រូវបានយកមកប្រើជាញឹកញាប់ដោយហេតុផលយុទ្ធសាស្ត្រ ។ ខ្ញុំអាចនិយាយបានថាប្រការផ្សេងៗដែលចែងនៅក្នុងមាត្រាទី៣៨អាចការពារតែជនជាប់ចោទតែប៉ុណ្ណោះ ដូច្នេះមានន័យថាមាត្រានេះមិនអនុញ្ញាតឲ្យមានការលើកលែងទោសដល់ជនជាប់ចោទមុនពេលចេញសាលក្រមរបស់តុលាការឡើយ ។ ប៉ុន្តែទាំងអស់នេះគឺជាសុទ្ធតែរឿងទាក់ទងនឹងការបកស្រាយរដ្ឋធម្មនុញ្ញទាំងអស់ ។ ឧទាហរណ៍ នៅសហរដ្ឋអាមេរិកលោកប្រធានាធិបតី ហ្វដ បានបកស្រាយអំណាចរដ្ឋធម្មនុញ្ញក្នុងការផ្តល់ការលើកលែងទោសថាមានលក្ខណៈមិនកំណត់ដាច់ណាត់ ធ្វើដូច្នេះគឺដើម្បីឲ្យរដ្ឋធម្មនុញ្ញនេះអាចមានប្រយោជន៍ចំពោះចុងចោទមុនពេលដែលមានសាលក្រមបញ្ជាក់ពីកម្រិតទោសចេញពីតុលាការ ។ ផ្អែកលើមូលដ្ឋានច្បាប់នេះ លោក ហ្វដ គិតថាខ្លួនគាត់មានអំណាចក្នុងការផ្តល់ការលើកលែងទោសចំពោះអតីតប្រធានាធិបតី រីឆាតនិចសុនដោយសង្គ្រោះគាត់ពីដំណើរការចោទប្រកាន់ជាសាធារណៈពីសំណាក់សភាជាន់ទាបក្រោយពីរឿងអាស្រូវរបស់ វតធ័រវេងហ្គេត (វ៉ូបឺតសុន ទំព័រ២៣៩) ។

ប៉ុន្តែទោះជាអំណាចរបស់ព្រះមហាក្សត្រដែលស្ថិតក្នុងមាត្រាទី២៧ជាអ្វីក៏ដោយ ការលើកលែងទោសតែមួយដងគឺមិនត្រូវគ្នាទៅនឹងកាតព្វកិច្ចនៃច្បាប់អន្តរជាតិក្នុងការជម្រះទោសឡើយ ។

**ការលើកលែងទោសនិងកាតព្វកិច្ចក្រោមច្បាប់អន្តរជាតិ**

មិនខុសពីប្រទេសដទៃទៀតឡើយ ប្រទេសកម្ពុជាគឺជាភាគីមួយនៅក្នុងសន្ធិសញ្ញាជាច្រើន ។ អនុសញ្ញាទាំងអស់នេះបង្កើតបានជាកាតព្វកិច្ចដែលរដ្ឋមួយមិនអាចចៀសផុតនិងត្រូវតែអនុវត្តច្បាប់របស់ខ្លួន ។ ច្បាប់នេះកើតចេញមកពីអនុសញ្ញាទីក្រុងវីយែនស្តីពីច្បាប់សន្ធិសញ្ញាឆ្នាំ១៩៧៦ (ដែលចូលជាធរមាននៅថ្ងៃទី២៧ ខែមករា ឆ្នាំ១៩៨០) និងចុះហត្ថលេខាដោយប្រទេសកម្ពុជាមួយដែរ ។ មាត្រាទី២៦ នៃអនុសញ្ញានេះមានគោលការណ៍មួយដែលហៅថា Pacta sunt servanda: "រាល់សន្ធិសញ្ញានីមួយៗដែលចូលជាធរមានរួចហើយដាក់កាតព្វកិច្ចដល់ភាគីហត្ថលេខី ហើយត្រូវតែបានប្រតិបត្តិដោយសុទ្ធចិត្ត" ។

**មាត្រាទី២៧ នៃអនុសញ្ញានេះចែងថា ៖**

"ភាគីនៃសន្ធិសញ្ញានេះមិនអាចបញ្ជាក់ថាខ្លួនបានអនុវត្តនូវ "ខ" ផ្សេងៗនៃច្បាប់ផ្ទៃក្នុងឡើយ ដរាបណាភាគីនោះមិនបានអនុវត្តនូវសន្ធិសញ្ញាមួយទេ..." ។ ភាគីជាច្រើនបង្កើតនូវយុត្តាធិការទាក់ទងទៅនឹងការរំលោភលើបទដ្ឋានដែលមានរួមបញ្ចូលនៅក្នុងសន្ធិសញ្ញាទាំងនេះ ។ ប៉ុន្តែក្រោយសង្គ្រាមលោកលើកទីពីរ អំណាចក្នុងការកាត់ទោសដោយផ្អែកលើមូលដ្ឋាននៃបទដ្ឋានអន្តរជាតិបានរីកលូតលាស់យ៉ាងលឿនតាមទិសដៅកាតព្វកិច្ចក្នុងការជម្រះទោស ។ ដូច្នេះត្រូវមានកាតព្វកិច្ចក្នុងការជម្រះទោសជនដែលដល់ចំពោះឧក្រិដ្ឋកម្មមួយចំនួនដែលសហគមន៍អន្តរជាតិចាត់ទុកថាជាឧក្រិដ្ឋកម្មនៃច្បាប់អន្តរជាតិ ។ ចំពោះប្រការមួយចំនួននៃអនុសញ្ញាទីក្រុងវីយែន ដែលបានលើកឡើងខាងលើកាតព្វកិច្ចនេះមានផលវិបាកចំពោះការផ្តល់ការលើកលែងទោសដោយរដ្ឋាភិបាលក្នុងស្រុកមួយ ។ ឧទាហរណ៍ដាក់ស្តែងច្បាប់ឬព្រះរាជក្រឹត្យដែលផ្តល់ការលើកលែងទោស "មុនពេល" ការជម្រះក្តីនិងការកំណត់ទោសចំពោះជនជាប់ចោទដែលដល់ កើតមានឡើងប្រហែលជាមានការផ្ទុយគ្នាទៅនឹងកាតព្វកិច្ចច្បាប់អន្តរជាតិក្នុងការជម្រះក្តីដែលត្រូវប្រើជំនួសដោយច្បាប់ក្នុងស្រុកវិញ ។ ដូច្នេះក្នុងកាលៈទេសៈខ្លះ ការផ្តល់នូវការលើកលែងទោសមិនអាចធ្វើទៅបានឡើយ ។

ខាងក្រោមនេះខ្ញុំសូមធ្វើការពិនិត្យដោយសង្ខេបទៅលើបញ្ហាថាតើពេលណាទើបច្បាប់អន្តរជាតិតម្រូវឲ្យមានការជម្រះ

ទោស ។ ខ្ញុំសូមលើកយកតែចំណុចមួយចំនួនប៉ុណ្ណោះដែលទាក់ទងដល់តុលាការជំនុំជម្រះទោសពួកខ្មែរក្រហម ។ កាតព្វកិច្ចក្នុងការកាត់ទោសអាចកើតមានបានក្រោមសន្ធិសញ្ញាផ្សេងៗ និងក្រោមអ្វី ដែលហៅថា "ច្បាប់ទំនៀមទម្លាប់អន្តរជាតិ" ។

## កាតព្វកិច្ចនៃសន្ធិសញ្ញា

កាតព្វកិច្ចនៃសន្ធិសញ្ញាក្នុងការជំនុំជម្រះក្តីបទឧក្រិដ្ឋកម្ម ចែកចេញជាបីជំពូក ÷

១) សន្ធិសញ្ញាមួយចំនួនកំណត់ច្បាស់ពីកាតព្វកិច្ចរបស់ភាគីរដ្ឋក្នុងការជំនុំជម្រះទោស ឬដាក់ទោសដល់ជនដែលប្រព្រឹត្តបទល្មើសដែលចូលទៅក្នុងឧក្រិដ្ឋកម្មក្រោមច្បាប់អន្តរជាតិ ។

២) ការបកស្រាយផ្នែកច្បាប់ស្តីពីសន្ធិសញ្ញាសិទ្ធិមនុស្សបង្ហាញច្បាស់ថាភាគីរដ្ឋដែលខកខានមិនបានធានាឲ្យប្រាកដ និងគោរពសិទ្ធិការពារភាពថ្លៃថ្នូររបស់បុគ្គល ប្រសិនបើភាគីទាំងនេះមិនធ្វើការស៊ើបអង្កេតរឿងក្តីជំនុំជម្រះទោសនិងសងជំងឺចិត្តឲ្យបានត្រឹមត្រូវពិតប្រាកដទេ ។

៣) សិទ្ធិក្នុងការទាមទារសំណងជម្រះការខូចខាតដែលមាននៅក្នុងលិខិតូបករណ៍សិទ្ធិមនុស្សបានចែងពីកាតព្វកិច្ចក្នុងការស៊ើបអង្កេតរឿងក្តី ជំនុំជម្រះរឿងក្តី និងសងការខូចខាត ។ (ណាមីរុត-អារីហ្សាៈ ដកស្រង់ពីសន្ធិសញ្ញាអន្តរជាតិស្តីពីកាតព្វកិច្ចក្នុងការស៊ើបអង្កេតជំនុំជម្រះក្តីនិងសងការខូចខាត ទំព័រទី២៨) ។

ខាងក្រោមនេះ ខ្ញុំនឹងនិយាយជាសំខាន់អំពីកាតព្វកិច្ចដំបូង និងខ្លាំងជាងគេដែលត្រូវបានបញ្ចូលទៅក្នុងសន្ធិសញ្ញាចំនួនពីរ ដែលក្នុងនោះប្រទេសកម្ពុជាជាភាគីមួយដែរ នៅក្នុងសម័យកម្ពុជាប្រជាធិបតេយ្យ ។

## ១) អនុសញ្ញាទីក្រុងហ្សឺណែវ

ប្រទេសកម្ពុជាគឺជាភាគីមួយនៅក្នុងអនុសញ្ញាទីក្រុងហ្សឺណែវ ធ្វើឡើងនៅខែសីហា ឆ្នាំ១៩៤៩ ។ អនុសញ្ញានេះអនុវត្តចំពោះ "ករណីសង្គ្រាមប្រកាស ឬក៏ក្នុងទម្រង់ជាជម្លោះប្រដាប់អាវុធដែលកើតឡើងរវាងភាគីក្នុងកិច្ចសន្យាពីរឬច្រើន ទោះបីជារដ្ឋដែលកើតសង្គ្រាមមិនត្រូវបានទទួលស្គាល់ដោយរដ្ឋណាមួយក៏ដោយចុះ" ។

អនុសញ្ញាទាំងបួនខាងក្រោមនេះគឺការពារដល់ក្រុមមនុស្សមួយចំនួននៅក្នុងពេលមានជម្លោះប្រដាប់អាវុធ ÷

- កងកម្លាំងប្រដាប់អាវុធដែលរងរបួសនិងមានជំងឺនៅក្នុងសមរភូមិ
- កងកម្លាំងប្រដាប់អាវុធដែលរងរបួស មានជំងឺ និងលិចនាវានៅសមុទ្រ
- ឈ្លើយសឹក
- ជនស៊ីវិលនៅពេលមានកលយុគ

អនុសញ្ញាទាំងបួនស្ទើរតែមានប្រការប្រហាក់ប្រហែលគ្នា ដែលផ្តោតទៅលើកាតព្វកិច្ចរបស់ប្រទេសចុះកិច្ចសន្យានៅពេលមាន "បទល្មើសធ្ងន់ធ្ងរ" ។ ក្នុងករណីនេះមានប្រការមួយចែងថា "ភាគីចុះកិច្ចសន្យានីមួយៗត្រូវតែស្ថិតនៅក្រោមកាតព្វកិច្ចក្នុងការស្វែងរកជនដែលត្រូវបានចោទប្រកាន់ថាបានប្រព្រឹត្តបទល្មើស ឬក៏បានចេញបញ្ជាឲ្យប្រព្រឹត្តបទល្មើសធ្ងន់ធ្ងរហើយត្រូវនាំយកជនទាំងនេះទៅតុលាការរបស់ប្រទេសខ្លួន ។

ការរំលោភធ្ងន់ធ្ងរទាក់ទងនឹងប្រការដែលរៀបរាប់ខាងលើគឺមានដូចខាងក្រោម "ប្រសិនបើអំពើទាំងនេះត្រូវបានប្រព្រឹត្តប្រឆាំងនឹងក្រុមមនុស្ស និងទ្រព្យសម្បត្តិដែលការពារដោយអនុសញ្ញា÷ ការសម្លាប់ដោយចេតនា ការធ្វើទារុណកម្មឬអំពើអមនុស្សធម៌ដូចជាយកមនុស្សទៅពិសោធន៍ជាលក្ខណៈជីវសាស្ត្រ ការបង្កឲ្យមានការឈឺចាប់ឬរងរបួសធ្ងន់ធ្ងរចំពោះរាងកាយសុខភាព ការបំផ្លិចបំផ្លាញនិងការរឹបអូសទ្រព្យសម្បត្តិ ដែលកើតឡើងដោយការប្រើមធ្យោបាយយោធាដែលមិនចាំបាច់ និងធ្វើឡើងដោយខុសច្បាប់និងការធ្វេសប្រហែស" ។

ដោយផ្អែកលើពង្រាងច្បាប់ស្តីអំពីការបង្កើតតុលាការវិសាមញ្ញ ឧក្រិដ្ឋកម្មសង្គ្រាមមានការទាក់ទងនឹងដែនសមត្ថកិច្ចរបស់តុលាការ ។ ដោយសារក្នុងអំឡុងពេលនៃការកាន់កាប់ប្រទេសរបស់កម្ពុជាប្រជាធិបតេយ្យមានជម្លោះប្រដាប់អាវុធជាមួយនឹងប្រទេសវៀតណាម (និងប្រទេសមួយចំនួនទៀត) ហាក់ដូចជាសបញ្ជាក់ថា អនុសញ្ញាទាំងនេះអនុវត្តបានចំពោះអំពើជាច្រើនដែលកើតឡើងនៅក្នុងសម័យកាលនោះ ។ ការដែលថាឧក្រិដ្ឋកម្មដែលចូលក្នុងជាបទល្មើសធ្ងន់ធ្ងរដែលត្រូវបានប្រព្រឹត្តរួចមកហើយនោះ មានលក្ខណៈជាក់ស្តែងមិនអាចប្រកែកបាន ។

ការដាក់កម្រិតទោសចំពោះបទឧក្រិដ្ឋកម្មសម្រាប់សមាជិកខ្មែរក្រហមដែលធ្វើឡើងមុនពេលតុលាការកើតឡើងរបៀបនេះពិតជារឿងដែលយើងគួរតែគិតពិចារណា ។

ទាក់ទងនឹងបទដ្ឋានអធិបញ្ញានៅក្នុងអនុសញ្ញាក្នុងការជម្រះទោស ការកាត់ក្តី ដែលកើតឡើងមុនពេលមានតុលាការហើយចុងចោទទាមទារឲ្យមានការលើកលែងទោសគឺវាផ្ទុយទៅនឹងច្បាប់អន្តរជាតិ ហើយបញ្ហានេះមិនអាចយកទៅពិចារណាបានទេ ។

២) អនុសញ្ញាស្តីពីការការពារ និងការដាក់ទណ្ឌកម្មចំពោះបទឧក្រិដ្ឋប្រល័យពូជសាសន៍ដែលធ្វើឡើងតាំងពីឆ្នាំ១៩៤៨ (ចូលជាធរមាននៅឆ្នាំ១៩៥១) បានចាត់អំពើខាងក្រោមនេះជាបទឧក្រិដ្ឋ ÷

### មាត្រា III

- អំពើប្រល័យពូជសាសន៍
- ការសមគំនិតក្នុងការប្រព្រឹត្តអំពើប្រល័យពូជសាសន៍
- ការបង្កដោយផ្ទាល់និងជាសាធារណៈឲ្យមានការប្រព្រឹត្តអំពើប្រល័យពូជសាសន៍
- ការប៉ុនប៉ងប្រព្រឹត្តអំពើប្រល័យពូជសាសន៍
- ការចូលដៃចូលជើងក្នុងអំពើប្រល័យពូជសាសន៍

អនុសញ្ញានេះមានចែងជាច្រើនប្រការទាក់ទងនឹងកាតព្វកិច្ចរបស់ភាគីអនុសញ្ញាដែលមានដូចខាងក្រោមនេះ ÷

### មាត្រា IV

បុគ្គលណាដែលបានប្រព្រឹត្តអំពើប្រល័យពូជសាសន៍ឬអំពើណាមួយដែលបានរៀបរាប់នៅក្នុងមាត្រា៣ខាងលើនឹងត្រូវផ្តន្ទាទោស ទោះបីបុគ្គលនោះជាអ្នកដឹកនាំដែលមានការទទួលខុសត្រូវស្របតាមរដ្ឋធម្មនុញ្ញក្តី ជាអ្នករដ្ឋការក្តី ឬជាឯកជនក្តី ។

### មាត្រា V

ភាគីទាំងឡាយមានភារកិច្ចអនុម័តតាមក្របខ័ណ្ឌនៃរដ្ឋធម្មនុញ្ញរៀងៗខ្លួននូវច្បាប់ជាចាំបាច់ដើម្បីធ្វើឲ្យបទបញ្ញត្តិទាំងឡាយនៃអនុសញ្ញានេះមានប្រសិទ្ធភាព និងជាពិសេសដើម្បីធ្វើឲ្យមានប្រសិទ្ធភាពដល់ទណ្ឌកម្មនានាដែលត្រូវធ្វើចំពោះជនដែលបានប្រព្រឹត្តអំពើប្រល័យពូជសាសន៍ ឬអំពើណាមួយទៀតដែលបានរៀបរាប់នៅក្នុងមាត្រា III ខាងលើ ។

### មាត្រា VI

បុគ្គលទាំងឡាយណាដែលជាប់ចោទពីបទប្រល័យពូជសាសន៍ ឬអំពើណាមួយផ្សេងទៀតដែលបានរៀបរាប់នៅក្នុងមាត្រាខាងលើត្រូវតែទទួលការជំនុំជម្រះទោសដោយតុលាការដែលមានសមត្ថកិច្ចរបស់រដ្ឋណាដែលអំពើនោះត្រូវបានប្រព្រឹត្តឡើងលើទឹកដីរបស់ខ្លួន ឬក៏ដោយតុលាការព្រហ្មទណ្ឌអន្តរជាតិដែលនីតិក្រម (ទម្រង់ការច្បាប់) របស់ខ្លួនត្រូវបានភាគីទាំងអស់យល់ព្រមទទួលស្គាល់ ។

តាមគំនិតរបស់ខ្ញុំ គ្មានអ្វីគួរឲ្យសង្ស័យទៀតទេថា មេដឹកនាំខ្មែរក្រហមត្រូវតែបានចោទប្រកាន់ពីបទប្រល័យពូជសាសន៍ឬបទឧក្រិដ្ឋណាមួយដែលមាននៅក្នុងមាត្រាIII ។ ដូចដែលបានបង្ហាញតាមរយៈមាត្រាមួយចំនួនខាងលើឃើញថាមានកាតព្វកិច្ចជាក់លាក់ក្នុងការនាំយកជនជាប់ចោទពីបទប្រល័យពូជសាសន៍មកតុលាការនិងផ្តន្ទាទោសជននោះប្រសិនបើត្រូវបានរកឃើញថាមានកំហុសពិតមែន ។ ដូច្នេះការលើកលែងទោសតាមលក្ខណៈច្បាប់ឬមិនមានលក្ខណៈច្បាប់ក្តី ចំពោះឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ផ្ទុយទៅនឹងអនុសញ្ញាទាំងស្រុង ។ ប្រសិនបើចុងចោទម្នាក់ក្នុងចំណោមចុងចោទដទៃៗទៀតលើកយកហេតុផលឲ្យមានការលើកលែងទោសចំពោះខ្លួន ព្រះរាជអាជ្ញាត្រូវតែមានជំហរមួយថាភាពផ្ទុយគ្នារវាងការលើកលែងទោសនេះទៅនឹងច្បាប់អន្តរជាតិមានន័យថាការចែងច្បាប់លើកលែងទោសមិនអាចយកមកធ្វើការពិចារណាបានឡើយ ។ **(នៅមានត)**

**យ៉ន ខាន់ គ្រីនថិន**

## ទ្រឹស្តីខ្មែរក្រហម

**◆ យើងសន្សឹមសន្តិភាព ក៏ប៉ុន្តែចក្រពត្តិនិយមវីវរួសច្បាំងគ យើងជាច់ខាតមិនចុះចាញ់ ធ្វើសង្គ្រាមហើយចាំកសាង។**

**◆ ស្លាប់ដើម្បីផលប្រយោជន៍ប្រជាជនមានទម្ងន់ជាងភ្នំព្រះសុមេរុទៅទៀត ស្លាប់ដើម្បីពួកមូលធន សក្តិភូមិនិងពួកប្រតិកិរិយា មានទម្ងន់មិនបានស្លាបក្ងានផង។**

(ដកស្រង់ចេញពីសៀវភៅញុក ទំព័រទី៦០)

**(ផ្នែកមុខ)** រូបភាពរបស់ក្រសួងឃោសនាការ ព័ត៌មាន និងវប្បធម៌(ផ្នែកភាពយន្ត) នៃរដ្ឋកម្ពុជា



(ផ្នែកក្រោយ)

- កងទ័ព និង ប្រជាជនទាំងមូល ក្រុមសាមគ្គីគ្នាជាធ្លុងមួយ ធ្វើមួយ ខាយឱយបរាជ័យរាល់ឧបាយកលដ៏ពិសពុល របស់ពួកឈ្លានពានិយមអនុត្តរភាពនិយមចិន និងពួកក្បត់ ប៉ុល ពត-អៀង សារី ។
- គ្រប់គ្រួសារ និងជនទាំងឡាយត្រូវចូលប្រព្រឹត្តស្រ័យបង្ក បង្កើតផល ស្បៀងអាហារ និងភោជនាហារ ។
- លើកកំពស់ស្មារតី ប្រុងប្រយ័ត្ន មិនចាញ់បោកពាក្យ ឃោសនារបស់ពួក ប៉ុល ពត-អៀង សារី ។
- កម្ពុជានិងវៀតណាម សាមគ្គីគ្នាគឺឈ្នះបំបែកបំបាក់សាមគ្គី គឺក្រុមបរាជ័យ ។

# ថ្ងៃចងកំហឹង

ទិវាចង កំហឹងប្រារព្ធឡើងនៅថ្ងៃទី២០ ខែឧសភា បេះតែ បន្តដើរតួយ៉ាងសំខាន់នៅក្នុងសង្គមកម្ពុជាបច្ចុប្បន្ន ។ ជាទូទៅ ទិវាចងកំហឹងត្រូវបានប្រារព្ធឡើងដើម្បីរំឭកឡើងវិញ និងពង្រឹង ការចងចាំនៅក្នុងអារម្មណ៍ឈឺចាប់របស់ប្រជាជនកម្ពុជាក្នុងរបប កម្ពុជាប្រជាធិបតេយ្យឬសម័យ ប៉ុល ពត (១៩៧៥-១៩៧៩) ។ ដោយមានការគាំទ្រផ្តួចផ្តើមពីរដ្ឋាភិបាលនៃសាធារណរដ្ឋ ប្រជាមានិតកម្ពុជា នៅក្នុងដើមទសវត្សរ៍ឆ្នាំ៨០ ទិវាចងកំហឹងថ្ងៃ ២០ ឧសភា មានការចូលរួមពីប្រជាជនបីជំពូក÷ ទីមួយអ្នកដែល ស្លាប់ក្នុងអំឡុងរបបខ្មែរក្រហម ទីពីរអ្នកដែលនៅរស់រានមានជីវិត ពីរបបខ្មែរក្រហម និងទីបីគឺក្រុមជាតិដែលកំពុងតែចាប់ផ្តើម

កសាងជារូបរាងសាជាថ្មីក្រោយឆ្នាំ១៩៧៩ ។

ថ្ងៃ២០ ខែឧសភា ឆ្នាំ១៩៧៦ ត្រូវបានចាត់ទុកជាទូទៅថាជាថ្ងៃអបអរកំណើតសហករណ៍ដែលជានយោបាយរបស់មេដឹកនាំខ្មែរក្រហម ។ សេចក្ដីសម្រេចចិត្តនេះហើយដែលនាំឲ្យមានផលវិបាកអកុសលដល់ប្រព័ន្ធដីស្រែចម្ការនិងប្រជាជនកម្ពុជាទាំងមូល ។ ការសម្រេចចិត្តឲ្យមានសហការូបនីយកម្មនិងការបង្កឲ្យមានការស្លាប់បាត់បង់ជីវិតដោយសារគ្រោះទុរ្ភិក្សនិងការបាក់កម្លាំងត្រូវបានយល់ជាទូទៅ (ដោយរដ្ឋាភិបាលសាធារណរដ្ឋប្រជាមានិតកម្ពុជានិងរដ្ឋាភិបាលក្រោយៗទៀត) ថាជារឿងប្រវត្តិសាស្ត្រនិងមនោគមវិជ្ជាដែលក្នុងនោះខ្មែរក្រហមបានបំប្លែងពីជនបដិវត្តន៍ឲ្យទៅជារបបមួយដែលផ្ដាច់ការ ។ ការវិភាគផ្នែកប្រវត្តិសាស្ត្រថ្ងៃទី២០ ខែឧសភា ឆ្នាំ១៩៧៦ យល់ថាសម័យកាលបន្ទាប់ពីកាលបរិច្ឆេទនេះគឺកើតចេញពីគំនិតនិងអំពើរបស់ ប៉ុល ពត និងបក្ខពួកខ្លួន ។ ប៉ុន្តែគំនិតនេះនិងឆ្នាំដែលសន្មតថាមានការសម្រេចចិត្ត ធ្វើឲ្យមានការច្រឡំគ្នា ។ ឧទាហរណ៍ ព្រឹត្តិបត្រសារព័ត៌មានកម្ពុជាសរសេរជាភាសាអង់គ្លេសចេញផ្សាយនៅថ្ងៃទី២១ ខែឧសភា ឆ្នាំ១៩៨៨ សរសេរថា "ថ្ងៃទី២០ ខែឧសភា ឆ្នាំ១៩៧៥ បានក្លាយទៅជាថ្ងៃចងកំហឹងទូទាំងប្រទេសក្នុងប្រវត្តិសាស្ត្រនៃប្រទេសកម្ពុជាប្រឆាំងនឹងរបប ប៉ុល ពត ពីព្រោះថាគ្រាន់តែប៉ុន្មានថ្ងៃក្រោយពីការកាន់អំណាចរបស់វាប៉ុណ្ណោះ ពួក ប៉ុល ពត បានកំណត់យកថ្ងៃនេះជាថ្ងៃនៃការចាប់ផ្ដើមយុទ្ធនាការប្រល័យពូជសាសន៍ដែលធ្វើឲ្យប្រជាជនកម្ពុជាស្លាប់អស់រាប់លាននាក់" (អេស. ប៉េ. កា ២១ ឧសភា ១៩៨៨ ទំព័រ៣) ។

នៅក្នុងរបាយការណ៍ថ្មីៗនេះតាមបណ្ដាញផ្សាយព័ត៌មានផ្សេងៗនិយាយថា ថ្ងៃ២០ ឧសភា ត្រូវបានយល់ជាទូទៅថាជាថ្ងៃកំណើតរបស់ ប៉ុល ពត ប៉ុន្តែអាជ្ញាធរផ្នែកប្រវត្តិសាស្ត្របានប្រានចោលយ៉ាងមានប្រសិទ្ធភាពនិងជាសាធារណៈនូវការអះអាងបែបនេះ ។

នៅក្នុងសម័យសាធារណរដ្ឋប្រជាមានិតកម្ពុជានិងរដ្ឋកម្ពុជា (១៩៧៩-១៩៨៩និង១៩៨៩-១៩៩១) ថ្ងៃ២០ឧសភា ជាថ្ងៃបុណ្យជាតិមួយយ៉ាងសំខាន់ដែលត្រូវបានរៀបចំយ៉ាងត្រឹមត្រូវ ។ ទិវានេះត្រូវបានប្រារព្ធឡើងនៅទីក្រុងភ្នំពេញ ទីរួមខេត្តនិងភូមិឃុំ ទូទាំងប្រទេសកម្ពុជា ។ ក្រោយពីមានការចុះហត្ថលេខាលើកិច្ចព្រមព្រៀងសន្តិភាពនៅទីក្រុងប៉ារីសក្នុងឆ្នាំ១៩៩១ រវាងភាគីនយោបាយកម្ពុជាដែលមានជម្លោះនឹងគ្នាមក ការប្រារព្ធទិវាចងកំហឹង "២០ឧសភា" លែងក្លាយជាបុណ្យជាតិជាផ្លូវការទៀតហើយ ។ ប៉ុន្តែកាលពីឆ្នាំ១៩៩៨, ១៩៩៩ និង២០០០ "២០ឧសភា" ត្រូវបានរំឭកឡើងវិញដោយសាលាក្រុងភ្នំពេញ និងប្រជាជនច្រើនកកកុញនៅតាមបូជនីយដ្ឋាននានាជាពិសេសនៅមណ្ឌលឧក្រិដ្ឋកម្មបឹងជើងឯកព្រមទាំងកន្លែងមួយចំនួនទៀតនៅក្នុងក្រុងភ្នំពេញ ។ ការផ្លាស់ប្ដូរក្នុងការប្រារព្ធទិវាចងកំហឹង ២០ឧសភា នៅក្នុងប្រវត្តិសាស្ត្រកម្ពុជាបច្ចុប្បន្ន បានក្លាយទៅជាចំណុចសំខាន់នៃប្រធានបទនេះ ។ នៅក្នុងការប្រារព្ធទិវាចងកំហឹងថ្ងៃ២០ឧសភា មានពិធីសាសនានិងវប្បធម៌ជាច្រើន ។ តាមការមើលឯកសារជាច្រើននៅមជ្ឈមណ្ឌលឯកសារកម្ពុជាទាក់ទងនឹងការប្រារព្ធទិវាចងកំហឹង "២០ឧសភា" ចាប់ពីឆ្នាំ១៩៨៦ ដល់ឆ្នាំ១៩៩១ យើងអាចបង្កើតជារូបភាពជាទូទៅដែលទាក់ទងនឹងការអនុវត្តនយោបាយនៅពេលបច្ចុប្បន្ននិងនៅក្នុងអតីតកាលដ៏ព្រឺព្រួចតាមរយៈព្រឹត្តិការណ៍ថ្ងៃ២០ ឧសភា ។

ក្នុងអំឡុងពេលនៃការគ្រប់គ្រងរបស់របបសាធារណរដ្ឋកម្ពុជានិងរដ្ឋកម្ពុជា ការប្រារព្ធទិវា ២០ឧសភា គឺជាផ្នែកមួយនៃនយោបាយផ្លូវការរបស់រដ្ឋ ហើយសកម្មភាពនៅថ្ងៃប្រារព្ធពិធីនេះត្រូវបានសហការដោយរណសិរ្ស (រណសិរ្សសាមគ្គីកសាងការពារមាតុភូមិកម្ពុជា) ដោយមានការសហការជាមួយនឹងក្រសួងពាក់ព័ន្ធនានាជាពិសេសក្រសួងដែលទទួលខុសត្រូវផ្នែកវប្បធម៌ ។ ចំពោះអាជ្ញាធរខេត្ត ស្រុក និងភូមិ រណសិរ្សបានចេញញត្តិថា កន្លែងដែលសមរម្យសម្រាប់ប្រារព្ធទិវាចងកំហឹង ២០ឧសភា រួមមានកន្លែងសម្លាប់ កន្លែងធ្វើទារុណកម្ម កន្លែងកប់ខ្មោច ឬក៏ការដ្ឋានបង្ខំឲ្យប្រជាជនធ្វើការងារក្នុងរបបកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) ។ នៅក្នុងឆ្នាំ១៩៩០ រោងចក្រ សាលារៀន មន្ទីរពេទ្យ និងសហគ្រាសផ្សេងៗនៅតាមទីរួមខេត្ត ត្រូវបានណែនាំឲ្យធ្វើជាបដាពាក្យស្លោកនិងខិត្តប័ណ្ណថ្កោលទោសឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងដោយរបប ប៉ុល ពត ។ បដាទាំងអស់

និងវិត្តបណ្ណផ្សេងៗត្រូវបានសាធារណជនកាន់ដង្ហែឆ្ពោះមកអនុមិទ្ទីង និងកន្លែងប្រារព្ធពិធីដទៃទៀតដើម្បីឈរបង្ហាញនៅមុខបូជនីយដ្ឋាន (សេចក្តីណែនាំរៀបចំប្រារព្ធទិវាចងកំហឹង ២០ឧសភា ឯកសារតម្កល់នៅមជ្ឈមណ្ឌលឯកសារកម្ពុជាលេខ៣៣១) ។

នៅពេលប្រារព្ធទិវាចងកំហឹង ២០ឧសភា "អ្នកតំណាងជនរងគ្រោះ" បានឡើងមកបកអាក្រាតមុខ និងថ្កោលទោសអំពើឧក្រិដ្ឋកម្មរបស់ពួក ប៉ុល ពត ដែលកើតឡើងចំពោះខ្លួន ពោលគឺឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ និងដោយកម្លាំងសេសសល់របស់ខ្មែរក្រហមក្រោយឆ្នាំ១៩៧៩ ។ ឯកសារពិស្តារមកពីអាជ្ញាធរភ្នំពេញនិងបណ្តាស្រុកផ្សេងៗមានបញ្ជាក់ពីការរៀបចំនិងក្បួនដង្ហែចូលរួមក្នុងមិទ្ទីង ថ្ងៃ២០ ឧសភា ។ ការប្រារព្ធពិធីនេះនៅឆ្នាំ១៩៨៩ ១៩៩១ និង ១៩៩៩ រួមមានពិធីបំពាក់កម្រងផ្កា ចម្រៀង បទវិយោគកថា និងពិធីបង្សុកូលចំពោះអ្នកដែលបានបាត់បង់ជីវិត ការថ្លែងសុន្ទរកថាដោយអ្នកតំណាងចូលរួម ព្រមទាំងការរ៉ាយរាប់រឿងរ៉ាវផ្ទាល់ខ្លួនរបស់បុគ្គលម្នាក់ៗនិងគ្រួសារជនរងគ្រោះ (របាយការណ៍ពីស្រុកស្ទោងខេត្តកំពង់ធំ ស្តីពីទិវា២០ឧសភា ឆ្នាំ១៩៨៩ ដែលតម្កល់នៅមជ្ឈមណ្ឌលឯកសារកម្ពុជាលេខ៥៨១ និងឯកសារលេខ៤៩៨មកពីខេត្តស្ទឹងត្រែង និយាយពីទិវា២០ ឧសភា ១៩៩១ និងឯកសារកាសែត ខេមបូឌាដេលីឆ្នាំ ១៩៩៩) ។ ឯកសារទាំងនេះរួមជាមួយនឹងឯកសារដទៃផ្សេងទៀតបានបង្ហាញពីការរៀបរាប់អំពីមនោសញ្ចេតនាតាមរយៈវិយោគកថាដែលផ្តោតលើការចាំបាច់ក្នុងការប្រមូលអារម្មណ៍ និងចិត្តចងចាំមិនអាចបំភ្លេចបានដើម្បីការកសាងជាតិ ។ ពិធីនេះត្រូវបានរៀបចំឡើងដូចដែលរណសិរ្សចង់បាននៅតាមកន្លែងជាក់លាក់ដែលជាកន្លែងសម្លាប់និងកន្លែងឃុំឃាំងឬកន្លែងដែលមានសង់ចេតិយតម្កល់អដ្ឋិធាតុជនរងគ្រោះសម្រាប់ធ្វើបុណ្យរំឭក ។

ក្នុងន័យដើម្បីធ្វើការរំឭកនេះ ទិវាចងកំហឹងតែងតែត្រូវបានចងចាំមិនភ្លេចនូវសម័យកាលនយោបាយដ៏គួរឲ្យព្រឺព្រួចដែលមិនទាន់ត្រូវបានដោះស្រាយតាមផ្លូវច្បាប់ឲ្យបានសមស្របនៅឡើយ ។ ក្នុងខណៈដែលពិធីបុណ្យកំពុងតែប្រព្រឹត្តទៅដើម្បីឧទ្ទិសចំពោះជនរងគ្រោះដែលតាមការប៉ាន់ស្មានមានចំនួនប្រហែល ៣លាននាក់នោះ ជនដៃដល់ដែលបានប្រព្រឹត្តបទល្មើសក៏ឆ្លៀតឱកាសគំរាមកំហែងមកលើប្រទេសកម្ពុជាតាមរយៈការវាយប្រហារតាមព្រំដែនភាគខាងជើងនិងភាគខាងលិច ។ ការសង្កត់ធ្ងន់ទៅលើការរៀបរាប់និងចងចាំនូវរឿងជូរចត់ពីអតីតកាលបានធ្វើឲ្យទិវាចងកំហឹងនេះកាន់តែសំខាន់និងលើកទឹកចិត្តដល់ប្រជាជនក្នុងការចូលរួមកាន់តែខ្លាំងក្លាដូចដែល ជា ស៊ីម បានថ្លែងសុន្ទរកថាកាលពីឆ្នាំ១៩៨៦ ក្នុងទិវាចងកំហឹងថ្ងៃ២០ឧសភាថា÷ "សមមិត្តនិងមិត្តជាទីស្នេហា! អ្នកដែលបានបាត់បង់ជីវិតទៅកំពុងតែប្រាប់យើងឲ្យលើកកម្ពស់ការប្រុងប្រយ័ត្ន ពង្រឹងសាមគ្គីភាពនិងអនុវត្តសកម្មភាពបដិវត្តន៍ ។ យើងត្រូវតែមានការប្រុងប្រយ័ត្នចំពោះអំពើឃោរឃៅនិងល្បិចពិសពុលរបស់ខ្មាំងទោះក្រោមរូបភាពណាក៏ដោយ" ។

នៅក្នុងឆ្នាំ១៩៩០ នៅទីក្រុងភ្នំពេញ ទិវាចងកំហឹង ២០ ឧសភា ត្រូវបានប្រារព្ធឡើងយ៉ាងអធិកអធមនៅសារមន្ទីរប្រល័យពូជសាសន៍ទួលស្លែងនិងនៅមណ្ឌលឧក្រិដ្ឋកម្មបឹងជើងឯកក្នុងស្រុកដង្កោ ។ ក្នុងគោលបំណងប្រារព្ធទិវានេះនៅឆ្នាំ១៩៩០ រណសិរ្សប្រកាសថាទិវានេះ "ធ្វើឲ្យប្រជាជនបានដឹងពីឧក្រិដ្ឋកម្មថ្មីៗរបស់ពួក ប៉ុល ពត និងដើម្បីទប់ស្កាត់កុំឲ្យពួកវាវិលត្រឡប់មកកាន់អំណាចសាជាថ្មី" (សេចក្តីណែនាំក្នុងការប្រារព្ធទិវាចងកំហឹង២០ឧសភា ឆ្នាំ១៩៩០-ឯកសារលេខ៣៣១ តម្កល់នៅមជ្ឈមណ្ឌលឯកសារកម្ពុជា) ។

ក្នុងន័យនេះ វាហាក់ដូចជាមិនត្រឹមត្រូវឥតខ្ចោះទេក្នុងការកំណត់ទិវាចងកំហឹងជាថ្ងៃចងចាំនោះ ។ ទោះបីជាអនុស្សាវរីយ៍ដ៏គួរឲ្យព្រឺព្រួចគឺទិដ្ឋភាពសំខាន់មួយនៅថ្ងៃនោះក៏ដោយ ប៉ុន្តែក៏នៅមានសេចក្តីអំពាវនាវពីមជ្ឈិមឲ្យមានការចូលរួមពីសំណាក់មហាជនក្នុងការប្រែក្លាយការឈឺចាប់ទៅជាការកសាងនិងការពារមាតុភូមិកម្ពុជាថ្មី ។ តាមរយៈការប្រារព្ធពិធីជាផ្លូវការនិងជាសាធារណៈ មានការសង្កត់ធ្ងន់អំពីការជួយឧបត្ថម្ភគាំទ្ររបស់ប្រទេសវៀតណាមចំពោះប្រទេសកម្ពុជាជាច្រើនទសវត្សរ៍មុន ជាពិសេសក្រោយពេលរបបកម្ពុជាប្រជាធិបតេយ្យ និងនិយាយពីការពង្រឹង "ភាតរភាព" ជាមួយនឹងប្រទេសទាំងពីរ ។ វាជាការច្បាស់ណាស់ថាការអំពាវនាវឲ្យមានការចងចាំនូវ

អនុស្សាវរីយ៍ពីអតីតកាលនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ គឺតែងតែភ្ជាប់ទៅនឹងការដឹងគុណរបស់ប្រទេសកម្ពុជាចំពោះប្រទេសវៀតណាម ។ មិនតែប៉ុណ្ណោះសេចក្តីអំពាវនាវបានរំឭកដល់សារៈសំខាន់ចាំបាច់ក្នុងការពង្រឹងចំណងសាមគ្គីភាពរវាងប្រជាជាតិទាំងពីរ (ឬទាំងបីរួមទាំងប្រទេសឡាវ) ទៀតផង ដូចដែលបានបញ្ជាក់ច្បាស់តាមរយៈប្រសាសន៍របស់ ជា ស៊ីម នៅក្នុងទិវា ២០ឧសភា កាលពីឆ្នាំ១៩៨៦ថា "ប្រជាជនវៀតណាមបីជំនាន់ហើយដែលបានធ្វើពលិកម្មនៅក្នុងទឹកដីរបស់យើងដើម្បីប្រជាជនយើង...យើងសូមផ្ញើនូវការគោរពនិងដឹងគុណចំពោះមាតានិងបងស្រីវៀតណាមដែលបានលះបង់កូនចៅនិងប្តីសម្លាញ់មកបំពេញកាតព្វកិច្ចយុទ្ធសាស្ត្រដ៏ថ្លៃថ្លានៅក្នុងប្រទេសយើង" ។

ដូច្នេះការប្រារព្ធទិវា២០ឧសភា គឺជាពេលមួយដែលការយកចិត្តទុកដាក់របស់ប្រជាជនបានងាកទៅរកបញ្ហាអន្តរជាតិដែរ ។ នៅឆ្នាំ១៩៨៦ ជា ស៊ីម បានលើកឡើងអំពី "ល្បិចកលឆ្គតលីលានិងខ្មៅងងឹតរបស់ពួកខ្មែរក្រហមដែលទើបតែបានបង្កើត "រដ្ឋាភិបាលត្រីភាគីមួយ" នៅតាមព្រំដែនថៃ ។ ការលើកឡើងរបស់ ជា ស៊ីម ស្តីអំពីខ្សាំងអន្តរជាតិមានទម្ងន់ស្មើគ្នាទៅនឹងការពិភាក្សាស្តីអំពីទំនាក់ទំនងល្អជាមួយប្រទេសជិតខាងដូចជាវៀតណាម ឡាវ និងសហភាពសូវៀត ។ របាយការណ៍មួយចំនួនបង្ហាញថាសូម្បីតែក្នុងការប្រារព្ធទិវា ២០ ឧសភា នៅតាមមូលដ្ឋានជាពិសេសក្នុងអំឡុងទសវត្សរ៍ឆ្នាំ១៩៨០ ក៏មាននិយាយអំពីទស្សនៈវិស័យរបស់អន្តរជាតិដែរ ។ មានសេចក្តីរាយការណ៍ថាសភាពការណ៍នយោបាយភូមិសាស្ត្រអន្តរជាតិត្រូវបានពិភាក្សានៅតាមការប្រារព្ធពិធីថ្នាក់ស្រុកដែលមានមហាជនប្រមាណពីរ-បីពាន់នាក់ចូលរួមនៅឯបូជនីយដ្ឋានទួលក្អួង (របាយការណ៍ពីស្រុកស្ទោង ខេត្តកំពង់ធំ នៅពេលប្រារព្ធទិវា ២០ ឧសភា ឆ្នាំ១៩៨៩ តម្កល់នៅមជ្ឈមណ្ឌលឯកសារកម្ពុជាលេខ៥៨១) ។

នៅឆ្នាំ១៩៩០ រណសិរ្សបានធ្វើការសង្កត់ធ្ងន់ទៅលើការចាំបាច់ក្នុងការ "បំផុសព្រះសង្ឃនិងគណៈកម្មការវត្ត ប្រជាជនចាស់ជរា បញ្ញវ័ន្ត ព្រមទាំងជនជាតិភាគតិច" ឲ្យមានការពិភាក្សានិងថ្កោលទោសចំពោះពួក ប៉ុល ពត ហើយការថ្កោលទោសទៀតសោតគឺ "សំដៅបង្ហាញពីសារជាតិរបស់រដ្ឋាភិបាលចម្រុះត្រីភាគីកាលពីពេលនោះ ។ នយោបាយនិងលទ្ធផលដែលត្រូវបានរំពឹងទុកគឺជា "ការធ្វើញត្តិរបស់តុលាការនៅក្នុងទីក្រុង ហេក និងមេដឹកនាំសាសនានៅទូទាំងពិភពលោក" ដើម្បីទាញឲ្យមានការពាក់ព័ន្ធជាមួយនឹងរដ្ឋកម្ពុជា (សេចក្តីណែនាំក្នុងការប្រារព្ធទិវា ២០ ឧសភា ឆ្នាំ១៩៩០ ឯកសារលេខ ៣៣១ តម្កល់នៅមជ្ឈមណ្ឌលឯកសារកម្ពុជា) ។

ទោះបីជាការអនុវត្តជាក់ស្តែងនិងសេចក្តីថ្លែងការណ៍នៅក្នុងទិវាថ្ងៃ២០ ឧសភា បាន "ងាកចេញមករក" បញ្ហាសម្ព័ន្ធភាពនយោបាយភូមិសាស្ត្រអន្តរជាតិក៏ដោយ ប៉ុន្តែប្រទេសសំខាន់ៗដែលគាំទ្រដល់កម្ពុជាបានមានការប្រែប្រួលយ៉ាងសំខាន់នៅក្នុងអំឡុងពេលពីរទសវត្សរ៍ចុងក្រោយនេះ ។ នៅទសវត្សរ៍ទី១នៃការប្រារព្ធពិធីនេះ ទិវាចងកំហឹង ២០ឧសភា មានលក្ខណៈទោរទន់ទៅរកប្រទេសជិតខាងជាបងប្អូន (ដូចជា វៀតណាម ឡាវ) និងប្រទេសកុម្មុយនិស្តធំៗនៅក្នុងសហគមន៍អន្តរជាតិនិងសហភាពសូវៀត ។ មកត្រឹមចុងទសវត្សរ៍ឆ្នាំ៨០ និងចាប់ពីដើមទសវត្សរ៍ឆ្នាំ៩០មកដល់បច្ចុប្បន្ន ទិវាចងកំហឹង ២០ ឧសភា បាននិងក្លាយទៅជាការបើកទូលាយដ៏សំខាន់នៅក្នុងនោះមានការបង្ហាញនិងការតវ៉ានឹងប្រទេសដែលមិនមែនកុម្មុយនិស្ត ព្រមទាំងមហាសន្និបាតនិងអង្គការផ្សេងៗទៀតរបស់អង្គការសហប្រជាជាតិ ។ ឧទាហរណ៍ជាក់ស្តែង ការជួបប្រជុំគ្នារបស់បញ្ញវ័ន្តខ្មែរនៅមុនពេលប្រារព្ធទិវាចងកំហឹង ២០ឧសភា កាលពីឆ្នាំ១៩៨៨ បានថ្កោលទោសចំពោះរបប ប៉ុល ពត និងបានព្រមព្រៀងគ្នាជាឯកច្ឆ័នធ្វើញត្តិគាំទ្រការថ្កោលទោសនេះ ។ ញត្តិថ្កោលទោសត្រូវបានផ្ញើទៅអង្គការសហប្រជាជាតិនិងក្រុមប្រឹក្សាសន្តិភាពពិភពលោក ។ ញត្តិ...បានអំពាវនាវឲ្យអង្គការទាំងអស់នេះនិងមតិសាធារណៈពិភពលោកចាត់វិធានការប្រឆាំងនឹងពួក ប៉ុល ពត អៀង សារី ខៀវ សំផន ដែលត្រូវបានថ្កោលទោសជាអន្តរជាតិព្រមទាំងបរិវារ ហើយថ្កោលទោសចំពោះផែនការដ៏ខ្មៅងងឹតរបស់ប្រទេសនិងកម្លាំងមួយចំនួនដែលកំពុងតែផ្តល់ការគាំទ្រផ្តល់ទាំងផ្នែកសម្ភារនិងស្មារតីដល់ពួកប្រល័យពូជសាសន៍ ប៉ុល ពត ក្នុងគោលបំណងឲ្យពួកនេះវិលត្រឡប់មក

កាន់អំណាចកាប់សម្លាប់ប្រជាជនកម្ពុជាជាថ្មីនិងធ្វើការគំរាមកំហែងដល់ការរស់ឡើងវិញរបស់ជាតិ (អេស.ប៉េ.កា ថ្ងៃទី១៨ ខែឧសភា ឆ្នាំ១៩៨៨ ទំព័រ៣) ។

ឱកាសក្នុងការធ្វើញត្តិគាំទ្រជាអន្តរជាតិដែលបង្ហាញតាមរយៈទិវា២០ឧសភា បានបន្តរៀបចំឡើងមកដល់សព្វថ្ងៃនេះ ។ ប្រជាប្រិយភាពនៃទិវានេះនៅក្នុងឆ្នាំ១៩៩៩ និងឆ្នាំ២០០០ ទាំងជួរការនិងទាំងមិនជួរការនៅក្នុងសង្គមកម្ពុជាទាំងមូលត្រូវបានមើលឃើញតាមលក្ខណៈវិភាគថាជាសញ្ញាបង្ហាញឲ្យឃើញថាអង្គការសហប្រជាជាតិនិងអ្វីដែលហៅថា «មតិសាធារណៈពិភពលោក» មិនទាន់និងកំពុងតែមិនទទួលស្គាល់ពេញលេញដល់គ្រោះទុក្ខភ័យដែលកើតឡើងនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ និងអំពើហិង្សានិងភាពមិនប្រាកដប្រជាដែលកើតមានឡើងដោយការធ្វើអន្តរាគមន៍របស់អន្តរជាតិនានាទៅក្នុងទឹកដីកម្ពុជាទាំងមុនក្នុងអំឡុងពេលនិងក្រោយអំឡុងឆ្នាំ១៩៧៥-១៩៧៩ ។ ឧទាហរណ៍ សារព័ត៌មាន អាសូស៊ីអេតប្រេស បានរាយការណ៍នៅក្នុងឆ្នាំ២០០០ ថា «ដោយមានការអាក់អន់ស្រពន់ចិត្តចំពោះភាពមិនប្រាកដប្រជាដែលចេះតែបន្តនៅក្នុងការចរចាស្តីអំពីតុលាការប្រល័យពូជសាសន៍ មានប្រជាជនកម្ពុជារាប់រយនាក់ធ្វើការប្រមូលផ្តុំគ្នាធ្វើការបួងសួងសុំយុត្តិធម៌ក្នុងពេលប្រារព្ធពិធីរំឭកដល់ជនរងគ្រោះកម្ពុជាចំនួន ១លាន ៧សែននាក់ដែលស្លាប់បាត់បង់ជីវិតនៅក្នុងរបបខ្មែរក្រហម» (ដកស្រង់ពីកាសែត អេ ភី មានចំណងជើងថា ប្រជាជនកម្ពុជាបួងសួងសុំយុត្តិធម៌នៅក្នុងទិវាចងកំហឹង ២០ឧសភា ដែលចេញផ្សាយ ខែឧសភា ឆ្នាំ២០០០) ។

តាមរយៈកាសែត អេ ភី មានការបង្ហាញមតិពីសំណាក់អ្នកទោសគុកទួលស្លែងម្នាក់ដែលមានសំណាងរួចរស់រានមានជីវិតឈ្មោះ វ៉ាន់ ណាត ថា «ខ្ញុំបានសួរខ្លួនឯងជាច្រើនលើកច្រើនសាថាតើពេលណាទើបគេរកយុត្តិធម៌សម្រាប់រូបខ្ញុំព្រមទាំងជនរងគ្រោះដែលស្លាប់បាត់បង់ជីវិត...ចំពោះរូបខ្ញុំការស្វែងរកយុត្តិធម៌កាន់តែយឺតយ៉ាវណាស់ទៅហើយ ហើយខ្ញុំហាក់ដូចជាអស់សង្ឃឹមហើយពេលនេះ» ។

សរុបមក យើងអាចយល់បានថាទិវាចងកំហឹង ២០ ឧសភា ដែលត្រូវបានប្រារព្ធឡើងជាដំបូងតាំងពីទសវត្សរ៍នៃវត្តមានរបស់កងទ័ពនិងរដ្ឋបាលវៀតណាមនៅក្នុងប្រទេសកម្ពុជាបានធ្វើជាផ្តល់ឱកាសក្នុងការរៀបចំឲ្យមាន (អ្នកខ្លះយល់ថាបង្កើន) ទំនាក់ទំនងជិតស្និទ្ធនិងមានប្រយោជន៍ជាមួយនឹងប្រទេសវៀតណាម ។ ការប្រារព្ធទិវា២០ឧសភា បានរំឭកឡើងវិញនូវអនុស្សាវរីយ៍និងអារម្មណ៍របស់ប្រជាជនក្នុងអំឡុងឆ្នាំ១៩៧៥-១៩៧៩ និងបានផ្តល់ជាឱកាសដ៏មានន័យ និងមានលក្ខណៈវប្បធម៌ក្នុងការសម្តែងនូវកំហឹងនិងការឈឺចាប់ដែលទទួលរងដោយប្រជាជនម្នាក់ៗ និងទូទៅនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។ លើសពីនេះទៀត ទិវានេះត្រូវបានជំរុញដោយនយោបាយដើម្បីឲ្យប្រជាជនកម្ពុជាយល់ពីសារជាតិពិតរបស់ឧក្រិដ្ឋកម្មប្រព្រឹត្តនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យនិងយល់ថាជនដៃដល់ដែលមានការគាំទ្រពីរដ្ឋាភិបាលនៃប្រទេសផ្សេងៗ បានបន្តគំរាមកំហែងដល់ស្ថិរភាពដែលទើបតែបានបង្កើតឡើងនាពេលថ្មីៗ ។ **រ៉ាឆល ហ៊ូឌ**


មណ្ឌលឧក្រិដ្ឋកម្ម
បឹងជើងឯក

# សៀវភៅកំណត់ហេតុជីវិត

មជ្ឈមណ្ឌលឯកសារកម្ពុជាបានស្រាវជ្រាវរកឃើញសៀវភៅកំណត់ហេតុផ្ទាល់ខ្លួនជាង៤០០ក្បាល ដែលសរសេរឡើងនៅក្នុងរបបខ្មែរក្រហម ។ សៀវភៅកំណត់ហេតុទាំងនេះគឺជាកម្មសិទ្ធិរបស់កម្មាភិបាលខ្មែរក្រហមនិងជនរងគ្រោះ ។ សៀវភៅកំណត់ហេតុផ្ទាល់ខ្លួនរបស់កម្មាភិបាលខ្មែរក្រហម ជាទូទៅគឺជាការកត់ត្រាទុកនូវរឿងរ៉ាវផ្ទាល់ខ្លួនដែលពាក់ព័ន្ធទៅនឹងការងារប្រចាំថ្ងៃរបស់អង្គការ ការពិភាក្សានៅក្នុងអង្គប្រជុំជីវភាព ឬការអប់រំនយោបាយ ក្បួនទ័ពពីថ្នាក់មជ្ឈិម ។ ចំណែកឯសៀវភៅកំណត់ហេតុផ្ទាល់ខ្លួនរបស់ជនរងគ្រោះ ជាទូទៅគឺជាការកត់ត្រាទុកនូវរឿងរ៉ាវជីវិតដ៏សម្ងាត់ដែលមានតែនៅក្នុងជម្រៅបេះដូង ។ សៀវភៅកំណត់ហេតុផ្ទាល់ខ្លួនទាំងពីរប្រភេទនេះអាចជួយឲ្យយើងបានយល់ខ្លះថា ទោះជានៅក្នុងកាលៈទេសៈលំបាកវេទនា ឬការគាបសង្កត់ព្រៃផ្សៃយ៉ាងណាក៏ដោយ ក៏ការបញ្ចេញគំនិតអារម្មណ៍ នៅតែមិនអាចឃាត់ឃាំងបាន ។ ខ្ញុំសូមលើកយកសៀវភៅកំណត់ហេតុជីវិតមួយមកផ្សាយជូនទាំងស្រុងដូចខាងក្រោមនេះ ។

**ទីក្រុងប៉ារីស ថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥**

ថ្ងៃនេះជាថ្ងៃដែលពួកខ្មែរក្រហមបានចូលក្នុងទីក្រុងភ្នំពេញ ខ្ញុំហាក់សប្បាយរីករាយព្រោះសង្ឃឹមថានឹងបានជួបជុំគ្រួសារ ដែលបានព្រាត់ប្រាសមកជាងមួយឆ្នាំហើយ ។ ឃើញហាក់ដូចជាស្ពាយការចេញដំណើរទីពីររបស់ខ្ញុំ ខុសតែពីរថ្ងៃសោះខ្ញុំបាននៅឃើញព្រឹត្តិការណ៍ដ៏ជាក់ស្តែងផ្ទាល់នឹងភ្នែក ទំព័រប្រវត្តិសាស្ត្រមួយថ្មីក៏ត្រូវបើកឡើង... ។

**ទីក្រុងប៉ារីស ថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥**

ឱ! ពេលដែលខ្ញុំឮថាស្រុកខ្មែរ...មានសង្គ្រាមទៀតនោះ ចិត្តខ្ញុំហាក់...សប្បាយ ហើយនឹកឃើញថា...នឹងបានជួបមុខលោកឪពុកអ្នកម្តាយ...ក្នុងរយៈពេលដ៏ខ្លី ។ ឱ! អ្នក...ជាទីគោរព ពេលនេះតើលោក...កំពុងធ្វើអ្វី កូននៅចងចាំជានិច្ចសូរស័ព្ទសម្តីម៉ែ ពាក្យប្រៀនប្រដៅរបស់ម៉ែជាទីស្រឡាញ់តែមួយ ។ ទោះកូនទៅដល់ទីណាក៏ដោយ កូនតែងតែទទួលសេចក្តីសុខ និងការរាប់អានដ៏ស្មោះស្ម័គ្រពីអ្នកដទៃទាំងអស់ជាកុសលរបស់ម៉ែ ជាអំពើដោយសារម៉ែបានធ្វើដល់កូន ឮថាស្រុកយើងចប់សង្គ្រាម កូនស្រមៃហាក់ឃើញរូបកូនបានជួបជុំនិងលោកទាំងពីរ ។ ចិត្តកូនចង់តែត្រឡប់ទៅវិញឲ្យបានឆាប់ដើម្បីសាសព័ជាមួយអ្នកទាំងទ្វេនូវការនឹករលឹកដ៏គ្មាន...របស់កូន ។

ឱ! អ្នកម៉ែអើយ ពេលកូនធ្វើការឲ្យបារាំង កូនតែងរលឹកឃើញដល់ពេលដែលកូនធ្វើការនៅផ្ទះយើង ស្រុកយើងដែលអាចឲ្យមានប្រយោជន៍ដល់ជាតិយើង ពេលនោះកូនហាក់លែងចង់ធ្វើឲ្យវាភ្លាម ហើយចង់តែត្រឡប់ទៅវិញភ្លាម ។

ឱ! អ្នកមានគុណទាំងទ្វេ តើឥឡូវលោកមានសភាពបែបណា? សុខសប្បាយឬទេ? មានសុខភាពល្អឬទេ? ឪ! ខ្ញុំចង់ជួបមុខលោកណាស់ តើប៉ុន្មានថ្ងៃទៀតខ្ញុំអាចទទួលដំណឹង...! ចិត្តចង្អៀតចង្អល់ខ្វល់នឹកគ្មានល្ហែ នឹកដល់អ្នកម៉ែជាទីស្នេហាគ្មានដែលមានពេលណារសាយ ។

សង្គ្រាមចប់ហើយ តែកូននៅតែ...ឆ្ងាយពីម៉ែ ។ ចិត្តកូនតែងគិតៗឥតមានល្ហែដល់ទៅលោកម៉ែជារៀងរាល់ថ្ងៃ ព្រោះលោកមានវ័យចំណាស់ណាស់ទៅហើយ ឱ! លោកម៉ែ លោកពុកអើយ តែថ្ងៃណាកូនអាចជួបលោកទាំងទ្វេម្តងវិញនោះ ។

**ថ្ងៃទី១ ខែមិថុនា ឆ្នាំ១៩៧៥**

ខ្ញុំមកនៅបង់លីយ័រមួយឈ្មោះថា រុយអែល ម៉ាល់មេហ្សុង ក្នុងផ្ទះមួយដ៏ធំគួរឲ្យសប្បាយ តែចិត្តខ្ញុំរឹតតែនឹកៗទៅស្រុកណាស់ទៅទៀត ទេសភាពស្ងាត់ជ្រងំនៃទន្លេធ្វើឲ្យខ្ញុំរលឹកនឹកឃើញដល់ភូមិខ្ញុំ ។

ឱ! គ្មានអ្វីមួយដែលអាចឋិតថេរជាប់បានយូរទេតែងតែព្រាត់ប្រាសនិរាសគ្មានសល់ បាក់បែកខ្ទេចខ្ទីទៅតាមពេលវេលា ។ ថ្ងៃនេះសប្បាយ តែស្អែកអាចក្លាយជាព្រួយ ឱ!ជីវិតខ្ញុំមិនដឹងទៅជាអ្វីទេ? តើខ្ញុំអាចមានប្រយោជន៍សម្រាប់ជាតិឬទេ?

**ទីក្រុងប៉ារីស ថ្ងៃទី១០ ខែមិថុនា ឆ្នាំ១៩៧៥**

ពេលខ្ញុំចាប់សៀវភៅនេះកាលណា ខ្ញុំនឹកឃើញដល់មិត្តដែលជាម្ចាស់សៀវភៅហាក់ដូចជានៅនឹងមុខខ្ញុំ សើចញញឹមមក

រកខ្ញុំ ។ ស្គាល់គ្នាបានតែមួយភ្លែតរួចបែកគ្នា មិនដឹងថ្ងៃណាបានជួបថ្មីត្បិតតែខ្ញុំទើបនិងបានស្គាល់មិត្ត តែមិត្តហាក់ដូចជារាប់អានខ្ញុំដូចជាមិត្តម្នាក់ដែលមិត្តស្គាល់យូរមកហើយ ។ ការជួបជុំមិត្តភក្តិជជែកលេងពិតជាសប្បាយណាស់ ថ្វីត្បិតតែខ្ញុំបានស្គាល់មិត្តក្នុងរយៈពេលដ៏ខ្លីក៏ដោយ ក៏ខ្ញុំបានដឹងច្បាស់ពីការទុក្ខព្រួយរបស់មិត្ត មិត្តឲ្យខ្ញុំជួយដោះស្រាយពិភាក្សា តែនៅតែចេញមិនទាន់រួច ។ ឱ! ចិត្តមនុស្សពិតជាពិបាកនឹងស្មានឲ្យត្រូវណាស់ គ្មានអ្វីអាចវាស់អាចថ្លឹងបានទេហើយការប្រែប្រួលក៏រហ័សណាស់ទៅទៀត ។ សូម្បីតែមិត្តភក្តិដែលស្រឡាញ់រាប់អានណាស់ក៏ដោយក៏នៅតែមើលមិនអាចយល់ឲ្យអស់បានទេ នៅតែមានកន្ទុកកន្ទៀតរាប់មិនអស់ ។ ជាតិនេះខ្ញុំស្ទើរតែលើកដៃឡើងសច្ចាថាខ្លាចហើយមនុស្ស ។

ស្ទើរតែមិនដល់ពីរខែផងដែលខ្ញុំបានស្គាល់មិត្ត ថេរវេលាដ៏ខ្លីហួសវិស័យ តែអាចជាចំណងដៃមិត្តភាពគ្មានថ្ងៃភ្លេច ។

កូនសៀវភៅក្រហមដែលខ្ញុំកាន់នេះនឹងនៅជាមួយខ្ញុំរហូតថ្ងៃដែលខ្ញុំកាន់សៀវភៅនេះ គឺថ្ងៃមួយក្នុងខែមេសា ដែលជាខែដែលប្រទេសជាទីស្នេហាទទួលបដិវត្តន៍ទ្រឹស្តីក្រហមដ៏មានពណ៌ក្រហមឆ្អិនដូចសៀវភៅនេះ តើថ្ងៃណាទៅខ្ញុំបានជួបមិត្តជាថ្មីពេលជួបមិត្តជាថ្មី សៀវភៅដ៏ស្អាតនេះពិតជាពោរពេញទៅដោយទ្រឹស្តីចម្លែករបស់ខ្ញុំ ពេលនោះមិត្តនឹងបានមើលហើយនឹងអស់សំណើចមិនខាន ។

យប់ស្ងាត់ណាស់ទៅហើយ គ្មានឮស្នូរអ្វីក្រៅពីសំឡេងខ្យល់បក់ទេ មេឃក្តៅពីថ្ងៃប្រែជាត្រជាក់បន្តិចនៅពេលយប់ ។ ភាពស្ងាត់ជ្រងំធ្វើឲ្យរូបខ្ញុំស្រពន់ចិត្តក្រៃ ព្រោះនឹកស្រមៃដល់មិត្តថ្មីមថ្ងៃដែលទៅឆ្ងាយក្រៃមិនអាចហៅឮ ។ ណ្ហើយខ្ញុំលាសិនហើយ ឱ!មិត្តយើងអើយថ្ងៃក្រោយជួបគ្នា ។

ថ្ងៃទី១០ ខែមិថុនា ឆ្នាំ១៩៧៥

**ទីក្រុងប៉ារីស ថ្ងៃទី១៤ ខែមិថុនា ឆ្នាំ១៩៧៥**

យប់នេះខ្ញុំគេងយល់សប្តិឃើញរូបខ្ញុំបានជួបលោកម្តាយជាទីស្នេហា ។ ខ្ញុំស្ទុះទៅឱបថើបលោក រួចយំសោកយ៉ាងខ្លាំង ។ ខ្ញុំឃើញអ្នកម្តាយនៅមានសុខភាពដដែល ចិត្តកូនហាក់ដូចជាអរៗពេកកន្លង បានជួបលោក រូបកូនដូចហោះ សប្បាយពេកណាស់ តែកូនភ្ញាក់ឡើងកូនខំស្វាបរកតែជាការយល់សប្តិសោះ បើសុបិនកូនក្លាយជាការពិតនោះកូនពិតជាអស់កង្វល់ទៀតហើយ ។ កូនចង់ជួបលោកណាស់ ទោះបីម្តេចម្តាក៏កូនអស់ចិត្តដែរ ។

**ទីក្រុងប៉ារីស ថ្ងៃទី១៥ ខែមិថុនា ឆ្នាំ១៩៧៥**

នៅក្នុងជាតិនេះខ្ញុំបានសច្ចាក្នុងចិត្តថា ខ្ញុំដាក់ចិត្តស្រឡាញ់តែលើមនុស្សម្នាក់គត់ ។ អ្នកដែលស្រឡាញ់ខ្ញុំមានច្រើនតែមនុស្សដែលខ្ញុំស្រឡាញ់មានតែម្នាក់គត់ ។ ការជ្រើសរើសមនុស្សពិតជាពិបាកណាស់ ។ ខ្ញុំហាក់ដូចជាឆ្ងល់នឹងខ្លួនឯងដែរថា តើហេតុអ្វីបានជាខ្ញុំស្រឡាញ់ប៉ះលើមនុស្សម្នាក់ដែលសង្គមមនុស្សចាត់ថាជាមនុស្សដែលមានគុណវិបត្តិស្ទើរគ្រប់យ៉ាង ។ គឺមកពីខ្ញុំចង់ធ្វើការពិសោធន៍ ។ ឱ! ខ្ញុំដឹងហើយ គេថាកាលណាមានការស្រឡាញ់គឺមានទុក្ខ គឺជាការពិតណាស់ ។ តែចំពោះរឿងនេះបើសិនថាខ្ញុំដឹងថាគេមិនស្រឡាញ់តបវិញទេនោះ ខ្ញុំជឿជាក់ថាខ្ញុំខំធ្វើចិត្តខ្ញុំកុំឲ្យមានការសោហ្មង ហើយត្រូវចាត់ទុកថាជាសំណាងទៅវិញទេ ការពិតការចងជាគ្រួសារមួយគឺពិតជាដូចយកកទៅលនិងអន្ទាក់ ។ ដែលគេទុកគ្រាន់តែជារបោយនៃជីវិត ។ ជីវិតខ្ញុំៗអស់ចិត្តហើយបើសិនជាខ្ញុំស្លាប់ទៅក្នុងវ័យក្មេងទៀតនោះគឺរឹតតែប្រសើរជាងការរស់នៅក្នុងលោកដែលមានតែភាពដដែលៗ ។

សេចក្តីស្នេហារបស់ខ្ញុំដែលខ្ញុំសុខចិត្តប្រគល់ទៅឲ្យគេតែបើគេមិនទទួលវិញនោះក៏គ្មានអ្វីគួរឲ្យឈឺចាប់ដែរ ពេលនោះគឺយើងពិតជាដឹងច្បាស់ពីគុណភាពយើង ។

ចិត្តដែលស្រឡាញ់មានតែម្តង បើបែរជាខុសខ្ញុំសុខចិត្តនៅៗរហូតអស់មួយជីវិតវិញ មិនមែននៅក្នុងន័យថាស្មោះនឹងអ្នកទេ តែនៅដើម្បីយកជ័យជម្នះលើចិត្តឲ្យបាន នៅឲ្យដូចពាក្យដែលថានៅឲ្យដូចបំណាំងដែលបានគ្រោងទុក នៅឲ្យបរិសុទ្ធលុះថ្ងៃសូន្យ ជីវិតប្រៀបដូចក្បូនដែលលូនតាមទឹករហូតដល់ថ្ងៃទើរ ។ ខ្ញុំនឹងខំរស់យកជ័យជម្នះលើជីវិតខ្ញុំឲ្យបាន ខំសាងជីវភាពឲ្យបានសុខសាន្តក្នុងសេចក្តីថ្លៃថ្នូរ ។ ជីវិតមួយដែលស្គាល់តែការសាកល្បងស្ទើរគ្រប់កន្លែង ។ តើជីវិតគេឯទៀតដូចខ្ញុំឬទេ?

ឱ! នេះហើយបុប្ផៀងជីវិត!

ថ្ងៃទី១៧ ខែមិថុនា ឆ្នាំ១៩៧៥ ខ្ញុំមកដល់ ម៉ូស្គូ

**ម៉ូស្គូ ថ្ងៃទី២០ ខែមិថុនា ឆ្នាំ១៩៧៥**

ថ្ងៃនេះខ្ញុំបានធ្វើដំណើរកំសាន្តតាមមាត់ ផ្លាស នៅម៉ាហ្គា ទៅលេងកំពង់ផែនៅម៉ាហ្គា ទឹកដោរព្រៀបពេញច្រាំង រលកបោកមួយៗមកលើឆ្នេរខ្សាច់ដីណែន ធ្វើឲ្យខ្ញុំនឹកស្រមៃដល់ស្រុកកំណើត នឹកបងប្អូន មិត្តភក្តិ បើសិនជាបានមកជុំគ្នាប្រហែលជាសប្បាយ ។ ខ្ញុំនឹកឃើញដល់អនុស្សាវរីយ៍ ថ្ងៃទី៩ ខែមីនា ឆ្នាំ១៩៧៥ នៅភ្នំពេញដែលខ្ញុំបានជួបជុំមិត្តភក្តិជាច្រើនតែចិត្តខ្ញុំមិនសប្បាយទៅវិញ ព្រោះខ្ញុំទទួលពាក្យល្បែងគួរឲ្យឈឺចាប់ដែលប៉ះពាល់ដល់អំពើល្អដែលខ្ញុំបានធ្វើ ។ ថ្ងៃនោះខ្ញុំហាក់ដូចជាចង់ស្បថថាលែងចង់ធ្វើអំពើល្អជាមួយអ្នកណាទៀតហើយដើម្បីចៀសវាងការភ័ន្តច្រឡំនៃមនុស្សឯទៀត ការពិតគឺជាអំពើមួយដែលស្មោះអស់ពីដួងចិត្តគ្មានល្អក់បន្តិចឡើយ ។ ដូច្នេះហើយបានជាខ្ញុំស្ទើររាងចាលនឹងគំនិតនៃមនុស្ស ។ ថ្ងៃនេះជាចៃដន្យខ្ញុំបានដើរទៅជួបបារាំងពីរនាក់ហៅឡើងជិះកាណូតដើរលេងបានមួយជុំមើល កូដ ប្រឹតាញ គួរឲ្យសប្បាយដែរ គឺ ហ្វ្រង់ស័រ និង ហ្សង់ព្យែរ ។ មនុស្សទាំងឡាយដែលខ្ញុំជួបស្គាល់ខ្ញុំៗតែងចាត់ទុកដូចជាមិត្តឬជាមនុស្សដែលរួមដំណើរជាមួយគ្នា រួចហើយបែកគ្នាទៅ ។ ខ្ញុំនឹងខំតាំងចិត្តឲ្យនៅជាកណ្តាលជានិច្ច ។

ម៉ារហ្គា ថ្ងៃទី២០ ខែមិថុនា ឆ្នាំ១៩៧៥

## ថ្ងៃទី២១ ខែមិថុនា ឆ្នាំ១៩៧៥ នៅម៉ារហ្គា

ថ្ងៃនេះខ្ញុំបានទៅងូតទឹកនៅផ្លាស នៅម៉ារហ្គា ថ្ងៃលើកទីមួយហើយដែលខ្ញុំមកងូតទឹកនៅផ្លាស ស្រុកបារាំងទឹកត្រជាក់ណាស់តែអាចទ្រាំបានអាចងូតបាន ។ គួរឲ្យសប្បាយដែរ ទឹកថ្លាឆ្លុះដូចកញ្ចក់ គ្មានល្អក់សោះតែបែរជាផឹកមិនកើត ។ ម៉ារហ្គាទេសភាពគួរឲ្យគយគន់ ផ្ទះ ទីក្រុង គួរឲ្យទាក់ភ្នែក គួរឲ្យសប្បាយតែខ្ញុំនៅតែសប្បាយចាញ់សមុទ្រស្រុកខ្មែរ ចាញ់ផ្លែឈើស្រុកខ្មែរ ចាញ់ត្រីស្រុកខ្មែរ ចាញ់អ្វីៗទាំងអស់ដែលនៅស្រុកកំណើតខ្ញុំ ។

## ម៉ារហ្គា ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ១៩៧៥

១៥ថ្ងៃកន្លងទៅនៅម៉ារហ្គា ធាតុអាកាសល្អជានិច្ច ហាក់ជួយបំភ្លេចភាពកង្វល់របស់ខ្ញុំឲ្យអស់ពីគំនិត អស់ពីទ្រូង ព្រៃព្រឹក្សាទឹកសមុទ្រ ជើងភ្នំ ឆ្នេរខ្សាច់ល្វឹងល្វើយ ហាក់ជួយបបោសអង្អែលចិត្តខ្ញុំឲ្យមានក្តីសង្ឃឹមជានិច្ចក្នុងជីវិតប្រៀបដូចសមុទ្រពណ៌ផ្ទៃមេឃ និងផ្ទៃមេឃគ្មានពពក ។ តែសតិអារម្មណ៍ខ្ញុំនៅតែគិតៗជានិច្ចពីរឿងដែលកន្លងមកហើយនិងរឿងដែលអាចមកដល់ហើយនិងរឿងដែលមិនទាន់មកដល់ ។

ខ្ញុំឃើញគ្រួសារគេនៅជិតគ្នាខ្ញុំនឹកដល់គ្រួសារខ្ញុំ ឪពុកម្តាយជាទីស្រឡាញ់ ជាទីគោរព មិនដឹងថ្ងៃណាបានជួបលោកជាថ្មីពេលនឹកឃើញរឿងនេះហាក់ចង់ទៅស្រុកវិញឲ្យបានឆាប់ៗ ។ ពេលឃើញទេសភាពស្រុកគេខ្ញុំនឹកដល់ស្រុកខ្ញុំ ដល់ភូមិខ្ញុំ ដល់ដំណាំខ្ញុំ ដល់កិច្ចការខ្ញុំ ដល់អនុស្សាវរីយ៍កាលនៅពីតូចៗរហូតដល់ធំ ។ ថ្ងៃទី២៥ ខែមិថុនា ឆ្នាំ១៩៧៥ ខ្ញុំទៅ ប្រេស ជាលើកទីមួយ ប្រេស ជាទីក្រុងប្រហាក់ប្រហែលនឹងកំពង់ចាម ធ្វើចិត្តខ្ញុំរលឹកភ្លាមដល់ទីក្រុងកំណើត ។ រាត្រីចន្ទរះភ្លឺថ្លានៅលើភ្នំម៉ារហ្គា ស្ងាត់ជ្រងំត្រជាក់ញ័របំប្រប់ ខុសពីរាត្រីច័ន្ទរះភ្លឺថ្លានៅសំបួរមាស លើដៃទន្លេមេគង្គ ចាំងលើដើមដូងនិងស្លឹកល្ហុតនិងខ្សែទឹកហូររមេញ ព្រមជាមួយនិងវាយោរំភើយត្រជាក់ល្ហម ។ ទាំងនេះហើយដែលជាអនុស្សាវរីយ៍មិនអាចភ្លេចបាននៃស្រុកខ្ញុំ ។ ទោះតូច ទោះក្រ ទោះពិបាកម្តេចម្តា ខ្ញុំត្រូវតែត្រឡប់ទៅស្រុកវិញយកការចេះដឹងដ៏តិចតួចរបស់ខ្ញុំទៅជួយកូនខ្មែរ ដៃខ្ញុំដែលខ្មែរបានឲ្យខ្ញុំត្រូវតែទៅជួយខ្មែរវិញ ។

## ម៉ារហ្គា ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ១៩៧៥

រំលឹកឡើងវិញនូវអនុស្សាវរីយ៍កាលខ្ញុំនៅស្រុកខ្មែរ

ថ្ងៃអាទិត្យ ទី១០ ខែកុម្ភៈ ញ៉ាំបាយផ្ទះម៉ែ

ថ្ងៃច័ន្ទ ទី១១ ខែកុម្ភៈ ឆ្នាំ១៩៧៥ អាហារពេលល្ងាចមួយយ៉ាងរីករាយនៅផ្ទះ yx... ។

ថ្ងៃអាទិត្យ ទី៩ ខែមីនា ឆ្នាំ១៩៧៥ អាហារថ្ងៃត្រង់យ៉ាងគ្រោតគ្រាតមួយនៅផ្ទះ yx អនុស្សាវរីយ៍គ្មានថ្ងៃភ្លេច ។

ស្អែកឡើងថ្ងៃសៅរ៍ ខ្ញុំប្រមូលសំបុត្រទាំងអស់ដុតចោលនិងរូបថត តែចៃដន្យអ្វីនៅសល់សំបុត្រពីរ តើជាប្រផ្នូលយ៉ាងដូចម្តេច? ខ្ញុំគ្មានបំណងនិងលាក់ទុកទេតែហេតុអ្វីក៏នៅសល់ តើជាតិនេះយើងបានជួបគ្នាឬទេ? បើមិនបានជួបទេ ធ្វើម្តេចព្រេងវាសនាយើងសាងមកមិនត្រូវជួបគ្នា ខ្ញុំនិងខំតាំងចិត្តឲ្យនឹងជានិច្ច កុំឲ្យស្មុគ កុំឲ្យរំភើបញាប់ញ័រនិងអ្វីៗទាំងអស់ដែលខ្ញុំជួបប្រទះក្នុងជីវិតគឺត្រូវតាំងចិត្តឲ្យនៅជាកណ្តាលរហូត ។

**(នៅមានត)**

# គ្រួសារ ភោគ ឆាយ

មានលោកពូម្នាក់បានមកដល់មជ្ឈមណ្ឌលឯកសារកម្ពុជា ហើយសួរនាំរកឯកសារទាំងឡាយដែលមានការពាក់ព័ន្ធជាមួយនឹងករណីអ្នកទោសក្នុងរបបខ្មែរក្រហមនៅមន្ទីរស-២១ឈ្មោះ ភោគ ឆាយ និង ភោគ គី ។ លោកពូបានដំណឹងនេះខ្វះៗតាមរយៈការអានទស្សនាវដ្តី «ស្វែងរកការពិត» របស់មជ្ឈមណ្ឌលឯកសារកម្ពុជាដែលចេញផ្សាយជារៀងរាល់ខែ ។ លោកពូមានឈ្មោះថា ឆាយ មង្គលកែវ រស់នៅខេត្តបាត់ដំបង ។ លោក មង្គលកែវ ត្រូវជាក្មួយនិងជាកូនចិញ្ចឹមរបស់ជនរងគ្រោះនៅមន្ទីរ ស-២១ បុគ្គលទួលស្លែងឈ្មោះ ភោគ ឆាយ ហៅ ទូច (ទស្សនាវដ្តី «ស្វែងរកការពិត» បានចុះផ្សាយរួចមក ហើយនូវការសង្ខេបចម្លើយសារភាពទាំងស្រុងរបស់ ភោគ ឆាយ ក្នុងលេខ៥ និងលេខ៦) ។

មជ្ឈមណ្ឌលឯកសារកម្ពុជាបានរក្សានិងចងក្រងទុកយ៉ាងប្រយ័ត្នប្រយែងបំផុតនូវឯកសារចម្លើយសារភាពរបស់ជនរងគ្រោះនៅគុកទួលស្លែងដែលមានចំនួនដល់ទៅជាងបួនសែនសន្លឹក ក្នុងនោះមានឯកសារចម្លើយសារភាពរបស់ ភោគ ឆាយ ហៅ ទូច ចំនួន៨១សន្លឹក ។ យោងឯកសារលេខ D៣៨៩ ភោគ ឆាយ ហៅទូច ត្រូវបានបញ្ជូនមន្ទីរស-២១ នៅថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧៧ ។ រំលងអស់រយៈពេល៣ខែ និង២២ថ្ងៃ ក្រោយបន្ទាប់ពីមានការសួរដេញដោលយកចម្លើយសារភាពរួចមក ភោគ ឆាយ ហៅទូច ត្រូវបាន កម្មាភិបាលខ្មែរក្រហមសម្លាប់នៅថ្ងៃទី៦ ខែកក្កដា ឆ្នាំ១៩៧៧ ។ មានឯកសារមួយផ្សេងទៀតហៅថា «ឯកសារបញ្ជីសម្លាប់» ដែលរៀបចំឡើងដោយសមមិត្ត ហ៊ី នៅមន្ទីរស-២១ ចុះថ្ងៃទី៧ ខែកក្កដា ឆ្នាំ១៩៧៧ ដែលផ្ទៀងផ្ទាត់ឃើញដូចគ្នាបេះបិទទៅនឹងឯកសារលេខ D៣៨៩ ។ ក្នុងឯកសារក្រោយនេះខ្ញុំរកឃើញ ថាឈ្មោះរបស់ ភោគ ឆាយ ហៅ ទូច បានឈរលេខរៀងទី១២៣ ក្នុងចំណោមជនរងគ្រោះ ១២៧នាក់ ដែលត្រូវបានសម្លាប់នៅក្នុងថ្ងៃតែមួយ គឺថ្ងៃទី៦ ខែកក្កដា ឆ្នាំ១៩៧៧ ។ មុនត្រូវបានសម្រេចឲ្យយកទៅសម្លាប់ចោល ប្រវត្តិរូបរបស់ ភោគ ឆាយ ហៅ ទូច ត្រូវបានបញ្ជូនទៅអង្គការដើម្បីធ្វើការពិនិត្យនិងស្នើសុំយោបល់ផ្សេងៗ ។ ឯកសារនេះបានដល់ដៃ សុន សេន ដែលជារដ្ឋមន្ត្រីទទួលបន្ទុកកិច្ចការសន្តិសុខជាតិនៃរបបកម្ពុជាប្រជាធិបតេយ្យ ។ មានចំណារជាពិសេសមួយក្នុងចំណោមចំណារជាច្រើនរបស់ សុន សេន ដែលមាននៅលើឯកសារចម្លើយសារភាពរបស់ ភោគ ឆាយ បន្ទាប់ពីបានពិនិត្យយ៉ាងហ្មត់ចត់រួចមក សរសេរថា «អា ហ+ជ. អ/ក ហើយ ៣០/៣/៧៧» ដែលមានន័យថា ***«អានហើយនិងជូនអង្គការហើយ ថ្ងៃទី៣០ ខែមីនា ឆ្នាំ១៩៧៧»*** ។ តាមរយៈចំណារខ្មៅពណ៌ក្រហមធំមួយនេះអាចឲ្យយើងយល់បានទៀតថាទំនងជានៅមានថ្នាក់លើមួយឬច្រើនថ្នាក់ទៀតនៅពីលើ សុន សេន ដែលក្នុងនោះអាចប្រហែលមាន អៀង សារី ហៅ សមមិត្ត វ៉ាន់, ខៀវ សំផន ហៅ សមមិត្ត ហែម និង នួន ជា ហៅ សមមិត្ត នួន ។ របៀបប្រហាក់ប្រហែលគ្នានេះដែរមានឯកសារចម្លើយសារភាពជាច្រើនត្រូវបានចារដាក់ថា «សមមិត្ត វ៉ាន់» ដូចជាករណីឯកសារលេខ J០០៤១២ ជាចម្លើយសារភាពរបស់អ្នកទោសនៅទួលស្លែងឈ្មោះ មាឃ ទូច ហៅ កែម និង J០០៤៥១ ជាចម្លើយសារភាពរបស់ សាន់ ប៉ូ ។ ចំណារដាក់ថា «សមមិត្ត វ៉ាន់» អាចទំនងជាចំណាររបស់សមមិត្ត នួន (នួន ជា) ឬសមមិត្ត លេខា ប៉ុល ពត ព្រោះថាចំណារទាំងនោះត្រូវបានសរសេរនិងប្រើប៊ិកខុសប្លែកពីចំណាររបស់ សុន សេន ហៅ ខៀវ ទាំងស្រុង ។

ចម្ងល់ដ៏ធំមួយត្រូវបានចោទសួរថា អ្នកធ្វើបញ្ជីសម្លាប់ឈ្មោះ ហ៊ី ឬសុន សេន ឬមេដឹកនាំខ្មែរក្រហមណាផ្សេងទៀត

ដែលនឹងប្រឈមមុខក្នុងការទទួលខុសត្រូវលើការស្លាប់របស់ ភោគ ឆាយ ចំពោះមុខលោក មង្គលកែវ? លោក មង្គលកែវ និយាយថាក្នុងឆ្នាំ១៩៧៧ លោកបានទទួលសំបុត្រពីរច្បាប់ពី ភោគ ឆាយ ដែលក្នុងន័យសំបុត្រនោះ ភោគ ឆាយ បានផ្ដាំផ្ញើ និងរៀបរាប់អំពីការប្រុងប្រយ័ត្នខ្លួននិងខំធ្វើខ្លួនឲ្យបានល្អដើម្បី រស់នៅក្នុងសង្គមបដិវត្តន៍របស់ខ្មែរក្រហម ។ តាំងពីនោះមក លោក មង្គលកែវ ពុំដែលបានដំណឹងអ្វីឡើយអំពី ភោគ ឆាយ រហូតដល់លោកបានអានទស្សនាវដ្ដី "ស្វែងរកការពិត" និងដោយ មជ្ឈមណ្ឌលឯកសារកម្ពុជា បានផ្ដល់ឯកសារចម្លើយសារភាព របស់ ភោគ ឆាយ ជូនទើបលោកពូបានដឹងច្បាស់ពីមរណភាព នេះ ។ គិតទៅមានរយៈពេល២៣ឆ្នាំក្នុងការស្វែងរកព័ត៌មាននេះ ។ ទោះបីជា ភោគ ឆាយ ដែលជាឪពុកមាផង ជាឪពុកចិញ្ចឹមផង ស្លាប់បាត់បង់ជីវិតដោយអំពើអយុត្តិធម៌ក៏ដោយឯកសារទាំងឡាយ អំពី ភោគ ឆាយ គឺមានសារៈសំខាន់សម្រាប់លោក មង្គលកែវ ព្រោះថាលោកចង់ដឹងជាយូរមកហើយអំពីកាលបរិច្ឆេទពិតប្រាកដ នៃការស្លាប់នេះដើម្បីរៀបចំធ្វើបុណ្យទានបញ្ជូនកុសលផលបុណ្យ ដល់ ភោគ ឆាយ ដែលបានស្លាប់ទៅ ។ ម្យ៉ាងទៀតដើម្បីឲ្យ ព្រលឹង ភោគ ឆាយ និងព្រលឹងបងប្អូនដែលបានចែកឋានទៅ ហើយ ឲ្យទៅកាន់សុគតិភព ។ លោក មង្គលកែវ នៅតែមិនយល់ ក្នុងចិត្តទាល់តែសោះថាហេតុអ្វីបានជាខ្មែរក្រហមសម្លាប់ឪពុកមា ឬឪពុកចិញ្ចឹមរបស់គាត់ ។

តើ ហ៊ឹ អ្នកធ្វើបញ្ជីសម្លាប់នៅទួលស្លែង ឬមួយ សុន សេន ដែលចារនៅលើឯកសារឬមួយក៏បណ្ដាមេដឹកនាំខ្មែរក្រហមណា ផ្សេងទៀតដែលអាចដោះស្រាយចម្ងល់ហើយទទួលខុសត្រូវ ចំពោះមហាសោកនាដកម្មដែលកើតមានចំពោះក្រុមគ្រួសារ របស់លោកមង្គលកែវ? បន្ថែមពីលើចម្ងល់ នេះលោក ឆាយ មង្គលកែវ ចង់ដឹងថាតើនៅមានក្រុមគ្រួសាររបស់ ភោគ ឆាយ នៅរស់រានមានជីវិតដែលឬយ៉ាងណា? ជាពិសេសគឺប្រពន្ធរបស់ ភោគ ឆាយ ឈ្មោះ សៀ គីម ដែលនៅក្នុងឯកសារចម្លើយ សារភាពពុំមានបញ្ជាក់ថាស្លាប់ឬរស់ ។

**ខាន់ថាន់ ពៅដារ៉ា**

## ចំណាររបស់កម្មាភិបាលមន្ទីរស-២១លើ ចម្លើយសារភាពរបស់ ភោគ ឆាយ ហៅ ធុច

◆◆◆ តម្កល់ទុកកំណត់សម្គាល់ៈ

១) រាយការណ៍នៅថ្ងៃ៣.៤.៧៧

២) វាគេចបញ្ហា៦ចំណុច

៣) ឃើញបាតុភាពព្រាលៗ ។ ឌុច ៣.៤.៧៧

◆◆◆ មេរៀនទូច

១) សរសេរសាថ្មីម្ដងទៀតកុំឲ្យប្រឫកប្រចល់ឲ្យសោះ

- ឯកសារសន្ដិបាលកុំនិយាយ "។ល។"

- កុំនិយាយបូកសរុបគេឯង ។ ត្រូវបែងចែកបដិវត្ត និងក្បត់ បដិវត្តឲ្យច្បាស់ ។

- បញ្ហាជាចាំបាច់មួយចំនួនត្រូវលម្អិតថែម កុំសរុបខ្លីពេក ។

២) ប្រយ័ត្នចូលខបាយកល បំផ្លាញបដិវត្ត

- រក្សាកម្លាំងក្បត់ទុកដើម្បីបន្តបំផ្លាញបដិវត្ត

ពីរយ៉ាងនេះគឺមានឈ្មោះថាឃោរឃៅ ។ នឹងត្រូវទារុណកម្ម ធ្ងន់បន្តិចម្ដងៗរហូតទាល់តែស្លាប់ គឺស្លាប់ដោយវេទនាបំផុត ។

៣) រក្សាទុកច្បាប់ដើមនេះដាច់ខាត ។ ប៉ុន ថ្ងៃ៩.៤.៧៧

◆◆◆ បងណាង ស្នើបងពិនិត្យសេចក្ដីរាយការណ៍នេះរបស់បង ឡើងវិញ ។ បងជាមហាអ្នកចាំគ្រប់បញ្ហាយ៉ាងល្អិតល្អន់ ។ តាមខ្ញុំចាំ សេចក្ដីរាយការណ៍នេះមានល្បៀងច្រើនកន្លែងគួរសមដែរក្នុងនោះខ្ញុំ បានគូសនិងចារមួយកន្លែង ។ ស្នើបងពិនិត្យនិងកែតម្រូវឲ្យបាន ត្រឹមត្រូវសម្រាប់ជូនអង្គការដោយអនុគ្រោះផង ។ ឌុច ២៣.៤.៧៧

◆◆◆បងឌុច

១) ក្នុងអត្ថបទនេះ ខ្លឹមសារសំខាន់គឺ

- ធុច ខទ្មេសនាមឲ្យវាស្គាល់ ឌឿន ។ ពេល ធុច មានរឿង ឌឿន ណែនាំឲ្យវាធ្វើព្រងើយជាមួយ ធុច ហើយចាត់តាំងវាឲ្យទទួល ភារកិច្ចយកការណ៍សំខាន់ៗក្នុងកំណត់ហេតុរាយការណ៍ឲ្យ ឌឿន ។

- ពេល ឌឿន ត្រូវមកនៅក្រសួងពាណិជ្ជកម្ម ឌឿន បានខទ្មេសនាម ថេ ជានិរសាសម្ងាត់ សំរាប់នាំព័ត៌មានពីវាទៅរាយការណ៍បន្តឲ្យ ភុំ ឬឲ្យ ឌឿន ។

- ១១.៧៦ វាបានជួប ហ៊ូ នឹម នៅសាលាបក្ស ។ ហ៊ូ នឹម ណែនាំវាឲ្យប្រុងប្រយ័ត្ន ។

២) សំណួរដេញដោលរបស់ខ្ញុំគឺវាឲ្យនិយាយអំពីសកម្មភាពក្បត់ នៅមន្ទីរអង្គការ ។ វាសរសេរបដិសេធមួយលើកជាពីរលើក ។ តែខ្ញុំនៅតែធ្វើទារុណកម្មបង្ខំឲ្យវាសារភាព ដោយពុំមានណែនាំអ្វី ឲ្យប៉ះពាល់ដល់ឈ្មោះ ថេ ឬ ហ៊ូ នឹម ទេ ។ ការសង្កត់របស់ខ្ញុំ គឺឲ្យវាសរសេរអំពីការទាក់ទងជាមួយ ឌឿន និង ភុំ ប៉ុណ្ណោះ ។ ដោយគោរព ថ្ងៃ៥ មេសា ១៩៧៧ ប៉ុន ។ **ខាន់ថាន់ ពៅដារ៉ា**

# ១៧ មេសា ប៉ាលែងបានបង្ហោះខ្លែងឱ្យខ្ញុំរហូត

កាលនៅតូចប៉ាធ្លាប់បង្ហោះខ្លែងឲ្យខ្ញុំ តែឥឡូវខ្ញុំគ្មានប៉ាហៅទៀតទេ។ ឆ្នាំមុន ខ្ញុំមើលតាមបង្អួចឃើញតែប៉ាគេបង្ហោះខ្លែងឲ្យកូនគាត់លេង។ ឆ្នាំនោះមានមនុស្សផ្អើលនាំគ្នាលេងខ្លែងយ៉ាងច្រើននៅសួនវិមានឯករាជ្យភ្នំពេញ។ ពេលខ្លះខ្ញុំឃើញនគរបាលឃាត់។ មិត្តភក្តិខ្ញុំនាំគ្នាជជែកអ្នកខ្លះថាគេត្រូវថែសួនឲ្យបានល្អអ្នកខ្លះថាវាជាសេរីភាពរបស់អ្នកលេងខ្លែង។ ខ្ញុំមិននៅជជែកជាមួយគេទេ ខ្ញុំដើរមកបង្អួចមួយទៀតនៅស្ងៀមម្នាក់ឯង។ ខ្ញុំនឹកឃើញម្តាយខ្ញុំប្រាប់ថា ប៉ាខ្ញុំស្រលាញ់ខ្ញុំណាស់



សីម សុរិយ៉ា ឆ្នាំ១៩៨៥

ព្រោះខ្ញុំជាកូនពៅ គាត់រត់បង្ហោះខ្លែងឲ្យខ្ញុំទាល់តែរបូតសារុងក៏មានដែរ។ ខ្ញុំចាំខ្លួនឯងថាប៉ាច្រើនបង្ហោះខ្លែងឲ្យខ្ញុំមែន។ ឥឡូវខ្ញុំអាយុ៣២ឆ្នាំទៅហើយ ខ្ញុំនៅចាំមុខគាត់ច្បាស់ណាស់ ហើយខ្ញុំក៏នៅចាំកន្លែងបង្ហោះខ្លែងនោះដែរ ឥឡូវហៅថាភូមិបារាំងនៅជាប់ទីរួមខេត្តបាត់ដំបង។

ថ្ងៃចុងក្រោយដែលខ្ញុំឈប់បានលេងខ្លែងជាមួយប៉ានោះគឺថ្ងៃមួយដែលម៉ាក់ប៉ាខ្ញុំចាប់ដៃខ្ញុំជាប់។ ម៉ាក់ចាប់ដៃខ្ញុំម្ខាងកាន់កន្ត្រកស្ពាម្ខាង។ ខ្ញុំទាបជាងគេ មានមនុស្សកកកុញដើរប្រជ្រៀតគ្នាមើលផ្លូវសឹងមិនឃើញ។ ម៉ាក់ខ្ញុំប្រាប់ខ្ញុំថា ពេលនោះប៉ាខ្ញុំខឹងខ្លាំងណាស់តែម៉ាក់ប្រាប់ឲ្យគាត់នៅស្ងៀម។ ទាហានខ្មែរក្រហមបង្ខំឲ្យគាត់នៅបោះម៉ូតូម៉ូប៊ីឡែតរបស់គាត់ចោលហើយឲ្យទៅតែខ្លួន។ គាត់ក៏ត្រូវបង្ខំចិត្តដោះយកកង់មកធ្វើរទេះដាក់ឥវ៉ាន់ជាប់ខ្លួនទៅ។ ចំណែកឯម៉ូតូនោះត្រូវបោះចោលតាមផ្លូវត្រង់មុំសាលាតាអន ចម្ងាយប្រហែល១០គីឡូម៉ែត្រពីភូមិបារាំងតាមដងស្ទឹងសង្កែ។ យើងបានទៅដល់ភូមិស្នោចម្ងាយប្រហែលពីភូមិបារាំងមកភូមិតាអនដែរ។ ចាប់តាំងពីថ្ងៃត្រូវដកហូតម៉ូតូនោះមក ប៉ាមិនមាត់កនៅតែស្ងៀមហើយមិនសួរពីសារអ៊ីរហូតដល់ធ្លាក់ខ្លួនឈឺ។

ខ្ញុំចាំថាខ្ញុំកំពុងលេងដុំ (គ) ស្រាប់តែម៉ាក់ស្រែកថា "ប៉ាឯងស្លាប់ហើយ"។ ម៉ាក់ថា គ្រាន់តែពេទ្យដកម្ជុលចេញភ្លាមគាត់ដាច់ដង្ហើមស្លាប់ភ្លាម។ ចាប់ពីពេលនោះមកគិតទៅមិនបានប៉ុន្មានខែផង ខ្ញុំក៏ក្លាយជាក្មេងកំព្រា ម៉ាក់ខ្ញុំក្លាយជាស្ត្រីមេម៉ាយរហូតដល់សព្វថ្ងៃ។

ខ្ញុំមិនចង់ឃើញទិដ្ឋភាពបង្ហោះខ្លែងទៀតទេ វាធ្វើឲ្យខ្ញុំក្រៀមក្រំចិត្ត រំខានធ្វើការមិនកើត ដ្បិតនឹកឃើញដល់ភាពសុខសាន្តជួបជុំជាមួយប៉ាខ្ញុំ ភាពសុខសាន្តដែលខ្មែរក្រហមបានដណ្តើមយកទៅ។ គ្មានអ្វីអាចសងរបួសមនោសញ្ចេតនាភាពសុខដុមរមនានៃជីវិតខ្ញុំនិងគ្រួសារខ្ញុំបានឡើយ។ ក្នុងនាមជាអ្នកស្រាវជ្រាវប្រវត្តិរបបកម្ពុជាប្រជាធិបតេយ្យ ខ្ញុំគ្រាន់តែចង់ឲ្យព្រលឹងប៉ាខ្ញុំបានស្ងប់ឲ្យព្រលឹងគាត់បានដឹងការពិតមុខមាត់មេដឹកនាំដែលធ្វើឲ្យគាត់ស្លាប់ ព្រមទាំងប្រវត្តិសាស្ត្រនិងតុលាការទប់ស្កាត់បាតុភូតប្រល័យពូជសាសន៍នេះកុំឲ្យមានជាថ្មីម្តងទៀត។ **សីម សុរិយ៉ា**



សីម សុរិយ៉ា ឆ្នាំ១៩៩៧
ទទួលសញ្ញាប័ត្រមហាបរិញ្ញានៅសកលវិទ្យាល័យយ៉េល

**លោក ឆាំង យុ និពន្ធនាយកមជ្ឈមណ្ឌលឯកសារកម្ពុជា**

ខ្ញុំបានដំណឹងដោយក្តីរំភើបនិងរីករាយថាលោកបានទទួលមេដាយសេរីភាពទ្រូមែន-រីហ្គែន ។ យោងតាមទង្វើរបស់លោកក្នុងអតីតកាលនិងបច្ចុប្បន្ននេះលោកសក្តិសមនឹងទទួលរង្វាន់នេះណាស់ ។ លោកបានជួយការងារជនភៀសខ្លួននៅប្រទេសថៃនិងហ្វីលីពីន ។ ឯកសារដែលលោកបានចងក្រង ពិសេសការផ្សាយតាមទស្សនាវដ្តី "ស្វែងរកការពិត" ពិតជាមានសារៈប្រយោជន៍ណាស់ចំពោះតុលាការអន្តរជាតិឯករាជ្យមួយ ។ សេចក្តីក្លាហានរបស់លោកបានជួយព្យាបាលជំងឺបាក់ស្បាតក្នុងសង្គមខ្មែរបច្ចុប្បន្ន ។ ជំហររបស់លោកចំពោះការកាត់ទោសខ្មែរក្រហមបានទទួលការគាំទ្រយ៉ាងពេញទំហឹងពីសំណាក់ប្រជាពលរដ្ឋខ្មែរ ។

កន្លងមកអ្នកនយោបាយខ្លះបាននិយាយថា អ្នកមានសញ្ជាតិពីរច្រើនតែមិនស្មោះត្រង់នឹងជាតិ ប៉ុន្តែទង្វើរបស់លោកបានបញ្ជាក់យ៉ាងច្បាស់ថា ទោះជាសញ្ជាតិមួយឬប៉ុន្មានក៏ដោយឲ្យតែមានមនសិការជាតិ អ្នកនោះនៅតែបម្រើជាតិ ទោះជាក្នុងកាលៈទេសៈដ៏លំបាកយ៉ាងណាក៏ដោយ ។

លោកបានរកយុត្តិធម៌ជូនប្រជាពលរដ្ឋ ដោយស្វែងរកការពិតអំពីរបបខ្មែរក្រហមប្រល័យពូជសាសន៍ ។ នេះជាស្នាដៃដែលរួមចំណែកកសាងមាតុភូមិកម្ពុជាឲ្យមានសន្តិភាពនិងរីកចំរើនពិតជាក់ស្តែង ព្រោះអ្វីដែលប្រជាជនកម្ពុជាស្អប់ខ្ពើមនិងខ្លាចរអារគឺការកើតឡើងវិញនូវរបបប្រល័យពូជសាសន៍ថ្មីៗទៀតដែលកំពុងកើតឡើងនៅកម្ពុជា ដោយសារការពុំរកការពិត ឬពុំរកយុត្តិធម៌ប្រាកដជូនជនរងគ្រោះក្នុងរបបប្រល័យពូជសាសន៍ ១៩៧៥-១៩៧៩ ។

ខ្ញុំសូមសរសើរនិងគោរពដោយស្មោះចំពោះស្នាដៃសេចក្តីក្លាហាន និងការលះបង់ដ៏ខ្ពង់ខ្ពស់របស់លោក ក្នុងការបម្រើជាតិប្រជាជនដែលអ្នកដឹកនាំខ្មែរដទៃទៀតត្រូវតែចងចាំនិងរៀនសូត្រតាម ។

ខ្ញុំសូមជូនពរលោកឲ្យមានសុខភាពល្អ និងជ័យជម្នះថ្មីៗទៀតក្នុងការបម្រើជាតិ និងសង្គមមនុស្សទាំងមូល ។

ភ្នំពេញ,ថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០០០

**តំណាងរាស្ត្រមណ្ឌលកណ្តាល**

ភ្នំពេញ,ថ្ងៃទី៦ ខែវិច្ឆិកា ឆ្នាំ២០០០

នាងខ្ញុំឈ្មោះ សួន សាវ៉ាត់ នាមដើម អ៊ឹង ខាណៃ

**សូមគោរពជូនលោកនាយក ឆាំង យុ**

**កម្មវត្ថុៈ** សំណើសុំសួររកគ្រួសារ ។

នាងខ្ញុំឈ្មោះ សួន សាវ៉ាត នាមដើម អ៊ឹង ខាណៃ ភេទស្រី ទីកន្លែងកំណើត ភូមិពាលញែក២ សង្កាត់ផ្ទះព្រៃ ទីរួមខេត្តពោធិសាត់ ទីលំនៅបច្ចុប្បន្នផ្ទះលេខ១១$E_3$ ផ្លូវ១៧៣ ក្រុម៣ សង្កាត់អូឡាំពិក ខណ្ឌចំការមន ក្រុងភ្នំពេញ ដែលមានទូរស័ព្ទលេខ ០១១ ៩៥៦ ៧៣០-០១២ ៩៣០ ១៣៨ ។ សុំសួររកស្វាមីឈ្មោះ គឹម ភឿកឡឿង មុខងារជានាយទាហាននៃមេបញ្ជាការកងកាំភ្លើងធំ វរសេនាតូចលេខ២ ក្នុងសម័យសាធារណរដ្ឋខ្មែរ ។ ក្នុងឆ្នាំ១៩៧៣ រដ្ឋាភិបាលបានបញ្ជូនគាត់ឲ្យទៅសហរដ្ឋអាមេរិកដើម្បីសិក្សាជាមេបញ្ជាការកងវរសេនាធំ កងកាំភ្លើងធំទី១ ។ នាងខ្ញុំបានទទួលដំណឹងថាគាត់បានវិលត្រឡប់មកប្រទេសកម្ពុជាវិញក្នុងឆ្នាំ១៩៧៦ ក្នុងសម័យ ប៉ុល ពត ហើយបាត់ដំណឹងរហូតមិនដឹងថាគាត់ស្លាប់ឬរស់?

អាស្រ័យដូចបានជម្រាបជូនក្នុងកម្មវត្ថុខាងលើសូមលោកនាយកមេត្តាជួយស្រាវជ្រាវឲ្យនាងខ្ញុំដោយក្តីអនុគ្រោះ ។

សូមលោកនាយកមេត្តាទទួលនូវការគោរពរាប់អាននិងដ៏ខ្ពង់ខ្ពស់អំពីនាងខ្ញុំ ។

សូមជូនពរ សុខភាពល្អនិងជ័យជម្នះគ្រប់ភារកិច្ច ។

# ទ្រឹស្តីខ្មែរក្រហម

◆ **តាចាស់ទិកលចរិត គាត់រំលើងភ្នំដូចម្តេច? កាលណាស្លាប់ទៅកូនខ្ញុំនឹងបន្ត ការរះដីងរះតែបន្តទៅទៀត កាលណាកូនខ្ញុំស្លាប់ទៅ ចៅខ្ញុំខាបន្តទៅទៀត ការរះដីងរះតែធ្វើបន្តៗរហូតដល់គ្មានឈប់ឡើយ ចំណែកឯភ្នំទាំងពីរនោះ នោះបីធំយ៉ាងណាក៏ដោយ ខាពុំអាចធំធាត់បានឡើយ ផ្ទុយទៅវិញ កាលណាយើងជីកគាស់រលើងមួយរបបៗ ខានឹងរះតែរាបទៅៗ "ភ្នំតែហោង"។**

(ដកស្រង់ចេញពីសៀវភៅញែក ទំព័រទី៦០)

## គោរពជូនលោកនាយកមជ្ឈមណ្ឌលឯកសារកម្ពុជា ស្វែងរកការពិត

ខ្ញុំបាទឈ្មោះ រស់ បាពន្ធ ភេទប្រុស អាយុ៣៩ឆ្នាំ ធ្វើការ នៅអង្គការស្បៀងអាហារពិភពលោកប្រចាំការខេត្តកំពង់ធំ (WFP) ។

ថ្មីៗកន្លងមកនេះ ខ្ញុំបាទបានឃើញទស្សនាវដ្ដីនៃមជ្ឈមណ្ឌលឯកសារកម្ពុជាស្វែងរកការពិត តាមរយៈមិត្តម្នាក់ដែលខ្ចីគេបន្តមកទៀតគឺឯកសារលេខ១ ខែមករា ឆ្នាំ២០០០ រហូតដល់លេខ៤ ខែមេសា ឆ្នាំ២០០០ ។ ខ្ញុំបាទមានសេចក្ដីត្រេកអរជាច្រើនចំពោះប្រទេសកម្ពុជាយើងដែលបានរៀបចំឲ្យមានមជ្ឈមណ្ឌលឯកសារកម្ពុជានេះឡើង ព្រោះមានប្រយោជន៍ច្រើនយ៉ាងចំពោះប្រទេសកម្ពុជាយើង ហើយនេះក៏ឋិតនៅក្នុងវិស័យរបស់ខ្ញុំបាទដែលចូលចិត្តចង់ស្វែងយល់និងរក្សាទុកនូវអ្វីដែលជាប្រវត្តិសាស្ត្ររបស់ជាតិនិងជាកេរដំណែលដូនតាយើង ។ ជាមួយនេះដែរ ខ្ញុំបាទបានដើរធ្វើការច្រើនស្រុកក្នុងខេត្តកំពង់ធំ ហើយថ្មីៗនេះបានជួបនឹងពូម្នាក់ឈ្មោះ កង ទឹម ជាអតីតខ្មែរក្រហម សព្វថ្ងៃនៅភូមិឈូកបឹង ឃុំឈូក ស្រុកប្រាសាទសំបូរ ខេត្តកំពង់ធំ តែស្រុកកំណើតរបស់គាត់នៅស្រុកបារាយណ៍ ខេត្តកំពង់ធំ ។ ខ្ញុំបានអង្គុយស្ដាប់គាត់និយាយមួយយប់នូវរឿងគាត់ឆ្លងកាត់តាំងពីឆ្នាំ១៩៧០មក ប្រវត្តិរបស់គាត់នេះមានភាពជាក់ស្ដែងអាចកំបាំងច្រើន និងប្លែកពីទស្សនាវដ្ដីស្វែងរកការពិតទាំង៤ច្បាប់មកនេះទៀត ។ ប្រធាននេះបើលោកនាយកមានបំណងចង់ជួបខ្ញុំនឹងអាចជូនជួបបាន ។

ខ្ញុំបាទសំណូមពរជាវទស្សនាវដ្ដីនៃមជ្ឈមណ្ឌលឯកសារកម្ពុជាស្វែងរកការពិតឲ្យបានគ្រប់លេខតទៅ ទោះមានចេញមុនលេខ១នេះក៏ដោយ ។

ជាអវសាននេះ ខ្ញុំបាទសូមគោរពជូនពរលោកនាយកនិងសហការីទាំងអស់នូវពុទ្ធពរទាំង៤ប្រការ គឺអាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លាតឡើយ ។

កំពង់ធំ,ថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០០០

**រស់ បាពន្ធ**

---

កំពង់ចាម,ថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០០០

ខ្ញុំបាទឈ្មោះ កែវ សុមេធ នាយរងការិយាល័យរបៀបឯកសារសាលាខេត្តកំពង់ចាម ។

**សូមគោរពជូន**

**លោក ឆាំង យុ នាយកនិពន្ធទស្សនាវដ្ដីស្វែងរកការពិត នៅកម្ពុជា (ភ្នំពេញ)**

ខ្ញុំបានអាននិងទស្សនាសៀវភៅស្វែងរកការពិតតាំងពីលេខ១រហូតដល់លេខ៥ ធ្វើឲ្យខ្ញុំព្រមទាំងកុលបុត្រ-ធីតាខ្មែរមានក្ដីសង្វេគជាពន់ពេកដល់វិញ្ញាណក្ខ័ន្ធខ្មែរដែលបានត្រូវខ្មែរក្រហមសម្លាប់យ៉ាងរន្ធាលក្នុងរបប៣ឆ្នាំ ៨ខែ ២០ថ្ងៃ ក្នុងចន្លោះឆ្នាំ១៩៧៥ ដល់៧៩ កន្លងទៅនោះ ។

លោកនាយកជាទីគោរពដ៏ជ្រាលជ្រៅបំផុត!

ខ្ញុំសូមកោតសរសើរជាអនេកប្បការចំពោះថ្វីដៃរបស់លោកដែលសរសេរការពិតជម្រាបដល់កូនខ្មែរគ្រប់ស្រទាប់ដោយលាតត្រដាងនូវអំពើឧក្រិដ្ឋប្រល័យពូជសាសន៍របស់ពួកខ្មែរក្រហម ។

សូមឲ្យនិពន្ធនាយកព្រមទាំងសហការីទស្សនាវដ្ដីស្វែងរកការពិតរបស់លោកក្លាយទៅជាប្រទីបមួយបំភ្លឺដល់ពលរដ្ឋខ្មែរទូទៅក្នុងព្រះរាជាណាចក្រកម្ពុជាជាប់ជានិច្ចយូរអង្វែងឆ្នាំតទៅ ។

ម្យ៉ាងសូមលោកនាយកមេត្តាបោះពុម្ពបន្ថែមទៀតនូវទស្សនាវដ្ដីនេះឲ្យបានច្រើនដើម្បីផ្សព្វផ្សាយដល់ភូមិ-ឃុំក្នុងទូទាំងប្រទេសរបស់យើង ។

សូមលោកនាយកព្រមទាំងសហការីទទួលបាននូវជោគជ័យជូនៗក្នុងការស្រាវជ្រាវស្វែងរកការពិតជូនដល់ពលរដ្ឋខ្មែរ ។

សូមលោកមេត្តាទទួលនូវការគោរពដ៏ស្មោះស្ម័គ្រអំពីខ្ញុំ ។

**កែវ សុមេធ**

---

សូមសរសេរលិខិត
ឬអត្ថបទពិភាក្សាជុំវិញបញ្ហាខ្មែរក្រហម ផ្ញើមក
**ទស្សនាវដ្ដី «ស្វែងរកការពិត»**
ប្រអប់សំបុត្រលេខ ១១១០ ភ្នំពេញ
ព្រះរាជាណាចក្រកម្ពុជា
ឬតាមទូរសារលេខៈ (៨៥៥) (២៣) ២១០៣៥៨
ឬ Email: dccam@bigpond.com.kh

# ជនរងគ្រោះ











ចម្រៀងខ្មែរក្រហម

# ជំនោរកក្ដឹក

ជំនោរកក្ដឹកបក់ផ្លាក់ រអឹកមកពីឧត្ដរ លើមាតុភូមិកម្ពុជាបវរ
រំដោះស្ដាពរ ថ្ងៃ១៧មេសា ។
វាលស្រែទាំងឡាយ ភ្លឺផ្ទេកពណ្ណរាយ ពេញដោយផ្លែផ្កា
ស្រូវយើងទុំហើយ ពណ៌មាសសុទ្ធថ្លា ក្រោមពន្លឺសូរិយាបដិវត្តន៍ដ៏ឆ្អិនឆ្អៅ ។
មើលន៌ស្រែយើង មើលលយល្វើយល្វឹង សន្ធឹងសន្ធៅ
កួរស្រូវរេរាំក្រហមឆ្អិនឆ្អៅ បក់បោកសូរ ប្រាវយោលយោគតាមខ្យល់ ។
ជនបទកម្ពុជា ពិតពេញផង់ថ្លាទៅដោយហុចផល ល្អបរិបូរសាយសព្វមណ្ឌល
យើងប្រឹងខ្វាយខ្វល់ច្រូតទាន់វេលា ។
មើលដើមស្រូវ ទាន់ផ្លែដាក់គ្រាប់ធ្ងន់ កួរវែងអស្ចារ្យ
ដោយសារតែគុណមាគ៌ាអង្គការ ផលយើងធូរធារ សាងកម្ពុជាថ្មី ។
ក្រុមសាមគ្គីយើង ប្រមូលកម្លាំង ច្រូតកាត់ឃ្មាតខ្មី
យើងច្រូតយើងច្រៀង យើងបោកបែនភ្លាម ក្នុងស្រែធំៗ ។
យើងលើកទំនប់ លើកភ្លឺរាំងទប់ ត្រង់ខ្វែងខ្វាត់
ក្រឡាឈើត្រង់ លើស្រែប្រាំងទៀត ដាច់ខាតឯករាជ្យម្ចាស់ការ ។
យើងជាកសិករ រីករាយអបអរ ភោគផលយើងបាន
តែខំប្រយុទ្ធមុខក្លាហាន កម្ពុជាគ្រប់ប្រាណ លើកភ្លឺស្រែទៀត ។
កែប្រែជនបទ កម្ពុជាបដិវត្តន៍ ប្រៀបដូចដួងខែ
ពេញបរមីចាំងចែងទីស្រែ សាយសព្វទិសទីពេញ សកលលោក ។
យើងរួមសាមគ្គីសម្រុកមូលមីរសាងជាតិសាងស្រុក ។

**កត់ត្រាចងក្រងជាឯកសារ**
**កញ្ញា សើ សាយ្យាណា**

ដើម្បីឧបត្ថម្ភការបោះពុម្ពនិងចែកចាយដោយឥតគិតថ្លៃដល់មន្ទីរស្រុក និងឃុំ នៅទូទាំងព្រះរាជាណាចក្រកម្ពុជា
ទស្សនាវដ្ដីចំនួន១០០០ច្បាប់ជារៀងរាល់លេខនឹងដាក់លក់តែនៅក្នុងរាជធានីភ្នំពេញប៉ុណ្ណោះ មួយច្បាប់ក្នុងតម្លៃ ៧០០០រៀល

មជ្ឈមណ្ឌលឯកសារកម្ពុជាអំពាវនាវដល់រដ្ឋាភិបាល មូលនិធិនានា និងសាធារណជនគ្រប់រូប សូមជួយឧបត្ថម្ភការបោះពុម្ពផ្សាយទស្សនាវដ្ដីនេះទៅតាមលទ្ធភាពដែលអាចធ្វើបាន ។ ព័ត៌មានបន្ថែមចំពោះការបោះពុម្ពផ្សាយទស្សនាវដ្ដីស្វែងរកការពិត សូមមេត្តាទាក់ទងមកកាន់នាយកមជ្ឈមណ្ឌលឯកសារកម្ពុជាតាមទូរស័ព្ទលេខ (៨៥៥) ២៣ ២១១ ៨៧៥ ។ សូមអរគុណ!

The Documentation Center of Cambodia would like to appeal to governments, foundations and individuals for support of the publication of Searching for the Truth!. For contribution, please contact (855) 23 211 875 or By Email: dccam@bigpond.com.kh. Thank you.

A magazine of the Documentation Center of Cambodia: Searching for the Truth! Number 12, December 2000
Funded by the Royal Ministry of Foreign Affairs,Oslo, Norway, Section for the Human Rights and Humanitarian Assistance; the Canada Funds, Canadian Embassy,Phnom Penh; and the Swedish International Development Cooperation Agency (Sida), Embassy of Sweden, Phnom Penh; and the Royal Netherlands Government, *The Hague*.